របាយការណ៍លទ្ធផលស្រាវជ្រាវ

# បញ្ជីឈ្មោះអ្នកបោះឆ្នោត ការចុះឈ្មោះបោះឆ្នោត និង សវនកម្មបញ្ជីឈ្មោះឆ្នាំ ២០១១

ខុមហ្វ្រែល COMFREL

សហការជាមួយ

ខែមីនា ឆ្នាំ ២០១២

# ឧបត្ថម្ភដោយ

ខុមហ្វ្រែល COMFREL

**គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា**

ផ្ទះលេខ ១៣៨ ផ្លូវ ១២២ ទឹកល្អក់១ ទួលគោក ភ្នំពេញ ប្រអប់សំបុត្រលេខ ១១៤៥

ទូរស័ព្ទ ០២៣ ៨៨៤ ១៥០ ទូរសារ ០២៣ ៨៨៥ ៧៤៥

អ៊ីម៉ែល: comfrel@comfrel.org, comfrel@online.com.kh

គេហទំព័រ: www.comfrel.org

មាតិកា


បុព្វកថា ............................................................ 1

១. សេចក្តីផ្តើម ............................................................ 2

២. គោលបំណង និងវិធីសាស្រ្តនៃគំរោង ............................................................ 7

៣. លទ្ធផលនៃគំរោង ............................................................ 9

៤. ចំនុចខ្វះខាត និងការដកពិសោធន៍មេរៀនពីការងារអង្កេត ............................................................ 10

៥. សង្ខេបលទ្ធផលស្រាវជ្រាវ ............................................................ 12

៦. នីតីវិធីនៃការចុះឈ្មោះបោះឆ្នោត ............................................................ 15

៧. អានុសាសន៍ ............................................................ 20

៨. វិភាគទិន្នន័យ ............................................................ 22

៨.១ ការចុះឈ្មោះបោះឆ្នោត ............................................................ 22

៨.១.១ កំរិតនៃការចុះឈ្មោះបោះឆ្នោតតាមភេទ និងអាយុ ............................................................ 22

៨.១.២ អ្នកមានសិទ្ធិបោះឆ្នោតដែលមិនបានទៅចុះឈ្មោះបោះឆ្នោត តាមខេត្ត និងអាយុ ............................................................ 22

៨.១.៣ អ្នកមានសិទ្ធិចុះឈ្មោះបោះឆ្នោតដែលមិនបានចុះឈ្មោះបោះឆ្នោតប្រៀបធៀបជាមួយកំរិតអប់រំ ............................................................ 23

៨.១.៤ អ្នកដែលមានសិទ្ធិចុះឈ្មោះបោះឆ្នោតដែលមិនបានចុះឈ្មោះបោះឆ្នោតប្រៀបធៀបជាមួយមុខរបរ ............................................................ 24

៨.១.៥ មូលហេតុដែលមិនបានចុះឈ្មោះបោះឆ្នោត ............................................................ 24

៨.១.៦ អ្នកចុះឈ្មោះបោះឆ្នោតបានចុះឈ្មោះបោះឆ្នោតដោយមិនបានទៅដោយផ្ទាល់ ............................................................ 25

៨.១.៧ អ្នកមានសិទ្ធិបោះឆ្នោតដែលជួបការលំបាកក្នុងការចុះឈ្មោះ និងពិនិត្យបញ្ជីឈ្មោះបោះឆ្នោត ............................................................ 26

៨.១.៨ អ្នកមានសិទ្ធិបោះឆ្នោតជួបការលំបាកក្នុងការចុះឈ្មោះបោះឆ្នោតតាមខេត្តនីមួយៗ ............................................................ 26

៨.២ ព័ត៌មាននៃការចុះឈ្មោះបោះឆ្នោត ............................................................ 27

៨.២.១ ប្រភពព័ត៌មាននៃការចុះឈ្មោះបោះឆ្នោត ............................................................ 27

៨.២.២ ប្រភពព័ត៌មានពីការបោះឆ្នោត ............................................................ 28

៨.២.៣ ប្រភពព័ត៌មានពីការបោះឆ្នោតជាមួយការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ ២០១២ ............................................................ 29

៨.២.៤ បញ្ជីឈ្មោះបោះឆ្នោតដំបូង ............................................................ 30

៨.២.៥ ទំរង់ ១០១៨ សំរាប់បំរើឲ្យការបោះឆ្នោតនាពេលអនាគត ............................................................ 30

៨.២.៦ អត្តសញ្ញាណប័ណ្ណដែលផុតសុពលភាព ............................................................ 31

៨.៣ ការពិនិត្យបញ្ជីឈ្មោះបោះឆ្នោត ............................................................ 32

៨.៣.១ អ្នកបានចុះឈ្មោះបោះឆ្នោតបានពិនិត្យឈ្មោះនៅក្នុងបញ្ជីឈ្មោះ ២០១០ ............................................................ 32

៨.៣.២ មូលហេតុដែលអ្នកបានចុះឈ្មោះបោះឆ្នោតមិនបានពិនិត្យឈ្មោះនៅក្នុងបញ្ជីឈ្មោះ ២០១០ .................... 32
៨.៤ ភាពមិនប្រក្រតី .................................................................................................... 33
៨.៤.១ អត្តសញ្ញាណប័ណ្ណត្រូវបានគេដកហូត ........................................................................ 33
៨.៤.២ អត្តសញ្ញាណប័ណ្ណត្រូវបានគេដកហូតតាមខេត្ត ............................................................ 33
៨.៥ ភាពភ័យខ្លាច .......................................................................................................... 35
៨.៥.១ ភាពភ័យខ្លាចរបស់អ្នកបោះឆ្នោត ................................................................................ 35
៨.៥.២ មូលហេតុដែលបណ្តាលឲ្យមានការភ័យខ្លាច ................................................................... 35
៨.៥.៣ ការស្ទង់មតិស្តីពីប្រព័ន្ធចុះឈ្មោះបោះឆ្នោត ....................................................................36
៨.៦ ការចូលរួមរបស់អ្នកបោះឆ្នោត ....................................................................................36
៨.៦.១ អ្នកបោះឆ្នោតនឹងចូលរួមបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ ២០១២ ...........................36
៨.៦.២ មូលហេតុដែលអ្នកបោះឆ្នោតមិនចូលរួមបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ ២០១២ ..........................37
៨.៧ ឯកសារសំរាប់ការចុះឈ្មោះបោះឆ្នោត ...........................................................................37
៨.៧.១ អ្នកមានសិទ្ធិបោះឆ្នោតមានអត្តសញ្ញាប័ណ្ណជាតិខ្មែរ ..........................................................37
៨.៧.២ អ្នកបានចុះឈ្មោះបោះឆ្នោតប្រើប្រាស់ឯកសារសំរាប់ការចុះឈ្មោះបោះឆ្នោត ...............................38
៨.៨ ភាពត្រឹមត្រូវនៅក្នុងបញ្ជីបោះឆ្នោត ២០១១ ...................................................................39
៨.៨.១ ការផ្ទៀងផ្ទាត់ទិន្នន័យអ្នកបោះឆ្នោតនៅក្នុងបញ្ជីបោះឆ្នោត ២០១១ ធៀបនឹង បញ្ជីបោះឆ្នោត ២០០៨ .............39
៦. សន្និដ្ឋាន ..............................................................................................................40
ឧបសម្ព័ន្ធ ១ វិធិសាស្ត្រនៃការស្រាវជ្រាវ .............................................................................41
ឧបសម្ព័ន្ធ ២ កម្រងសំនួរសម្រាប់ការអង្កេត .........................................................................51
ឧបសម្ព័ន្ធទី ៣ បញ្ជីឈ្មោះបោះឆ្នោតគ ជ ប រូបភាពសកម្មភាព និងសំរង់ឯកសារផ្សេងៗ .......................59

# បុព្វកថា

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា ហៅកាត់ថា (**ខុមហ្វ្រែល**) ធ្វើការដើម្បីលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ និងការចូលរួមរបស់ប្រជាពលរដ្ឋ តាមគោលការណ៍កសាងសមត្ថភាពរបស់បណ្តាញទូទាំងប្រទេស និងសហប្រតិបត្តិការជាមួយអង្គការជាសមាជិក និងជាដៃគូ ។ លទ្ធិប្រជាធិបតេយ្យមិនមែនត្រឹមតែការបោះឆ្នោតនោះទេ ក៏ប៉ុន្តែការបោះឆ្នោតដោយសេរី និងយុត្តិធម៌ ជាលក្ខខណ្ឌចាំបាច់នៃលទ្ធិប្រជាធិបតេយ្យ ។

ខុមហ្វ្រែល (COMFREL) បន្តយ៉ាងខ្លាំងក្លាក្នុងការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ និងការបោះឆ្នោតដ៏ត្រឹមត្រូវផតក្លែងបន្លំ និងបែបប្រជាធិបតេយ្យ ។

ការជួយឲ្យមានការកែទម្រង់នៃការបោះឆ្នោត ខុមហ្វ្រែល និងភាគីពាក់ព័ន្ធការបោះឆ្នោតផ្សេងទៀតបានសហការរៀបចំធ្វើការអង្កេតស្រាវជ្រាវដើម្បីសិក្សាពីភាពមិនប្រក្រតីនៃការចុះឈ្មោះបោះឆ្នោត បញ្ជីឈ្មោះបោះឆ្នោត និងសវនកម្មបញ្ជី២០១១ ។ នៅពេលនោះ វាមិនទាន់មានការអង្កេតស្រាវជ្រាវដើម្បីដោះស្រាយបញ្ហាសំខាន់ៗមួយចំនួនដូចជា តើមានអ្នកមានសិទ្ធិបោះឆ្នោតប៉ុន្មាននាក់ដែលមិនទាន់បានចុះឈ្មោះនៅឡើយ និងមកពីមូលហេតុអ្វីខ្លះដែលមិនបានចុះឈ្មោះបោះឆ្នោត ជាពិសេសពីកំរិតនៃភាពត្រឹមត្រូវនៃបញ្ជីបោះឆ្នោត ២០១១ ។

នៅក្នុងការសិក្សាស្រាវជ្រាវនេះ ខុមហ្វ្រែល (COMFREL) មានមោទនភាព និងអំណរគុណដ៏ជ្រាលជ្រៅបំផុតដល់គ្រូបង្គោល អ្នកសង្កេតការណ៍ និងអង្គការមិនមែនរដ្ឋាភិបាលដៃគូមួយចំនួនដូចជា គណៈកម្មាធិការអព្យាក្រឹត្យ និងយុត្តិធម៌ដើម្បីការបោះឆ្នោតដោយសេរី និងត្រឹមត្រូវនៅកម្ពុជា (និកហ្វិច/NICFEC) មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព (ភីឌីភី/PDP) សមាគមយុវជនខ្មែរ (ឃេ វ៉ាយ អេ/KYA) ដែលបានចូលរួមយ៉ាងសកម្មនៅក្នុងប្រតិបត្តិការអង្កេតស្រាវជ្រាវក្នុងកំឡុងពេលពីខែ មិថុនា ២០១១ ដល់ខែ មករា ២០១២ ហើយដែលធ្វើអោយការស្រាវជ្រាវនេះបានសំរេចជាស្ថាពរ ។

ខុមហ្វ្រែល ក៏សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅនូវការផ្តល់សហប្រតិបត្តិការពីក្រសួងមហាផ្ទៃ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) គណបក្សនយោបាយសំខាន់ៗមួយចំនួន និងអជ្ញាធរគ្រប់លំដាប់ថ្នាក់ដែលពាក់ព័ន្ធ ។

ខុមហ្វ្រែល ក៏សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅដល់ម្ចាស់ជំនួយដូចជា ស្ថានទូតអង់គ្លេស, Forum Syd, NPA (Norwegian People's Aid) និងសហភាពអឺរ៉ុប(EU) ។

ជាពិសេស សូមថ្លែងអំណរគុណផងដែរដល់ក្រុមការងាររបស់ខុមហ្វ្រែល ដែលមានរាយនាម ដូចជា៖ លោក កន សាវង្ស លោក សុខ ពិទូរ្យ កញ្ញា គង់ រ៉ាវីន លោក គឹម ឈន លោក កុយ ច័ន្ទដារិទ្ធ អ្នកស្រី សៀង ដាលីយ៉ា អ្នកស្រី ភួង សុខកា លោក ប្លង់ បឿត លោក ស៊ិន ទិត្យសីហា លោក មាស សិរីសោភ័ណ លោក សួន យុធ្យា និងលោក Bruno Smith Vasconcello de Faria ក្រោមការដឹកនាំរបស់ លោក គល់ បញ្ញា នាយកប្រតិបត្តិ អង្គការ **ខុមហ្វ្រែល** ។

សូមថ្លែងអំណរគុណផងដែរចំពោះ លោកសាស្ត្រាចារ្យ មាយ កាម៉ារ៉ាន់ នៃសកលវិទ្យាល័យភូមិន្ទភ្នំពេញ ដែលបានផ្តល់ប្រឹក្សាបច្ចេកទេស និងវិធីសាស្ត្រស្រាវជ្រាវ ព្រមទាំងលោក Rob Savage ដែលបានចូលរួមផ្តល់យោបល់ ពិនិត្យ កែសំរួល និងផ្ទៀងផ្ទាត់របាយការណ៍នេះ។

របាយការណ៍នេះ បង្ហាញលទ្ធផលនៃការអង្កេត ដែលទាក់ទងទៅនឹងអ្នកបោះឆ្នោត ការចុះឈ្មោះបោះឆ្នោត បញ្ជីបោះឆ្នោត និងសវនកម្មបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០១១ ។

# បញ្ជីឈ្មោះអ្នកបោះឆ្នោត ការចុះឈ្មោះបោះឆ្នោត និងសវនកម្មបញ្ជីឈ្មោះ ២០១១

## ១. សេចក្តីផ្តើម

ការចុះឈ្មោះបោះឆ្នោតឆ្នាំ២០១១ សម្រាប់បម្រើឲ្យការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់ ឆ្នាំ២០១២បាន បញ្ចប់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតក្រុមប្រឹក្សាឃុំ/សង្កាត់ និងស្មៀនមួយចំនួនធំបានខិតខំ និងបំពេញតួនាទីដោយចុះឈ្មោះអ្នកបោះឆ្នោតបានជាង១៩២% (ចំនួន៩១៥,១៧៨រូប) នៃចំនួនប៉ាន់ប្រមាណទុក (៤៧៦,០៣៧រូប)។

ចំនួននេះអាចពន្យល់ថា មានកំហុសលើសប្រហែល៩២%នៃការប៉ាន់ប្រមាណតួលេខរបស់ គ.ជ.ប ចំពោះអ្នកមានសិទ្ធិបោះឆ្នោតយ៉ាងច្រើន។ ទោះបីយ៉ាងណាការសង្កេតឃើញថា ប្រជាពលរដ្ឋខ្លះនៅមិនបានចុះឈ្មោះបោះឆ្នោត ហើយក៏នៅមានការព្រួយបារម្ភ អំពីគុណភាពបញ្ជីផងដែរ។ ឧទាហរណ៍ប្រជាពលរដ្ឋបានកំពុងជួបការលំបាកខ្លាំងក្នុងស្ថានភាពទឹកជំនន់ធ្ងន់ធ្ងរ និងប្រជាពលរដ្ឋខ្លះដែលទទួលរងគ្រោះដោយជីផ្លី និងគ្មានឯកសារគ្រប់គ្រាន់ ដូចជានៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យជាដើម ដែលមានប្រជាពលរដ្ឋមួយចំនួននៅទីនោះមិនត្រូវបានមន្ត្រីចុះឈ្មោះបោះឆ្នោតឲ្យទេ ដោយខ្វះលក្ខខណ្ឌទីលំនៅ។

ការសង្កេតឃើញថា ការងារចុះឈ្មោះបោះឆ្នោតឆ្នាំនេះនៅតែមានបន្សល់នៅភាពមិនប្រក្រតីមួយ ដែលមានទាំងការអនុវត្តន៍នីតិវិធី និងការមិនទុកចិត្តរបស់គណបក្សនយោបាយ។

ការមិនទុកចិត្តពីសំណាក់គណបក្សនយោបាយ (ដែលធ្លាប់បង្ហាញការមិនទុកចិត្តកន្លងមក) កាន់តែកើនឡើងថែមទៀត ចំពោះការចុះឈ្មោះបោះឆ្នោត។ ប្រព័ន្ធប្រតិបត្តិការចុះឈ្មោះបោះឆ្នោត និងការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត ដែលត្រូវបានចាត់ចែងដោយសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ និងស្មៀនភាគច្រើន គឺមកពីគណបក្សប្រជាជនកម្ពុជា កាន់អំណាច (គណបក្សប្រជាជនកម្ពុជាត្រួតត្រាប្រធានក្រុមប្រឹក្សាឃុំ/សង្កាត់ និងប្រធានភូមិ៩៨%) ហើយជាបេក្ខជនសំខាន់របស់គណបក្ស ដែលត្រូវប្រកួតប្រជែងក្នុងការបោះឆ្នោត។ គណបក្សនយោបាយមិនកាន់អំណាចដូចជាគណបក្សសមរង្ស៊ី បានលើកឡើងអំពីការមិនបញ្ចូលសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ របស់គណបក្សពួកគេទៅក្នុងការងារចុះឈ្មោះបោះឆ្នោត និងការធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះ។

ការអប់រំ និងការផ្តល់ព័ត៌មានដល់អ្នកបោះឆ្នោតដែលចាត់ចែងដោយគណបក្សនយោបាយ ត្រូវបានបង្កឧបសគ្គដោយអាជ្ញាធរមូលដ្ឋានមួយចំនួន។

យុវជន គឺជាតួអង្គយ៉ាងសំខាន់សម្រាប់ការបោះឆ្នោតខាងមុខ ៥៤%[1] នៃចំនួនអ្នកបោះឆ្នោតសរុបជាយុវជនដែលមានអាយុចន្លោះពី ១៨ ទៅ ៣៥ ឆ្នាំ ព្រោះថាពួកគេមានចំនួនច្រើនក្នុងបញ្ជីឈ្មោះបោះឆ្នោត ដែលអាចធ្វើឲ្យលទ្ធផលបោះឆ្នោតមានការប្រែប្រួល។ បើទោះជាលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតសម្រាប់ឆ្នាំ២០១១នេះ ធ្វើលើសផែនការក៏ដោយ ប៉ុន្តែការសង្កេតរបស់ខុមហ្វ្រែលបានរកឃើញថា នៅមានយុវជនគ្រប់អាយុបោះឆ្នោតមួយចំនួន មិនបានទៅចុះឈ្មោះបោះឆ្នោត ដោយមូលហេតុថា ពួកគេមិនមានឯកសារបញ្ជាក់អត្តសញ្ញាណ មិនចាប់អារម្មណ៍ និងមិនយល់ពីសារៈសំខាន់នៃការបោះឆ្នោត ខ្វះព័ត៌មាន អស់ជំនឿនឹងការបោះឆ្នោត និងចំណាកស្រុក។ ឃុំ/សង្កាត់មួយចំនួន ដែលបានធ្វើការសង្កេតបានរកឃើញថាមានយុវជនមកចុះឈ្មោះបោះឆ្នោតមានចំនួនតិចរួមមាន សង្កាត់កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង, សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ, សង្កាត់វាលវង្ស និងសង្កាត់កំពង់ចាម ក្រុងកំពង់ចាម ខេត្តកំពង់ចាម, សង្កាត់រការធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ និងសង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ។

[1] លោក ទេព នីថា អគ្គលេខាធិការនៃគជប www.cen.com.kh (២១ ធ្នូ ២០១១)

ខាងក្រោមនេះ គឺព័ត៌មានពិស្តារអំពីភាពមិនប្រក្រតីក្នុងដំណើរការចុះឈ្មោះ ការអប់រំ និងផ្តល់ព័ត៌មានចុះឈ្មោះបោះឆ្នោត បរិយាកាសនយោបាយ ដំណើរការដោះស្រាយបណ្តឹង និងការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង។

***ភាពមិនប្រក្រតីក្នុងដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត៖***

ក្នុងចំណោមឃុំ/សង្កាត់ទាំង៧២ដែលខុមហ្វ្រែលសង្កេត ខុមហ្វ្រែល បន្តរកឃើញភាពមិនប្រក្រតីមួយចំនួន។ ភាពមិនប្រក្រតីនៅក្នុងឃុំ/សង្កាត់ទាំងនេះ អាចមានច្រើនជាងទិន្នន័យដែលខុមហ្វ្រែលសង្កេតឃើញ ដោយការសង្កេតរបស់ខុមហ្វ្រែល គឺធ្វើជាលក្ខណៈចល័ត និងមិនប្រចាំការពេញមួយថ្ងៃនោះទេ។ ភាពមិនប្រក្រតីទាំងនោះមានដូចជា៖

**យឺតយាវក្នុងការបិទផ្សាយរបាយការណ៍ស្តីពីលទ្ធផលនៃការចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឲ្យការបោះឆ្នោតនៅសាលាឃុំ/សង្កាត់**ចំនួន ៣សង្កាត់ នៅសង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល, សង្កាត់កែប និងសង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប។

**ធ្វើការបដិសេធន៍មិនចុះឈ្មោះឲ្យប្រជាពលរដ្ឋចំនួន៤នាក់** ក្នុងសង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្តាលដោយមន្ត្រីចុះឈ្មោះបានយោងមូលហេតុថា អ្នកទាំងនោះមិនទាន់បានលុបឈ្មោះបោះឆ្នោតរបស់ខ្លួនពីកន្លែងចាស់។

**ស្មៀនមិនគោរពម៉ោងធ្វើការចំនួន១២ឃុំ រួមមានមកធ្វើការយឺត និងចេញទៅមុនម៉ោង និងការមិនមកធ្វើការ៖** ក្នុងឃុំម៉ាលិច ស្រុកអណ្តូងមាស ខេត្តរតនៈគីរី នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១១ ស្មៀនឃុំមិនបានមកបំពេញការងារ ខណៈពេលដែលមានប្រជាពលរដ្ឋប្រមាណ១៩រូបរង់ចាំចុះឈ្មោះ ហើយទីបំផុតមិនអាចចុះឈ្មោះបានទើបប្រជាពលរដ្ឋត្រឡប់ទៅផ្ទះវិញ និងករណីដូចគ្នានេះបានកើតឡើងក្នុងសង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ ប៉ះពាល់ប្រជាពលរដ្ឋប្រមាណ៣៥នាក់។ ឃុំ/សង្កាត់ផ្សេងៗទៀតរួមមាន៖ សង្កាត់លេខ២ និងសង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ, សង្កាត់កោះធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ, សង្កាត់តាខ្មៅ សង្កាត់តាក្តុល និងសង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្តាល, សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ, សង្កាត់ទួលល្វា និងសង្កាត់ប៉ៃលិន ក្រុងប៉ៃលិន ខេត្តប៉ៃលិន និងសង្កាត់ក្រាំងអំពិល ក្រុងកំពត ខេត្តកំពត។

**ការចុះឈ្មោះអ្នកបោះឆ្នោតដោយមិនមានវត្តមានអ្នកបោះឆ្នោតចំនួន** (យកឯកសារចុះឈ្មោះឲ្យ) ៤ឃុំ ដូចជាសង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនៈគីរី មានករណីប៉ូលីសប៉ុស្តិ៍រដ្ឋបាលដើរប្រមូលឈ្មោះ និងឯកសារបញ្ជាក់អត្តសញ្ញាណរបស់អ្នកគ្រប់អាយុបោះឆ្នោតមួយចំនួន ទៅឲ្យស្មៀនចុះឈ្មោះ ដោយសាមីខ្លួនមិនមានវត្តមានចំពោះមុខស្មៀនដោយផ្ទាល់។ ឃុំ/សង្កាត់ផ្សេងទៀតរួមមាន៖ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ និងសង្កាត់តាខ្មៅ និងសង្កាត់តាក្តុល ក្រុងតាខ្មៅ ខេត្តកណ្តាល។

**ករណីបាត់ឈ្មោះអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោតចុងក្រោយ**ចំនួន២ឃុំ ដូចជា នៅសង្កាត់លេខ៤នៃក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ប្រជាពលរដ្ឋដែលមកពិនិត្យឈ្មោះបានបាត់ឈ្មោះរបស់ខ្លួនពីបញ្ជីបោះឆ្នោតចុងក្រោយច្រើននាក់។

**ការខកខាន ឬយឺតយ៉ាវបិទបញ្ជីឈ្មោះបោះឆ្នោតចុងក្រោយឆ្នាំ២០១០** ចំនួន២ឃុំ នៅឃុំសំពោងយា ស្រុកពួក ខេត្តសៀមរាប និងឃុំលំជ័រ ស្រុកអូរយ៉ាដាវ ខេត្តរតនៈគីរី។

**ករណីយឺតយ៉ាវ ឬមិនមានការបិទផ្សាយកម្មវិធី/ប្រតិទិនចុះឈ្មោះបោះឆ្នោត** ចំនួន ៦ឃុំ/សង្កាត់ នៅសង្កាត់ឡាបានសៀក កាចាញ និងយក្ខឡោម នៃក្រុងបានលុង ឃុំលំជ័រ ស្រុកអូរយ៉ាដាវ ឃុំបាតាង ស្រុកលំផាត់ ខេត្តរតនៈគីរី និងសង្កាត់ទួលល្វា ក្រុងប៉ៃលិន ខេត្តប៉ៃលិន។

**ករណីចុះឈ្មោះអ្នកបោះឆ្នោតដោយមិនបំពេញគ្រប់លក្ខខណ្ឌមាន ២ឃុំ/សង្កាត់** នៅសង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្តាល និងសង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ ដែលស្មៀនបានចុះឈ្មោះអ្នកប្រើអត្តសញ្ញាណប័ណ្ណថតចម្លង។

**ទីតាំងការិយាល័យចុះឈ្មោះមានស្លាកសញ្ញាគណបក្សប្រជាជនកម្ពុជា** ចំនួន២ករណី ដូចជានៅសង្កាត់ប៉ៃលិន ក្រុងប៉ៃលិន ខេត្តប៉ៃលិន ដែលខុសនឹងនីតិវិធី និងបទបញ្ជាបោះឆ្នោតឆ្នាំ២០០៨ ប្រការ៥.៧.៥.១ ដែលហាមឃាត់ ការស្លៀកពាក់ ឬការបិទផ្សាយ ឬការនិយាយ ដែលមានការពាក់ព័ន្ធជាមួយគណបក្សនយោបាយ ឬបេក្ខជននៃគណបក្សនយោបាយណាមួយ។

***ការអប់រំ និងការផ្តល់ព័ត៌មានអំពីការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត៖***

នៅដំណាក់កាលដំបូង ការងារអប់រំអ្នកបោះឆ្នោតដោយអង្គការមិនមែនរដ្ឋាភិបាល និងគណបក្សនយោបាយនៅឃុំ/សង្កាត់មួយចំនួន ត្រូវអាជ្ញាធរមូលដ្ឋានរួមទាំងកម្លាំងប្រដាប់អាវុធបានតាមដាន និងបង្ហាញអាកប្បកិរិយាមិនសហការ/គាំទ្រដល់សកម្មភាពរបស់គណបក្សនយោបាយមួយចំនួន ដែលធ្វើការអប់រំអ្នកបោះឆ្នោតឲ្យទៅពិនិត្យបញ្ជីឈ្មោះបោះឆ្នោត និងចុះឈ្មោះបោះឆ្នោត។ ជាក់ស្តែងរហូតដល់មានករណីប្តឹងប្តល់ដល់អ្នកតំណាងរាស្ត្រ មូរ សុខហួរ មកពីគណបក្សសមរង្ស៊ី ដោយចោទសង្កាត់ក្បាលកោះ ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញទៅគ.ជ.ប ក្រោមហេតុផលសណ្តាប់ធ្នាប់សាធារណៈ តែបណ្តឹងនេះត្រូវ គ.ជ.ប បដិសេធ ដោយហេតុផលថាមិនមែនជាសមត្ថកិច្ចរបស់ខ្លួន។

ការសង្កេតរបស់ខុមហ្វ្រែលបានរកឃើញថា ប្រជាពលរដ្ឋប្រមាណ៣០% ក្នុងឃុំ/សង្កាត់ដែលខុមហ្វ្រែលធ្វើការសង្កេតមិនបានដឹងអំពីព័ត៌មានថាក្នុងភូមិរបស់ពួកគាត់នឹងមានការចុះឈ្មោះបោះឆ្នោតនោះទេ។ គួរបញ្ជាក់ផងដែរថាបើតាមសេចក្តីណែនាំរបស់ គ.ជ.ប កបឃ/ស និងស្មៀនត្រូវកំណត់ និងផ្សព្វផ្សាយជាសាធារណៈពីរយៈពេលកាលបរិច្ឆេទ និងប្រតិទិននៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតក្នុងឃុំ/សង្កាត់របស់ខ្លួនថាតើខ្លួនធ្វើនៅសាលាឃុំ/សង្កាត់ប៉ុន្មានថ្ងៃ នៅតាមភូមិប៉ុន្មានថ្ងៃ និងភូមិណាខ្លះក្នុងឃុំ/សង្កាត់នោះ។

មូលហេតុដែលប្រជាពលរដ្ឋមិនបានដឹងព័ត៌មានថា ភូមិរបស់ខ្លួននឹងមានការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតមានដូចជា គ្មានព័ត៌មាន(ការផ្សព្វផ្សាយមិនបានទូលំទូលាយ) មិនចាប់អារម្មណ៍ជាប់រវល់ និងរបរទទួលទានប្រចាំថ្ងៃ និងមានការរើសអើងនិន្នាការគណបក្សនយោបាយ។ ជាក់ស្តែងក្នុងសង្កាត់តាខ្មៅ និងសង្កាត់ព្រែកហូរ មានសេចក្តីរាយការណ៍ថាមន្ត្រីចុះឈ្មោះបោះឆ្នោតហាក់មានការបិទបាំង ប្រើអាកប្បកិរិយា ពាក្យសំដីមិនសមរម្យ មិនមានការរើសអើងក្នុងការផ្តល់ព័ត៌មានចំពោះអ្នកសង្កេតការណ៍ និងអ្នកគាំទ្រគណបក្សប្រឆាំង។ ឃុំ/សង្កាត់ដែលប្រជាពលរដ្ឋបានដឹងព័ត៌មានខាងលើនេះតិចជាងគេរួមមាន សង្កាត់ប៉ៃលិន និងសង្កាត់អូរតាវៅ ខេត្តប៉ៃលិន, ឃុំសំរោងយា ស្រុកពួក និងសង្កាត់សំបួរ ក្រុងសៀមរាប ខេត្តសៀមរាប, សង្កាត់កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង, និងសង្កាត់លេខ២ និងសង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

***បរិយាកាសនយោបាយ៖***

ក្នុងដំណាក់កាលនេះ បើទោះជាគ្មានសេចក្តីរាយការណ៍ពីករណីឃាតកម្មពាក់ព័ន្ធសកម្មជននយោបាយ និងករណីទម្លាក់ ឬបំផ្លិចបំផ្លាញស្លាកសញ្ញាគណបក្សនយោបាយក៏ដោយ ប៉ុន្តែខុមហ្វ្រែលនៅមានការព្រួយបារម្ភចំពោះការគំរាមកំហែង និងការធ្វើទុក្ខបុកម្នេញទៅលើសកម្មជននយោបាយ ពិសេសទៅលើគណបក្សជំទាស់តាមរយៈប្រព័ន្ធតុលាការ រដ្ឋសភា និងស្ថាប័នរដ្ឋមួយចំនួនទៀត។ ជាក់ស្តែងថ្មីៗនេះមានករណីព្យួរអភ័យឯកសិទ្ធិអ្នកតំណាងរាស្ត្រ **ចាន់ ចេង** របស់គណបក្សសមរង្ស៊ី ដែលត្រូវបានគេមើលឃើញថាអភ័យឯកសិទ្ធិរបស់តំណាងរាស្ត្រ គឺមិនខុសពីប្រជាពលរដ្ឋសាមញ្ញទេ សូម្បីតែបទលហុ និងបទមជ្ឈិមស្រាល ក៏អភ័យឯកសិទ្ធិនោះ ត្រូវបានដកយ៉ាងងាយដែរ។

ក្នុងរយៈពេលនេះដែរទាក់ទងការបញ្ចេញមតិខាងនយោបាយ ក៏មានករណីចាប់ខ្លួន និងឃុំខ្លួនសកម្មជនគណបក្សនយោបាយប្រឆាំងចំនួន៣រូប ដែលមកពីគណបក្សសិទ្ធិមនុស្ស២រូប ដែលគ្រាន់តែផ្សព្វផ្សាយឯកសារគោលនយោបាយគណបក្ស និងឯកសារប្រវត្តិសាស្ត្រខ្មែរឲ្យសមាជិកខ្លួន និងគណបក្សសមរង្ស៊ី១រូបដែលចូលរួមក្នុងសកម្មភាពតវ៉ាទំនាស់ដីធ្លី។

ដោយឡែកនៅសង្កាត់បាទី ក្រុងបាវិត ខេត្តស្វាយរៀងឯណោះវិញ មានសេចក្តីរាយការណ៍ថាមានករណីគំរាមដល់អាយុជីវិតមកលើលោក **មាស សាផល** ដែលមានតួនាទីជាប្រធានគណៈកម្មាធិការប្រតិបត្តិសង្កាត់បាទី នៃគណបក្សសិទ្ធិមនុស្ស ពីសំណាក់លោក **ព្រំ រុទ្ធី** ជំនួយការភូមិថ្នល់កែង សង្កាត់បាទី មកពីគណបក្សប្រជាជនកម្ពុជា។ ជុំវិញករណីនេះបើទោះជាមានការសំរុះសំរួល និងរកឃើញថាវាគ្រាន់តែជម្លោះពាក្យសម្តីនៅកន្លែងស៊ីផឹកក៏ដោយ ប៉ុន្តែវាបានធ្វើឲ្យប៉ះពាល់ដល់បរិយាកាសនយោបាយក្នុងដំណាក់កាលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នេះផងដែរ។

***<u>ដំណើរការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង៖</u>***

បញ្ជីបោះឆ្នោតដំបូងគឺបានមកពីបញ្ជីបោះឆ្នោតចុងក្រោយដែលបានធ្វើបច្ចុប្បន្នភាព និងផ្ទៀងផ្ទាត់រួច បូកនឹងបញ្ជីបោះឆ្នោតបន្ថែមដែលបានផ្ទៀងផ្ទាត់រួច។ ហើយបញ្ជីនេះនឹងក្លាយជាបញ្ជីបោះឆ្នោតផ្លូវការសម្រាប់ការបោះឆ្នោតឆ្នាំ២០១២ ក្នុងករណីគ្មានបណ្តឹងជំទាស់ ឬបណ្តឹងតវ៉ាលើបញ្ជីនេះ។ បើតាមប្រតិទិនរបស់ គ.ជ.ប បញ្ជីនេះបិទផ្សាយនៅថ្ងៃទី១៩ តុលា (ករណីគ្មានបណ្តឹង) ឬបិទផ្សាយនៅថ្ងៃទី២១ វិច្ឆិកា (ករណីមានបណ្តឹង) ហើយប្រជាពលរដ្ឋ និងគណបក្សនយោបាយអាចធ្វើការប្តឹងតវ៉ា ឬប្តឹងជំទាស់លើបញ្ជីបោះឆ្នោតដំបូងទៅក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីថ្ងៃបិទបញ្ជីនេះ។ ការបិទផ្សាយបញ្ជីនេះគឺសម្រាប់ឲ្យប្រជាពលរដ្ឋទៅផ្ទៀងផ្ទាត់ឈ្មោះចុងក្រោយ និងធ្វើការប្តឹងតវ៉ា ឬជំទាស់លើបញ្ជីនេះ។

ជុំវិញការបិទផ្សាយបញ្ជីនេះបើតាមការសង្កេតរបស់អ្នកសង្កេតការណ៍ខុមហ្វ្រែលបានរកឃើញថា មិនសូវមានប្រជាពលរដ្ឋទៅពិនិត្យបញ្ជីនេះទេ។ គិតជាមធ្យមចំពោះឃុំ/សង្កាត់ដែលខុមហ្វ្រែលធ្វើការសង្កេតមានប្រជាពលរដ្ឋ ប្រមាណតែ ៣១% ប៉ុណ្ណោះនៃប្រជាពលរដ្ឋដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតដំបូងបានទៅពិនិត្យឈ្មោះរបស់ខ្លួន។

ឃុំ/សង្កាត់ដែលប្រជាពលរដ្ឋទៅពិនិត្យតិចជាងគេរួមមាន សង្កាត់កំពង់កណ្តាល សង្កាត់ក្រាំងអំពិល សង្កាត់កំពង់បាយ ក្រុងកំពត ខេត្តកំពត, សង្កាត់កែប និងសង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប, ឃុំព្រែកកណ្តៀង ស្រុកពាមរក៍ ខេត្តព្រៃវែង, សង្កាត់រការក្រៅ សង្កាត់រកាក្នុង និងបារាយណ៍ ក្រុងដូនកែវ ខេត្តតាកែវ, សង្កាត់វាលវង្ស សង្កាត់កំពង់ចាម និងសង្កាត់សំបួរមាស ក្រុងកំពង់ចាម ខេត្តកំពង់ចាម, សង្កាត់កំពង់រទេះ និងសង្កាត់អាចារ្យលាក់ ក្រុងកំពង់ធំ ខេត្តកំពង់ធំ, សង្កាត់តាក្តុល និងសង្កាត់ព្រែហូរ ក្រុងតាខ្មៅ ខេត្តកណ្តាល, និងសង្កាត់កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង។

មូលហេតុចំបងៗ ដែលបណ្តាលឲ្យប្រជាពលរដ្ឋទៅពិនិត្យបញ្ជីឈ្មោះបោះឆ្នោត មានចំនួនតិច រួមមាន ខ្វះព័ត៌មានអំពីការបិទផ្សាយ មិនបានយល់ដឹងពីគោលបំណង និងសារៈសំខាន់ក្នុងការទៅពិនិត្យបញ្ជីនេះ ពិបាកធ្វើដំណើរដោយសារបញ្ហាទឹកជំនន់ គិតថាខ្លួនមានឈ្មោះហើយ(មិនចាំបាច់ទៅមើលក៏មិនអីដែរ) ជាប់រវល់ក្នុងការប្រកបរបរចិញ្ចឹមជីវិត និងមិនចាប់អារម្មណ៍។ ជាមួយគ្នានេះដែរបើតាមការសង្កេត និងសាកសួរប្រជាពលរដ្ឋដែលបានទៅពិនិត្យឈ្មោះបានរកឃើញថា មិនសូវមានបញ្ហាខុសឈ្មោះ ឬទិន្នន័យផ្សេងៗច្រើនទេ ប៉ុន្តែប្រជាពលរដ្ឋមួយចំនួនបានជួបការលំបាកក្នុងការស្វែងរកការិយាល័យបោះឆ្នោតរបស់ពួកគេ ក៏ព្រោះតែមានការកើនឡើងនូវចំនួនការិយាល័យបោះឆ្នោត។

ខុមហ្វ្រែល មានការព្រួយបារម្ភថា ការដែលប្រជាពលរដ្ឋភាគច្រើន មិនបានទៅពិនិត្យឈ្មោះរបស់ខ្លួនក្នុងបញ្ជីបោះឆ្នោតដំបូង ពួកគេអាចជួបបញ្ហានៅថ្ងៃបោះឆ្នោតខាងមុខ ដូចជាករណីបាត់ឈ្មោះ ខុសឈ្មោះ ឬខុសទិន្នន័យ និងរកការិយាល័យបោះឆ្នោតមិនឃើញជាដើម។

***<u>ដំណើរការដោះស្រាយបណ្តឹង៖</u>***

ក្នុងកំឡុងពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត និងបិទបញ្ជីឈ្មោះបោះឆ្នោតដំបូងនេះ ខុមហ្វ្រែលបានសង្កេតបណ្តឹងយ៉ាងតិចចំនួន ០៥ករណី ដែលបណ្តឹងទាំងនោះប្តឹងដោយគណបក្សសមរង្ស៊ី និងគណបក្សប្រជាជនកម្ពុជា។ បណ្តឹងទាំងនោះរួមមាននៅរាជធានីភ្នំពេញ និងខេត្តកណ្តាល។ ការសង្កេតឃើញថាបណ្តឹងទាំង០៥នោះ សុទ្ធតែធ្វើឡើងដោយតំណាងគណបក្សនយោបាយ។ នៅក្នុងដំណាក់កាលនេះដែរយើងសង្កេតឃើញថា ប្រជាពលរដ្ឋសាមញ្ញមិនបានលើក

ទឹកចិត្តឲ្យបានទូលំទូលាយ ក្នុងការធ្វើបណ្តឹងដោយខ្លួនឯងឡើយ។ នីតិវិធីបណ្តឹងមានភាពស្មុគ្រស្មាញ រយៈពេលខ្លី ព្រមគ្នានេះប្រជាពលរដ្ឋលោកយល់ថា ការបន្តបណ្តឹងវាខាតបង់ពេលរកទទួលទាន និងប្រាក់កាសច្រើនក្នុងការធ្វើបណ្តឹងបន្តមក គ.ជ.ប រហូតមានករណីខ្លះត្រូវបានប្រជាពលរដ្ឋបោះបង់ចោលឈប់ប្តឹងផ្តល់តែម្តង។

ដោយឡែករបាយការណ៍ដែលទទួលបានពី គ.ជ.ប ក្នុងដំណាក់កាលចុះឈ្មោះបោះឆ្នោត កបឃ/ស មានចំនួន ១២ បណ្តឹង (មានការកើនឡើង ៧១% បើធៀបទៅនឹងបណ្តឹងឆ្នាំ២០០៧ មាន៧បណ្តឹង) ក្នុងនោះ យល់ព្រមចំនួន ០៥ បណ្តឹង បដិសេធចំនួន ០៤បណ្តឹង ធ្វើការផ្សះផ្សាសះជាចំនួន ០១បណ្តឹង ធ្វើការផ្សះផ្សាយមិនសះជាចំនួន ០១បណ្តឹង និងដកពាក្យបណ្តឹងវិញចំនួន ០១បណ្តឹង។ គ.ជ.ប មានចំនួន ១០ បណ្តឹង (មានការថយចុះ ៨០% បើធៀបទៅនឹងបណ្តឹងឆ្នាំ២០០៧ មានរហូតដល់ ៥២បណ្តឹង) ក្នុងនោះយល់ព្រមចំនួន ០៣បណ្តឹង បដិសេធចំនួន ០៥បណ្តឹង និងដកពាក្យបណ្តឹងវិញចំនួន ០២ បណ្តឹង។ ក្នុងដំណាក់កាលនេះមានបណ្តឹងចំនួន២ បានប្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងនោះ បដិសេធទាំង២បណ្តឹង។ ពាក្យបណ្តឹងទាំងនេះត្រូវបានប្តឹងដោយគណបក្សសមរង្ស៊ីចំនួន១៨បណ្តឹង និងប្រជាពលរដ្ឋចំនួន ០២ បណ្តឹង។

ក្នុងដំណាក់កាលបិទផ្សាយបញ្ជីបោះឆ្នោតដំបូងវិញ កបឃ/ស មានចំនួន ៤១បណ្តឹង (មានការថយចុះ ៩៤% បើធៀបទៅនឹងបណ្តឹងឆ្នាំ២០០៧ មានរហូតដល់ ៧៥៩បណ្តឹង) ក្នុងនោះ បដិសេធចំនួន ២០បណ្តឹង យល់ព្រមចំនួន ០៥ បណ្តឹង យល់ព្រមមួយផ្នែក និងបដិសេធមួយផ្នែកលើពាក្យបណ្តឹងចំនួន ១៥បណ្តឹង និងដកពាក្យបណ្តឹងចំនួន០១បណ្តឹង។ គ.ជ.ប មានចំនួន ៣២បណ្តឹង (មានការកើនឡើង ៤៣៣% បើធៀបទៅនឹងបណ្តឹងឆ្នាំ២០០៧ មានតែ០៦បណ្តឹង) ក្នុងនោះយល់ព្រមចំនួន ០១បណ្តឹង បដិសេធចំនួន ១៥បណ្តឹង យល់ព្រមមួយផ្នែក និងបដិសេធមួយផ្នែកលើពាក្យបណ្តឹងចំនួន ១៦បណ្តឹង។ ក្នុងដំណាក់កាលនេះមានបណ្តឹងចំនួន២ បានប្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងនោះបដិសេធ ១បណ្តឹង និងបើកសវនាការដោះស្រាយ ដោយបដិសេធលើពាក្យបណ្តឹងចំនួន១បណ្តឹង។ ពាក្យបណ្តឹងទាំងនេះត្រូវបានប្តឹងដោយគណបក្សសមរង្ស៊ីចំនួន៣៧បណ្តឹង គណបក្សប្រជាជនកម្ពុជាចំនួន ០១បណ្តឹង និងប្រជាពលរដ្ឋចំនួន០៣បណ្តឹង។

កម្មវត្ថុនៃបណ្តឹងក្នុងដំណាក់កាលចុះឈ្មោះបោះឆ្នោតទាំងនោះ ភាគច្រើនគឺប្តឹងពីបទចុះឈ្មោះឲ្យជនជាតិវៀតណាម ប្តឹងមន្ត្រីចុះឈ្មោះអនុវត្តផ្ទុយពីនីតិវិធី និងសេចក្តីណែនាំរបស់ គ.ជ.ប ប្តឹងតវ៉ាសុំចុះឈ្មោះ ប្តឹងជំទាស់សុំលុបឈ្មោះអ្នកបោះឆ្នោត ប្តឹងសុំរក្សាឈ្មោះអ្នកបោះឆ្នោត ប្តឹងពីបទលុបឈ្មោះដោយពុំមានប្រជុំអនុម័តរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់ និងពុំមានឯកសារគតិយុត្ត និងប្តឹងជំទាស់សេចក្តីសម្រេចរបស់ កបឃ/ស។

ជុំវិញបណ្តឹងនេះដែរ អ្វីដែលគួរចាប់អារម្មណ៍នោះ គឺបណ្តឹងសុំលុបឈ្មោះអ្នកបោះឆ្នោតចំនួន ៥៨នាក់ នៅឃុំកំពង់ហ្លួង ស្រុកពញាឮ ខេត្តកណ្តាល របស់គណបក្សសមរង្ស៊ី ដែលបន្ទាប់ពីការចុះស្រាវជ្រាវនិងការបើកសវនការ គ.ជ.បបានសម្រេចរក្សាឈ្មោះ ៣៩នាក់ និងលុបឈ្មោះ ១៩នាក់ ដោយសារ ៤នាក់ស្លាប់ និង១៥នាក់បានផ្លាស់ទីលំនៅ។ លើករណីនេះបើសិនជាគ្មានបណ្តឹងរបស់គណបក្សសមរង្ស៊ីទេ មានន័យថាឈ្មោះទាំង១៩នាក់នេះនឹងបន្តនៅមានវត្តមានក្នុងបញ្ជីឈ្មោះបោះឆ្នោត ហើយសួរថាតើការធ្វើបច្ចុប្បន្នភាពរបស់មន្ត្រីចុះឈ្មោះក្នុងឃុំនេះយ៉ាងណា បានជារកមិនឃើញករណីនេះទាល់តែមន្ត្រីពី គ.ជ.ប ចុះទៅធ្វើការស្រាវជ្រាវ។

ជាមួយគ្នានេះរាល់បណ្តឹងភាគច្រើន មិនត្រូវបានអាជ្ញាធររៀបចំការបោះឆ្នោតលើកយកមកធ្វើការដោះស្រាយឡើយ នេះជាចំណុចមួយបញ្ជាក់ឲ្យឃើញពីភាពមិនទទួលខុសត្រូវរបស់អាជ្ញាធរទាំងនេះក្នុងយន្តការបោះឆ្នោត ដែលសមត្ថកិច្ចនេះមានចែងក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា។ ជាក់ស្តែងបណ្តឹងចំនួន ២ របស់គណបក្សសមរង្ស៊ី ទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងដំណាក់កាលចុះឈ្មោះ ត្រូវបានស្ថាប័ននេះធ្វើការបដិសេធដោយលើកហេតុផលមិនចូលក្នុងសមត្ថកិច្ចរបស់ខ្លួន ប៉ុន្តែបណ្តឹងទាំងពីរនេះ គ.ជ.បទទួលបើកសវនាការមុនប្តឹងបន្តទៅក្រុមប្រឹក្សាធម្មនុញ្ញ។

ការយោគយល់សម្រុះសម្រួលគ្រប់រូបភាពចំពោះទង្វើខុសច្បាប់ណាមួយនោះ វាមិនមែនជាដំណោះស្រាយដ៏ត្រឹមត្រូវទាំងគូភាគី និងអង្គការមានសមត្ថកិច្ចរៀបចំការបោះឆ្នោតនោះទេ។ យើងព្រួយបារម្ភថា ការសម្របសម្រួលដោយមិនចាត់

វិធានការផ្លូវច្បាប់បែបនេះ វានឹងក្លាយទៅជាយុទ្ធសាស្ត្រដ៏អាក្រក់មួយក្នុងយន្តការបោះឆ្នោតនៅកម្ពុជា។ ជាក់ស្តែងនោះគឺអាជ្ញាធរមូលដ្ឋានមួយចំនួនមិនប្រតិបត្តិទៅតាមការណែនាំរបស់ គ.ជ.ប ដាក់ចេញនោះទេ រីឯគ.ជ.ប ខ្លួនឯងវិញមិនបានធានាឲ្យប្រាកដថារាល់បញ្ញត្តិដែលខ្លួនបានដាក់ចេញនោះត្រូវបានសមត្ថកិច្ចក្រោមបង្គាប់ (ឃុំ/សង្កាត់) គោរពប្រតិបត្តិឲ្យបានត្រឹមត្រូវនោះទេ។ គ.ជ.ប បានគេចវេសពីការទទួលខុសត្រូវ លើការមិនគោរពតាមបទបញ្ញត្តិទាំងនោះ ឧទាហរណ៍ក្នុងករណីលុបឈ្មោះអ្នកបោះឆ្នោត ដែលតម្រូវឲ្យមានឯកសារគតិយុត្តិ។ តែយើងសង្កេតឃើញថា អាជ្ញាធរមូលដ្ឋានមួយចំនួនមិនបានគោរពតាមការណែនាំនេះទេ។ ជាមួយគ្នានេះដែរបណ្តឹងទាក់ទងនឹងការចុះឈ្មោះឲ្យជនជាតិវៀតណាមបានកើតឡើងរាល់ពេលបោះឆ្នោត ហើយត្រូវបានបដិសេធដោយ គ.ជ.ប ក្រោមហេតុផលថា ពួកគេមានឯកសារគ្រប់គ្រាន់សម្រាប់ការចុះឈ្មោះបោះឆ្នោត ក៏ប៉ុន្តែ គ.ជ.ប មិនបានអង្កេតមើលពីភាពពិតប្រាកដនៃលិខិតស្នាមនោះទេនៅពេលមានពាក្យបណ្តឹង ប៉ុន្តែតែងតែលើកដាក់ទៅស្ថាប័នផ្សេងទៀតដូចជា តុលាការ។ បញ្ហាទាំងនេះគឺជាសញ្ញាអវិជ្ជមានមួយ ដែលគួរឲ្យព្រួយបារម្ភទៅលើការធានានូវភាពសេរី និងយុត្តិធម៌ក្នុងការបោះឆ្នោតខាងមុខ។

***<u>កិច្ចសវនាការ៖</u>***

ពិនិត្យជារួម កិច្ចសវនាការរបស់ គ.ជ.ប ឃើញថាមានលក្ខណៈជាសាធារណៈ ដោយមានការអញ្ជើញសាធារណជន ក៏ដូចជាអង្គការមានបេសកកម្មឃ្លាំមើលយន្តការបោះឆ្នោត បានចូលរួមសង្កេតការណ៍យ៉ាងទូលំទូលាយ។

ប៉ុន្តែអ្វីដែលគួរចាប់អារម្មណ៍នោះគឺ ដំណើរការសួរដេញដោលពុំបានអនុញ្ញាតឲ្យភាគីបង្ហាញសមាសភាពពាក់ព័ន្ធមកចូលរួមក្នុងអង្គសវនាការឡើយ ដូចជាការចោទប្រកាន់ថាឈ្មោះក្នុងបញ្ជីបោះឆ្នោតជាជនបរទេស តែចុងចម្លើយអះអាងថា អ្នកទាំងនោះជាជនជាតិខ្មែរ។ ករណីនេះក្រុមប្រឹក្សាជំនុំជំរុះ គួរបង្គាប់ឲ្យចុងចម្លើយបង្ហាញភស្តុតាងជាក់ស្តែង (យកមនុស្សពាក់ព័ន្ធ៥-៦នាក់) ជាជាងធ្វើឡើងតែមាត់ទទេទៅលើប្រវត្តិរបស់មនុស្សរាប់រយនាក់ដូច្នោះ។

គ.ជ.ប គួរយកវិធាន នីតិវិធីរបស់តុលាការ មកធ្វើជាគោលក្នុងការដោះស្រាយវិវាទ ព្រោះបញ្ហាទាំងនោះសុទ្ធតែបានបញ្ញត្តិក្នុងច្បាប់ស្តីពីការបោះឆ្នោតរួចស្រេចទៅហើយ។ ចំពោះការសួរដេញដោលរវាងសមាជិកក្រុមប្រឹក្សា និងភាគី យើងសង្កេតឃើញថា វាមានលក្ខណៈដូចជាការជជែកយកឈ្នះចាញ់តែរៀងៗខ្លួនទៅវិញ វាហាក់បីដូចជាមិនមែនជាការសួររកហេតុផលក្នុងអង្គហេតុដើម្បីការសម្រេចសេចក្តីមួយប្រកបដោយត្រឹមត្រូវ តម្លាភាព យុត្តិធ៌មឡើយ។

## ២. គោលបំណង និងវិធីសាស្ត្រនៃគំរោង

គំរោងនៃការស្រាវជ្រាវមានគោលបំណងជួយផ្តល់ព័ត៌មាន ដែលអាចធ្វើឲ្យប្រសើរឡើងនៅក្នុងដំណើរការចុះឈ្មោះ និងពិនិត្យបញ្ជីឈ្មោះបោះឆ្នោត ជាពិសេសទាក់ទងទៅនឹងការចូលរួមរបស់អ្នកបោះឆ្នោត សំរាប់ការបោះឆ្នោតនាពេលអនាគត ។

គោលបំណងនៃការស្រាវជ្រាវនេះគឺដើម្បីផ្តល់ឲ្យ គជប និងស្ថាប័នដែលពាក់ព័ន្ធនូវព័ត៌មាន និងអានុសាសន៍ដែលអាចធ្វើឲ្យប្រព័ន្ធចុះឈ្មោះបោះឆ្នោតបច្ចុប្បន្នមានភាពប្រសើរឡើង។ ហើយក៏សង្ឃឹមថាព័ត៌មានទាំងនេះនឹងធ្វើឲ្យកាន់តែមានភាពទុកចិត្តនៅក្នុងដំណើរការបោះឆ្នោត សំរាប់ស្ថាប័នដែលមានការពាក់ព័ន្ធ ។

## វិធីសាស្ត្រនៃគំរោង

ការិយាល័យសំណាក ៨៥០ ត្រូវបានកំណត់សំរាប់ធ្វើការសិក្សាស្រាវជ្រាវ ។ ការិយាល័យសំណាកនេះត្រូវបានយកចេញពីអ្នកមានសិទ្ធិបោះឆ្នោតចំនួន ៣៩៧,៤៣៧នាក់ ក្នុងចំណោមអ្នកមានសិទ្ធិបោះឆ្នោត ៨,៨៩៤,៧១៩នាក់ ។ ការិយាល័យសំណាក និងអ្នកបោះឆ្នោតត្រូវបានជ្រើសរើសចេញពីខេត្តទាំង ២៣ និងរាជធានីភ្នំពេញ ។

អ្នកសម្ភាសន៍ដែលមានអាយុក្រោម ៥៥ ឆ្នាំត្រូវបានជ្រើសរើសចេញពីបេក្ខជនដែលរស់នៅខេត្តដែលបានកំណត់ ហើយពួកគេមានបទពិសោធន៍ធ្វើកិច្ចសម្ភាសន៍ និងការស្រាវជ្រាវពីមុនមក មិនថាជាមួយ ខុមហ្វ្រែល ឬជាមួយ អង្គការដែលពាក់ព័ន្ធ ។ អ្នកសម្ភាសន៍នីមួយៗត្រូវបានផ្តល់រយៈពេល ២ ថ្ងៃសំរាប់វគ្គបណ្តុះបណ្តាលដែលរៀបចំដោយខុមហ្វ្រែល ។

ចំនួននៃអ្នកផ្តល់បទសម្ភាសន៍ ត្រូវបានជ្រើសរើសស្របនឹងគំរូនៅក្នុងភូមិនីមួយៗ ដែលត្រូវកំណត់ក្នុងចំណោម ៨៥០ ការិយាល័យសំណាក ដោយត្រូវបានកំណត់ចំនួនអ្នកចុះឈ្មោះបោះឆ្នោត តាមសមាមាត្រធៀបនឹងការិយាល័យនីមួយៗ និងវិធីសាស្ត្រចាប់ឆ្នោតដោយចៃដន្យ ត្រូវបានប្រើប្រាស់សំរាប់ជ្រើសរើសអ្នកផ្តល់បទសម្ភាសន៍ សំរាប់ធ្វើការសម្ភាសន៍ ។

ការសិក្សានេះបានធ្វើការសន្និដ្ឋានថា នៅក្នុងផ្ទះនីមួយៗមាន១គ្រួសារ ដូច្នេះដើម្បីជ្រើសរើសគ្រួសារសម្រាប់ធ្វើការសម្ភាសន៍ អ្នកសម្ភាសន៍របស់ខុមហ្វ្រែលបានធ្វើការជួបជាមួយប្រធានភូមិ សមាជិកជាន់ខ្ពស់ក្នុងភូមិជាមុន ដើម្បីបញ្ជាក់ពីចំនួនគ្រួសារ ផ្ទះ និងប្រជាជនរស់នៅក្នុងភូមិ ។ អ្នកសម្ភាសន៍បានធ្វើឆ្នោត ចំនួន ១០សន្លឹក ដែលមានពីលេខ ០១ ដល់លេខ១០ ដើម្បីជ្រើសរើសផ្ទះដែលត្រូវសម្ភាសន៍លើកទី១ ។ បន្ទាប់មក អ្នកសម្ភាសន៍នឹងចាប់ដោយចៃដន្យនូវឆ្នោតមួយសន្លឹកក្នុងចំណោមឆ្នោតទាំង១០នោះ ហើយធ្វើការសម្ភាសន៍ចាប់ពីទីតាំងផ្ទះដែលចាប់បាននេះ។ ផ្ទះដែលត្រូវសម្ភាសន៍បន្ទាប់មកទៀត ត្រូវជ្រើសរើសដោយប្រើវិធីសាស្ត្រដែលបានចែងនៅក្នុងឧបសម្ព័ន្ធ ១ ។

ដើម្បីជ្រើសរើសសមាជិកនៃផ្ទះនីមួយៗ សំរាប់ធ្វើការសម្ភាសន៍ អ្នកសម្ភាសន៍ត្រូវកំនត់ទៅតាមឋានានុក្រមអក្សរដែលមានព្យញ្ជនៈមុនគេ ហើយវិធីសាស្ត្រនេះប្រើសំរាប់អ្នកដែលមានសិទ្ធិបោះឆ្នោតតែប៉ុណ្ណោះ។ គ្រប់ទិន្នន័យដែលទទួលបាននឹងត្រូវត្រួតពិនិត្យដោយប្រធានក្រុមការងារចុះស្រាវជ្រាវនៅមូលដ្ឋាន ប្រធានក្រុមការងារនៅខេត្ត និងក្រុមវាយតម្លៃរបស់ខុមហ្វ្រែលស្នាក់ការកណ្តាលក្រុងភ្នំពេញ។ ប្រធានក្រុមការងារមូលដ្ឋានត្រូវធ្វើការត្រួតពិនិត្យផ្ទាល់ និងប្រមូលកម្រងសំនួរដែលបំពេញរួច និងធ្វើការពិនិត្យឲ្យមានសុក្រិត្យភាព។ ប្រធានក្រុមត្រូវណែនាំឲ្យអ្នកសម្ភាសន៍ធ្វើការសម្ភាសន៍ឡើងវិញ ប្រសិនបើរកឃើញនូវកំហុសឆ្គងផ្សេងៗ។ ប្រធានក្រុមការងារខេត្ត ត្រូវត្រួតពិនិត្យជាលើកចុងក្រោយទៅលើកម្រងសំនួរទាំងអស់ មុននឹងបញ្ជូនទៅឲ្យខុមហ្វ្រែលស្នាក់ការកណ្តាល។

អ្នកបញ្ចូលទិន្នន័យត្រូវបញ្ចូលឲ្យបានគ្រប់ជ្រុងជ្រោយទៅក្នុង Ms Access ក្នុងទម្រង់ដែលបានរៀបចំរួច។ ប្រធានក្រុមការងារខុមហ្វ្រែលស្នាក់ការកណ្តាលនឹងត្រូវធ្វើការត្រួតពិនិត្យប្រចាំថ្ងៃ ៥% នៃទិន្នន័យដែលបានបញ្ចូលហើយឲ្យបានត្រឹមត្រូវមុនពេលអនុវត្ត ប្រសិនបើកំហុសឆ្គងត្រូវបានរកឃើញ ។

នៅក្នុងការវិភាគទិន្នន័យ ខុមហ្វ្រែលក៏បានប្រើ Analyze Descriptive Frequency, Model Crosstab by layer, Model Chi-Square និង Long Linear ដើម្បីធ្វើការវិភាគពីបំរែបំរួល ទំនាក់ទំនង និងការលំបាក ថាតើចំនុចនីមួយៗអាស្រ័យគ្នាដែរឬទេ។ ( សូមមើលឧបសម្ព័ន្ធ ១ )

## ៣. លទ្ធផលនៃគំរោង

### លទ្ធផលទី ១

*ពីខែមិថុនា ដល់តុលា ២០១១ ក្រុមការងារខុមហ្វ្រែល និងអ្នកជំនាញខាងស្ថិតិ បានធ្វើការប្រជុំគ្នា ដើម្បីរៀបចំបង្កើតវិធីសាស្រ្ត និងដំណើរការនៃគំរោង។ ខុមហ្វ្រែល រួមជាមួយដៃគូ ដែលមាន NICFEC KYA និងPDP center បានធ្វើការពិភាក្សាជាមួយ គណបក្សហ្វ៊ុនស៊ីនប៉ិច គណបក្សនរោត្តមរណឫទ្ធិ គណបក្សសិទ្ធិមនុស្ស គណបក្សសមរង្ស៊ី ក្រសួងមហាផ្ទៃ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គជប) ដើម្បីរៀបចំកំរងសំនួរ និងសកម្មភាពចុះស្រាវជ្រាវ ។*

*គណបក្សនយោបាយទាំងនោះ រួមជាមួយអ្នកដែលចូលរួមដទៃទៀត បានផ្តល់នូវព៌តមានដែលគាំទ្រចំពោះ ការអង្កេត និងផ្តល់នូវទិន្នន័យសម្រាប់កម្រងសំនួរដែលបានរៀបចំឡើង។ ដៃគូដទៃទៀតរបស់ខុមហ្វ្រែល ក៏បានរៀបចំកិច្ច ប្រជុំជាច្រើន ដើម្បីធ្វើការពិភាក្សា និងទទួលបានទិន្នន័យពាក់ពន្ធ័ទៅនឹងការអភិវឌ្ឍន៍សៀវភៅបណ្តុះបណ្តាល ឧបករណ៍ កម្រងសំនួរ កម្មវិធីបណ្តុះបណ្តាល ការជ្រើសរើសអ្នកសង្កេតការណ៍ ការចាត់តាំងការងារ ដំណើរការត្រួតពិនិត្យ ផ្ទាល់ ការប្រមូលទិន្នន័យ ការសំអាតទិន្នន័យ ដំណើរការទិន្នន័យ ការវិភាគទិន្នន័យ ការរៀបចំ បទបង្ហាញ និងបញ្ហាពាក់ពន្ធ័ ដទៃទៀត ដើម្បីទទួលបានជោគជ័យនៅក្នុងគំរោងអង្កេតនេះ។*

### លទ្ធផលទី ២

*ក្នុងការស្រាវជ្រាវនេះ យើងមានអ្នកអង្កេតតាមមូលដ្ឋាន ២៣១នាក់ ដែលសុទ្ធតែត្រូវបានបណ្តុះបណ្តាល និង ចាត់តាំងអោយធ្វើកិច្ចសម្ភាសន៍ ១០០% ទៅលើអ្នកឆ្លើយដែលបានគ្រោងទុក ដែលសរុបមាន ៨៦៧២ នៃអ្នកបោះឆ្នោត នៅក្នុងការិយាល័យសំណាក ឬការិយាល័យបោះឆ្នោត។ ការិយាល័យសំណាក ឬការិយាល័យបោះឆ្នោតចំនួន ៨៥០ នៅក្នុង ២៤ ខេត្ត/ក្រុង ត្រូវបានជ្រើសរើសសំរាប់អ្នកអង្កេតធ្វើកិច្ចសម្ភាសន៍។*

ខុមហ្វ្រែល បានរៀបចំក្រុមគ្រូបង្គោល ដើម្បីរៀបចំវគ្គបណ្តុះបណ្តាលដែលមាន រយៈពេល ០២ថ្ងៃចំនួន ០៧ដង សម្រាប់អ្នកអង្កេតចំនួន ២៣១ នាក់ (អ្នកអង្កេតរយៈពេលវែងថ្នាក់ខេត្តចំនួន ៤៧ នាក់ និងអ្នកអង្កេតថ្នាក់ស្រុកចំនួន ១៩៤ នាក់)។ វគ្គបណ្តុះបណ្តាល រៀបចំឡើងនៅក្រុងភ្នំពេញ សៀមរាប ក្រុងព្រះសីហនុ ពោធិសាត់ បាត់ដំបង រតនៈគីរី និងកំពង់ចាម។ វគ្គបណ្តុះបណ្តាលនេះ ក៏ផ្តោតសំខាន់ទៅលើការត្រួតពិនិត្យនៃការចុះឈ្មោះរបស់អ្នកបោះឆ្នោត និងតារាងអ្នកបោះឆ្នោត ព្រមទាំងការអង្កេតទៅលើស្ថានភាពមុនពេលបោះឆ្នោត។

អ្នកអង្កេតចំនួន ២៣១ នាក់ ត្រូវបានចាត់តាំងអោយធ្វើការត្រួតពិនិត្យ និងអង្កេតទៅលើការិយាល័យសំណាក/ភូមិ ចំនួន ៨៥០ ជាមួយនឹងអ្នកដែលត្រូវសម្ភាសន៏ចំនួន ៨៦៧២ នៅក្នុងឃុំ ៦៤៤ ស្រុកចំនួន ១៨២ និង២៤ ខេត្ត/ក្រុង។ ការត្រួតពិនិត្យ និងអង្កេត គឺជាបណ្តុំនៃការសម្ភាសន៍ ជាលក្ខណៈប្រពន្ធ័ និងស្ថិតិ ការអង្កេត និងការសង្កេតទៅលើការចុះឈ្មោះអ្នកបោះឆ្នោត តារាងអ្នកបោះឆ្នោត (បញ្ជីបោះឆ្នោតដំបូង) និងស្ថានភាពមុនពេលបោះឆ្នោត។ តារាង ១ បង្ហាញពីចំនួនអ្នកផ្តល់បទសម្ភាសន៍តាមរយៈភេទ និង អាយុ។

**តារាង ១** ចំនួនអ្នកត្រូវផ្តល់បទសម្ភាសន៍តាមរយៈភេទ និង អាយុ

| | | |
|---|---|---|
| អ្នកផ្តល់បទសម្ភាសន៍ ៨៦៧២ នាក់ | ស្រី | ៦០,៥% |
| | ប្រុស | ៣៩,៥% |
| | យុវវ័យ(១៨-៣០) | ២៧,២% |

ដើម្បីជ្រើសរើសអ្នកសម្ភាសន៍នៅទីតាំងសំណាកនេះបានប្រើប្រាស់វិធីសាស្ត្រជាលក្ខណៈប្រព័ន្ធដោយ ១/កំណត់កម្រិតចន្លោះ ២/ជ្រើសរើសគ្រួសារ ៣/កំណត់អ្នកសម្ភាសន៍ នៅក្នុងផ្ទះនីមួយៗ។ បន្ទាប់ពីធ្វើការសម្ភាសន៍ អ្នកអង្កេតរយៈពេលវែង នឹងអង្កេតទៅលើស្ថានភាពមុនពេលបោះឆ្នោតរួមមានអំពើហិង្សា ការគំរាមកំហែងឬបង្ខិតបង្ខំ និងការរំលោភទៅលើ សិទ្ធិនិងសេរីភាពនយោបាយ និងការខុងឆ្គងនូវការប្រើប្រាស់ធនធានរដ្ឋ។

អ្នកអង្កេតរយៈពេលវែង និងក្រុមការងារ បានធ្វើការសង្កេតទៅលើករណីធំៗជាច្រើនដូចជា អង្កេតទៅលើពាក្យបណ្តឹង ត្រូវបានលើកឡើងដោយមន្ត្រីរៀបចំការបោះឆ្នោត និងរៀបចំនូវលិខិតតំណាងផ្សេងៗក្នុងករណីចាំបាច់។ ប្រធានក្រុមក៏ត្រូវបានចាត់តាំងនូវការងារបន្ថែមដោយត្រួតពិនិត្យ និងសង្កេតទៅលើទិន្នន័យទទួលបាន ។ ក្រុមការងាររបស់ខុមហ្វ្រែល និងអ្នកអង្កេតរយៈពេលវែងបានជួបជាមួយក្រុមត្រួតពិនិត្យផ្ទាល់ និងជួយមេដឹកនាំនៃក្រុមអ្នកអង្កេតក្នុងពេលធ្វើកិច្ចសម្ភាសន៍។

**លទ្ធផលទី ៣**

*របាយការណ៍ចុងក្រោយ រួមបញ្ចូលជាមួយការរកឃើញ និងអានុសាសន៍នឹងត្រូវបានផលិត ព្រមទាំងផ្ញើរជូនសមាជិកសភា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គជប) និងអ្នកដែលពាក់ព័ន្ធនឹងការបោះឆ្នោត ដូចជា គណបក្សនយោបាយ ម្ចាស់ជំនួយ និងប្រព័ន្ធផ្សព្វផ្សាយនានា (វិទ្យុ និងកាសែត) និងតាមរយៈវេបសាយ ។*

នៅខែធ្នូ ២០១១ ដល់ ខែមករា ២០១២ ទិន្នន័យបានបញ្ចូលដោយក្រុមការងារបញ្ចូលទិន្នន័យ ។ អ្នកស្ម័គ្រចិត្ត ១៥នាក់ បានធ្វើការបញ្ចូលទិន្នន័យទាំងអស់ទៅក្នុងប្រព័ន្ធកុំព្យូទ័រ។ អ្នកបច្ចេកទេស និងមន្ត្រីស្រាវជ្រាវខុមហ្វ្រែល ក្រុមការងារស្រាវជ្រាវ និងអ្នកជំនាញបានជួបគ្នា ដើម្បីវិភាគទិន្នន័យដែលទទួលបាន និងផលិតការរកឃើញ។ សេចក្តីព្រាងលទ្ធផលរកឃើញ ត្រូវបានធ្វើឡើងនូវពាក់កណ្តាល ខែកុម្ភៈ២០១២ ។ ហើយនៅថ្ងៃទី ២៨ ខែកុម្ភៈ ២០១២ ខុមហ្វ្រែលបានរៀបចំកិច្ចពិភាក្សាតុមូល ដើម្បីពិភាក្សាស្តីពីលទ្ធផលសង្កេតស្រាវជ្រាវ ដែលទាក់ទងទៅនឹងការចុះឈ្មោះបោះឆ្នោត និងបរិយាកាសមុនការបោះឆ្នោត ។ កិច្ចពិភាក្សានេះគឺដើម្បីប្រមូលព័ត៌មាន និងអានុសាសន៍ដែលទាក់ទងរបាយការណ៍សង្កេតស្រាវជ្រាវនេះ ជាពិសេស គឺការចាប់អារម្មណ៍ពីសំណាក់ស្ថាប័នពាក់ព័ន្ធនានាដូចជា អ្នកកាសែត គណបក្សនយោបាយ និងស្ថាប័នពាក់ព័ន្ធដទៃទៀត ។ អ្នកចូលរួមមកពីអង្គការសង្គមស៊ីវិល និងគណបក្សនយោបាយសំខាន់ៗមួយចំនួនបានយល់ព្រមទៅលើអានុសាសន៍ដែលខុមហ្វ្រែលបានលើកឡើង ប៉ុន្តែលើកលែងគណបក្សប្រជាជនកម្ពុជា និងគជប មិនយល់ព្រមទៅនឹងការរកឃើញ និងបានផ្តល់យោបល់ទៅនឹងអ្វីដែលបានរកឃើញ (សូមមើលឧបសម្ព័ន្ធទី ៣ សំរង់ឯកសារផ្សេងៗ)។

## ៤. ចំណុចខ្វះខាត និងការដកពិសោធន៍មេរៀនពីការងារអង្កេត

- ភូមិដែលត្រូវសំភាសន៍មួយចំនួនតូចត្រូវបានផ្លាស់ប្តូរមកភូមិដែលនូវក្បែរនោះ ហើយក្នុងឃុំតែមួយ ដូចជា ភូមិនៅក្នុងខេត្ត បាត់ដំបង ពោធិ៍សាត់ ព្រះវិហារ បន្ទាយមានជ័យ ភ្នំពេញ ដោយសារតែទឹកជំនន់ មិនមានមធ្យោបាយណាមួយដែលអាចធ្វើដំណើរទៅបាន។ សំរាប់ពេលវេលាសំភាសន៍មានការពន្យារពេល ដោយសារតែមានទឹកជំនន់ដែលធ្វើឲ្យអ្នកសំភាសន៍ ពិបាកក្នុងមធ្យោបាយធ្វើដំណើរ ផ្លូវដាច់ត្រូវជួលទូកឆ្លង និងកន្លែងខ្លះចាំបាច់ត្រូវជួលទូកចុះសំភាសន៍តាមផ្ទះ។ ក្នុងការដោះស្រាយករណីនេះ ខុមហ្វ្រែលបានពន្យារពេលរហូតដល់ទឹកស្រក រួចទើបឲ្យអ្នកសង្កេតការណ៍ ចុះទៅសំភាសន៍។
- ពិបាកក្នុងការស្វែងរកប្រជាពលរដ្ឋមកសំភាសន៍ ដោយសារតែខែធ្វើស្រែឬចំការ ហើយស្រែនៅឆ្ងាយពីភូមិ តម្រូវអោយអ្នកសង្កេតការណ៍ត្រូវចុះសំភាសន៍ដល់វាលស្រែ ឬចំការទៀតក្នុងការជួបគាត់។ ម្យ៉ាងទៀតប្រជាពលរដ្ឋខ្លះក៏

បានធ្វើចំណាកស្រុក ទៅធ្វើការនៅក្រៅភូមិមានរយៈពេលយូរថ្ងៃផង។ អ្នកសង្កេតការណ៍ត្រូវសម្ភាសន៍សមាជិកផ្សេង ក្នុងគ្រួសារនោះជំនួសវិញ។

- បើទោះបីក្នុងកំឡុងពេលចុះឈ្មោះបោះឆ្នោត អ្នកសង្កេតការណ៍ខុមហ្វ្រែលបានទទួលកាតសង្កេតការណ៍ ពី គ.ជ.ប ដើម្បីបានសិទ្ធិក្នុងការងារសង្កេតការណ៍ ទាក់ទងការចុះឈ្មោះអ្នកបោះឆ្នោត និងការធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះអ្នកបោះឆ្នោតក៏ដោយ អ្នកសង្កេតការណ៍របស់ខុមហ្វ្រែលត្រូវបានរារាំង ដោយអាជ្ញាធរមិនឲ្យចុះសំភាសន៍ ដូចជា
    - o ខេត្តស្វាយរៀង ត្រូវបានមេភូមិ ចៅសង្កាត់ អភិបាលក្រុងមិនអនុញ្ញាតឲ្យចុះសំភាសន៍ ក្នុងនោះមានជំទប់រងសង្កាត់បាវិត (លោក ខឹម ឈាន) ផង "គាត់បានប្រាប់អ្នកសំភាសន៍ថាៈ ប្រយ័ត្នប៉ូលីសមកចាប់បើហ៊ានសំភាសន៍"។ ក្នុងករណីនេះ អ្នកសំភាសន៍ (ទំនាក់ទំនងស្រុក និងលេខាខុមហ្វ្រែល) មិនបានតវ៉ាអ្វីទេ ប៉ុន្តែគាត់ព្យាយាមសួរហូតចប់។
    - o ករណីខេត្ត រតនគិរី មេប៉ុស្ត និងប្រធានក្រុមប្រឹក្សាឃុំ កាឡែងចុះមកហាមឃាត់មិនឲ្យចុះសំភាសន៍ ទោះបីមានការជួយអន្តរាគមន៍ពីលេខាខុមហ្វ្រែលរតនគិរី និងក្រុមការងារស្នាក់ការកណ្តាលក៏ដោយ។ ក្រោយមកមានការធ្វើបទសំភាសន៍តាមវិទ្យុអាស៊ីសេរីដោយមានការឆ្លើយបំភ្លឺពីលោក ស្វីន វេវ ក្រុមការងារខុមហ្វ្រែលបានព្យាយាមចុះសំភាសន៍ម្តងទៀត ពេលនោះមិនមានការរារាំង ឬហាមឃាត់ទៀតទេ។
- នៅក្នុងស្រុកកែវសីម៉ា ខេត្តមណ្ឌលគិរី មានភូមិមួយជាកន្លែងប្រមូលផ្តុំដោយសហគមន៍ ដែលមានប្រធានសហគមន៍រារាំង ដោយប្រាប់ប្រជាពលរដ្ឋមិនឲ្យជួបសំភាសន៍ ខណៈនោះអ្នកសំភាសន៍មិនអាចជួបជាមួយប្រជាពលរដ្ឋបានដោយទទួលនូវការបដិសេធន៍មិនផ្តល់បទសំភាសន៍ ទោះបីមានការពន្យល់ ឬណែនាំយ៉ាងណាក៏ដោយអំពីហេតុផលនៃការសំភាសន៍ក៏ដោយ សូម្បីតែអាជ្ញាធរក៏មិនហ៊ានជំទាស់ដែរ។ ករណីនេះធ្វើឲ្យមានការពន្យាពេល ហើយខុមហ្វ្រែលបានរៀបចំលេខាខេត្តចុះជាប់ជាមួយប្រធានសហគមន៍ ហើយពន្យល់ពីមូលហេតុនៃការសំភាសន៍ រួចក៏នាំអ្នកសង្កេតការណ៍របស់ខុមហ្វ្រែលមានសកម្មភាពចុះសំភាសន៍រហូតចប់។
- នៅកន្លែងមួយចំនួន ដោយសារតែថវិកាគ្រោងទុក ទាបជាងចំណាយជាក់ស្តែង ដូចជាមធ្យោបាយធ្វើដំណើរ ថវិកាហូបចុក ជាពិសេសនៅតំបន់ខេត្តជាយដែន ដូចជា រតនគិរី មណ្ឌលគិរី បន្ទាយមានជ័យ ស្ទឹងត្រែង ព្រះវិហារ ឧត្តរមានជ័យ...គឺមានតំលៃខ្ពស់។ ក្នុងករណីទាំងនេះ ខុមហ្វ្រែលខិតខំដោះស្រាយថវិកាដោយឡែកពីគោលការណ៍ និងថវិកាគ្រោងទុក ដើម្បីបំពេញការងារសង្កេតការណ៍គ្រប់តាមផែនការ។
- នៅក្នុងកំឡុងពេលចុះសំភាសន៍ ក្រុមការងារចុះត្រួតពិនិត្យ បានពិនិត្យរកឃើញនូវបញ្ហាមួយចំនួន ដែលអ្នកសំភាសន៍ មិនគោរពតាមការណែនាំ ដូចជា វិធីសាស្ត្រក្នុងការជ្រើសរើសមនុស្ស ការបំពេញសំណួរ ដែលកើតឡើងក្នុងខេត្តចំនួន ២គឺ ខេត្តបន្ទាយមានជ័យ និងរតនគិរី។ ករណីទាំងនេះ ខុមហ្វ្រែលបានជ្រើសរើសអ្នកសំភាសន៍ថ្មីចុះទៅសំភាសន៍ឡើងវិញ។
    - o ករណីបន្ទាយមានជ័យ អ្នកសំភាសន៍នៅក្នុងស្រុក ភ្នំស្រុក ឃុំស្វាយចេក ត្រូវធ្វើការសំភាសន៍ប្រជាពលរដ្ឋ ៦៩ទំរង់ឡើងវិញ។ ក្រោយការត្រួតពិនិត្យលើទំរង់ ខុមហ្វ្រែលរកឃើញថាអ្នកសង្កេតការណ៍សំភាសន៍លឿន (ជាធម្មតាអ្នកជំនាញត្រូវការរយៈពេលកន្លះម៉ោង) តែសំរាប់គាត់ត្រូវការតែរយៈពេលពី១០ ទៅ ១៥នាទីទេ។ម្យ៉ាងទៀតទំរង់សំណួរនិមួយៗ មានព័ត៌មានប្រហាក់ប្រហែលគ្នា។ ករណីទាំងនេះក្រុម

ការងារខុមហ្វ្រែល បានចុះដល់ទីតាំង ហើយស្វែងរកឈ្មោះអ្នកត្រូវសំភាសន៍មកសំភាសន៍ជាថ្មី និងសាកសួរព័ត៌មានមួយចំនួនពីអ្នកមកសំភាសន៍មុន បន្ទាប់មកប្រៀបធៀបចំលើយក្នុងទំរង់ ក៏ធ្វើការសន្និដ្ឋានឃើញថា ចំលើយមាននៅលើទំរង់មានបញ្ហា។

- o ករណីរតនគិរី អ្នកសំភាសន៍នៅស្រុកកូនមុំ ខ្វះសមត្ថភាពក្នុងការសំភាសន៍ ដោយបំពេញទំរង់មិនត្រឹមត្រូវ (ទោះបីមានការបញ្ជូនទំរង់ឲ្យធ្វើឡើងវហូតដល់ពីរដង) និងថែមទាំងបានបញ្ជូនទំរង់ឲ្យអ្នកដទៃបំពេញដោយមិនមានការសំភាសន៍ដោយផ្ទាល់ផង។ ករណីនេះ ខុមហ្វ្រែលបានបញ្ឈប់ការងាររបស់អ្នកសង្កេតការណ៍ ប៉ុន្តែបានឲ្យលេខាខេត្ត និងក្រុមការងារស្នាក់ការកណ្តាល ចុះសំភាសន៍ដោយផ្ទាល់ឡើងវិញ។

- នៅខេត្តមណ្ឌលគិរី មានអ្នកសង្កេតការណ៍ក្នុងស្រុកកែវសីមា ចំនួន ៤នាក់ ក្នុងនោះ ២នាក់ មិនធ្វើការងារ និង ២នាក់ទៀត បានបោះបង់ចោលការងារទៅធ្វើការជាមួយអង្គការផ្សេង បន្ទាប់ពីអ្នកទាំង ៤នាក់ បានឆ្លងកាត់វគ្គបណ្តុះបណ្តាលរួចហើយ ដោយមិនមានការបញ្ជាក់ពីដំណឹងជាមុន។ ទោះបីជាក្រុមការងារបានទំនាក់ទំនងជាប់រហូតក៏ដោយ ដល់ពេលបញ្ចប់នៃការប្រមូលទំរង់ ទើបពួកគេប្រាប់ថាសុំឈប់។ ករណីនេះខុមហ្វ្រែលបានស្នើឲ្យលេខាខេត្ត និងអ្នកសង្កេតការណ៍មួយចំនួនផ្សេងទៀត ចុះទៅធ្វើការងារជំនួស។
- គ្រូបង្គោលមួយចំនួនដែលមកពីអង្គការដៃគូ នៅមានកំរិតយល់ដឹងអំពីនីតិវិធីចុះឈ្មោះបោះឆ្នោត និងការធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះបោះឆ្នោត។ គ្រូបង្គោលរបស់ខុមហ្វ្រែលទទួលរ៉ាប់រងបង្រៀនចំណុចសំខាន់ជំនួស។ ម្យ៉ាងទៀត វគ្គខ្លះតម្រូវឲ្យក្រុមការងាររបស់ខុមហ្វ្រែល ពន្យល់បន្ថែមនៅពេលអ្នកសង្កេតការណ៍ចុះសំភាសន៍ជាក់ស្តែង និងក៏ដូចជាក្នុងវគ្គបណ្តុះបណ្តាល ដូចជានៅរាជធានីភ្នំពេញសិក្ខាកាមទាំង ៣ខេត្ត ដូចជាកំពង់ស្ពឺ តាកែវ កណ្តាល។
- ពេលវេលាសំរាប់ត្រួតពិនិត្យទំរង់ និងបញ្ចូលទិន្នន័យត្រូវបានបន្ថែមលើសផែនការកំណត់ (ក្នុងផែនការ អ្នកបញ្ចូល ១០នាក់ រយៈពេល ១០ថ្ងៃ តែជាក់ស្តែងចំណាយរយៈពេល ៣២ថ្ងៃ) ដោយសារតែទំរង់មានសំណួរច្រើនលើសពីទំរង់សំណួរកន្លងមក ម្យ៉ាងទៀតការសំអាតទិន្នន័យដោយគ្រូបង្គោលមានការយឺតយ៉ាវ តែជាក់ស្តែងពួកគេមិនមានពេលវេលាជួយ។ ខុមហ្វ្រែលបានបង្រៀនអ្នកបញ្ចូលទិន្នន័យឲ្យគាត់ជួយត្រួតពិនិត្យ និងកែសំអាតទិន្នន័យនោះ។
- មានការយឺតយ៉ាវក្នុងការវិភាគទិន្នន័យ ព្រោះខុមហ្វ្រែលបានបន្ថែមវិធីសាស្ត្រវិភាគស៊ីជំរៅជាងមុន ឧទាហរណ៍ ប្រើវិធីសាស្ត្របញ្ជាក់ពីទំនាក់ទំនង (Chi-square)។ ខុមហ្វ្រែលបានបង្កើតក្រុមមួយក្នុងការទទួលពិនិត្យ ធ្វើតារាង និងការបកស្រាយទិន្នន័យងាយៗ មុនបញ្ជូនទៅឲ្យអ្នកទីប្រឹក្សាសរសេររបាយការណ៍។

## ៥. សង្ខេបលទ្ធផលស្រាវជ្រាវ

"អ្នកផ្តល់បទសម្ភាសន៍" គឺសំដៅទៅលើអ្នកបោះឆ្នោតដែលត្រូវបានសម្ភាសន៍ និងកំណត់ដោយក្រុមការងារ (អ្នកមានសិទ្ធិបោះឆ្នោត រួមទាំងអ្នកបានចុះឈ្មោះបោះឆ្នោត)។ "ចម្លើយ" សំដៅទៅលើចម្លើយ របស់អ្នកផ្តល់បទសម្ភាសន៍ (អ្នកសម្ភាសន៍ម្នាក់ៗអាចមានចម្លើយលើសពី ១)។ "ភាពមិនត្រឹមត្រូវ" គឺសំដៅទៅលើព័ត៌មានរបស់អ្នកបោះឆ្នោត (ឈ្មោះ ភេទ ឆ្នាំកំណើត ឬអាស័យដ្ឋាន) នៅក្នុងបញ្ជីបោះឆ្នោត ខុសពីឯកសារបញ្ជាក់អត្តសញ្ញាណ របស់អ្នកបោះឆ្នោតហើយដែលអាចនាំឲ្យបាត់បង់សិទ្ធិបោះឆ្នោត ។

- ការសិក្សាបានបង្ហាញថា ៩៤.២% នៃអ្នកមានសិទ្ធិបោះឆ្នោតបានចុះឈ្មោះបោះឆ្នោត។ ប្រសិនបើការប៉ាន់ស្មានអ្នកមានសិទ្ធិបោះឆ្នោតសរុបដែលចេញដោយ គជប សំរាប់ឆ្នាំ ២០១១ មានភាពត្រឹមត្រូវនោះ គជប បានធ្វើការចុះឈ្មោះអ្នកមានសិទ្ធិបោះឆ្នោតចំនួនប្រមាណ១០៤%។ តួលេខនេះអាចធ្វើការប៉ាន់ប្រមាណថា ប្រហែលដោយសារតែបញ្ជីបោះឆ្នោតមានឈ្មោះអ្នកបោះឆ្នោតខ្មោច ឬ/និង ឈ្មោះស្ទួន នៅក្នុងបញ្ជីបោះឆ្នោតឆ្នាំ ២០១១។ម្យ៉ាងទៀត អាចបណ្តាលមកពីបញ្ហាបច្ចេកទេសក្នុងការប៉ាន់ប្រមាណរបស់ គជប ។
- ភាគរយនៃស្ត្រី និងបុរសដែលបានចុះឈ្មោះបោះឆ្នោតមានប្រហាក់ប្រហែលគ្នា។ រីឯចំនួននៃអ្នកចុះឈ្មោះបោះឆ្នោតជាយុវជន (អាយុពី ១៨ ដល់ ៣០) បានចុះឈ្មោះបោះឆ្នោតមានកំរិតទាបជាងអ្នកចុះឈ្មោះបោះឆ្នោតដែលមានវ័យចំណាស់ ។
- ក្នុងចំណោមអ្នកផ្តល់បទសម្ភាសន៍ដែលមិនបានចុះឈ្មោះបោះឆ្នោត ច្រើនជាង៧០% មានចំណេះដឹងត្រឹមតែកំរិតបឋមសិក្សា ឬមិនចេះអាន និងសរសេរអក្សរ។ ការវិភាគបង្ហាញពីទំនាក់ទំនងយ៉ាងច្បាស់រវាងការអប់រំ និងការចុះឈ្មោះបោះឆ្នោត ដោយអ្នកមានសិទ្ធិបោះឆ្នោតដែលមានកំរិតចំណេះដឹងទាបមិនបានចុះឈ្មោះបោះឆ្នោតច្រើនជាងអ្នកដែលមានកំរិតចំណេះដឹងខ្ពស់ ។
- ក្នុងចំណោមអ្នកផ្តល់បទសម្ភាសន៍ ដែលមិនបានចុះឈ្មោះបោះឆ្នោតមាន ៩០.៩% ជាអ្នកដែលមានមុខរបរផ្ទាល់ខ្លួន ។
- ហេតុផលដែលមិនបានចុះឈ្មោះបោះឆ្នោតមានដូចតទៅះ
    - ២៣.៦% បានគិតថា ពួកគាត់មានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោតរួចហើយ (ពួកគាត់អាចនរណាម្នាក់ជួយចុះឈ្មោះបោះឆ្នោតឲ្យ)
    - ១៥.១% ពុំបានទទួលព័ត៌មានពីការចុះឈ្មោះបោះឆ្នោត
    - ៩.៣% មិនមានពេលគ្រប់គ្រាន់ទៅចុះឈ្មោះបោះឆ្នោត
    - ៩.៣% បានផ្លាស់ប្តូរទីលំនៅ
    - ៩.២% មានជំងឺ
    - ៨.៨% ខ្វះឯកសារក្នុងការចុះឈ្មោះបោះឆ្នោត
    - ៤.២% មិនបានដឹងថាមានសិទ្ធិចុះឈ្មោះបោះឆ្នោត
    - ១.៧% ការិយាល័យចុះឈ្មោះបោះឆ្នោតស្ថិតនៅឆ្ងាយ
    - ១.៤% មិនមានថវិកា
    - ០.៨% ធុញនឹងការចុះឈ្មោះ និងពិនិត្យបញ្ជីឈ្មោះបោះឆ្នោត
    - ០.៨% មន្ត្រីចុះឈ្មោះមិនមានភាពរាក់ទាក់
- ២.៤% នៃអ្នកចុះឈ្មោះបោះឆ្នោតមិនបានធ្វើការចុះឈ្មោះបោះឆ្នោតដោយខ្លួនឯងទេ ជំនួសដោយនរណាម្នាក់ចុះឈ្មោះបោះឆ្នោតឲ្យ ។
- យ៉ាងហោច ២.៦% នៃអ្នកផ្តល់បទសម្ភាសន៍បានជួបការលំបាកក្នុងការចុះឈ្មោះបោះឆ្នោត ឬពិនិត្យបញ្ជីឈ្មោះបោះឆ្នោត។ នៅទូទាំង ២៤ ខេត្ត/រាជធានី រតនគិរី ១៤.២៩%, ក្រចេះ ១១.៤៣% និងបន្ទាយមានជ័យ

១០.២៩% បានជួបការលំបាកក្នុងការចុះឈ្មោះ និងពិនិត្យឈ្មោះបោះឆ្នោត។ កំរិតនៃការចុះឈ្មោះបោះឆ្នោតនៅខេត្តដែលជាប់ព្រំដែននេះអាចជះឥទ្ធិពល ដោយសារមូលហេតុ ការផ្លាស់ប្តូររបស់ប្រជាពលរដ្ឋ ឬការធ្វើអន្តោប្រវេសន៍ពលកម្មការងារទៅប្រទេសជិតខាង។ នៅក្នុងចំណោមអ្នកដែលជួបការលំបាក២៨% ជាយុវជន និង ៧២% ជាអ្នកមានវ័យចំណាស់ ។

- ប្រភពព័ត៌មានដែលទាក់ទងទៅនឹងការចុះឈ្មោះបោះឆ្នោត ភាគច្រើនបានមកពីមេភូមិ និងតាមរយៈ វិទ្យុ និង ទូរទស្សន៍។
- ក្នុងចំណោមអ្នកផ្តល់បទសម្ភាសន៍ ៩១.៥% មិនដឹងពីបញ្ជីឈ្មោះបោះឆ្នោតដំបូង។ ១៥.៨% នៃអ្នកមានសិទ្ធបោះឆ្នោតបានយល់ថាទំរង់ ១០១៨ នឹងប្រើប្រាស់សំរាប់ការបោះឆ្នោតនាពេលអនាគត ដូច្នេះពួកគេមិនបានយល់ថាទំរង់នេះត្រូវបានជំនួសដោយលិខិតបញ្ជាក់អត្តសញ្ញាណសំរាប់បំរើឲ្យការបោះឆ្នោត។ រីឯ ៦៦.២% មិនស្គាល់អ្វីទៅជាទំរង់ ១០១៨
- ៦២.៤% នៃអ្នកចុះឈ្មោះបោះឆ្នោតបានធ្វើការពិនិត្យឈ្មោះនៅក្នុងបញ្ជីបោះឆ្នោត ២០១០។ ក្នុងចំណោមអ្នកបានចុះឈ្មោះបោះឆ្នោតដែលមិនបានទៅពិនិត្យឈ្មោះបានអោយហេតុផលដូចតទៅ៖
    - ៥១.៣% គាត់មានឈ្មោះក្នុងបញ្ជីបោះឆ្នោតរួចហើយ
    - ២៣.៩% ពុំបានទទួលព័ត៌មានពីការចុះឈ្មោះ និងពិនិត្យឈ្មោះបោះឆ្នោត
    - ១៨.៧% ពុំមានពេលវេលាគ្រប់គ្រាន់ទៅចុះឈ្មោះបោះឆ្នោត
    - ១០.៣% គាត់មានជំងឺ
    - ៣.២% មន្ត្រីចុះឈ្មោះបោះឆ្នោតមិនរាក់ទាក់
    - ៣.២% ផ្លាស់ប្តូរទីលំនៅ
    - ២.៤% មិនដឹងថាមានសិទ្ធិបោះឆ្នោត
    - ១% ធុញជាមួយការចុះឈ្មោះ និងពិនិត្យឈ្មោះបោះឆ្នោត
    - ១% គ្មានថវិកា
    - ០.១% ត្រូវបានហាមឃាត់ដោយការរើសអើងផ្នែកនយោបាយ
    - ០.១% ត្រូវបានហាមឃាត់ពីការចុះ និងពិនិត្យឈ្មោះបោះឆ្នោត
- ៣៦.៦% នៃអ្នកចុះឈ្មោះបោះឆ្នោតមិនដឹងថាអត្តសញ្ញាណដែលផុតកំណត់អាចប្រើប្រាស់សំរាប់ការបោះឆ្នោត ២០១២ និង២០១៣។ ដោយឡែកនៅថ្ងៃទី ០១ ខែកក្កដា ឆ្នាំ ២០១១ គជប បានចេញសេចក្តីប្រកាស ពីការបន្តសុពលភាពអត្តសញ្ញាណប័ណ្ណដែលផុតកំណត់អាចប្រើប្រាស់បានរហូតដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៣ ។
- ៤.៧% នៃអ្នកមានសិទ្ធិបោះឆ្នោតបានបង្ហាញថា អត្តសញ្ញាណប័ណ្ណត្រូវបានគេដកហូត។ អត្តសញ្ញាណប័ណ្ណដែលត្រូវដកហូតទាំងនោះ ភាគច្រើនត្រូវបានយកដោយអាជ្ញាធរក្នុងគោលបំណងសំរាប់ការចុះឈ្មោះ និងពិនិត្យបញ្ជីឈ្មោះបោះឆ្នោត។ ក្នុងនោះ ៦២.២% ត្រូវបានយកដោយមេភូមិ ១៤.៦% ដោយមេឃុំ ១.១% ដោយក្រុមហ៊ុនឯកជន ៤.៤% យកដោយប៉ូលីស ។
- ៩៨.៨% នៃអ្នកចុះឈ្មោះបោះឆ្នោត នឹងទៅបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ នៅឆ្នាំ២០១២។

- ៦.៩% នៃអ្នកចុះឈ្មោះបោះឆ្នោត មិនមានអត្តសញ្ញាណប័ណ្ណជាតិខ្មែរ ។
- ការសិក្សាស្រាវជ្រាវបង្ហាញថា ៨៩% នៃអ្នកផ្តល់ចម្លើយដែលប្រើប្រាស់អត្តសញ្ញាណប័ណ្ណជាតិខ្មែរក្នុងការចុះឈ្មោះបោះឆ្នោត ។ ៣៤.៨% បានប្រើប្រាស់សៀវភៅគ្រួសារមានបិទរូបថត ។ ១៥.៤% ប្រើសំបុត្រកំណើត រីឯ ៣.៣% ប្រើសៀវភៅ ស្នាក់នៅនិង២.៤% ប្រើប្រាស់សៀវភៅគ្រួសារដែលចេញដោយអាជ្ញាធរ ។
- ២៤.៦% នៃអ្នកចុះឈ្មោះបោះឆ្នោតដែលមានខុសព័ត៌មានយ៉ាងតិចណាស់មួយករណីពីបញ្ជីបោះឆ្នោត ២០១១ (ឆ្នាំកំណើត ឈ្មោះ ភេទ និងអាស័យដ្ឋាន) ។ (នេះគឺជាការកើនឡើងនៃភាពមិនត្រឹមត្រូវបើធៀប ជាមួយ ២១.៨% សំរាប់បញ្ជីបោះឆ្នោត ២០០៨។)
- ខុមហ្វ្រែលបានប្រៀបធៀបទិន្នន័យដែលបានមកពីអ្នកផ្តល់បទសម្ភាសន៍ជាមួយបញ្ជីបោះឆ្នោត ២០១១ ដោយក្នុងនោះខុមហ្វ្រែលបានរកឃើញ ១៧.២% នៃអ្នកចុះឈ្មោះបោះឆ្នោត (ឈ្មោះមិនត្រូវបានរកឃើញនៅក្នុងបញ្ជីឈ្មោះបោះឆ្នោត ២០១១ ឬ ឈ្មោះទាំងនោះត្រូវបានផ្លាស់ប្តូរទាំងស្រុង) ។ តួលេខនេះឃើញថាមានកំរិតទាបជាងបញ្ជីឈ្មោះ ២០០៨ ដែលមាន ១៨.៥% ។ ទោះបីយ៉ាងណា ចំនួននេះមានប្រមាណ ១,៥ លាននាក់នៃអ្នកចុះឈ្មោះបោះឆ្នោត ដែលអាចប្រឈមនឹងការបាត់បង់សិទ្ធិសំរាប់ការបោះឆ្នោតនាពេលខាងមុខ ។ យោងតាមរបាយការណ៍សង្កេតស្រាវជ្រាវបញ្ជីបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោតឆ្នាំ ២០០៨របស់ខុមហ្វ្រែល មានអ្នកមានសិទ្ធិបោះឆ្នោត ប្រមាណ ៤៤០,០០០នាក់ មិនអាចបោះឆ្នោត ដោយសារតែជួបបញ្ហារកឈ្មោះមិនឃើញនៅឯការិយាល័យបោះឆ្នោត ។
- សវនកម្មបញ្ជីបោះឆ្នោត បានរកឃើញទិន្នន័យអ្នកបោះឆ្នោតដែលមិនមានក្នុងបញ្ជីឈ្មោះបោះឆ្នោត ដែលក្នុងនោះភ្នំពេញ ១២.៧% មានតួលេខខ្ពស់ជាងគេ ។ រតនគិរី ៧.៦%, ឧត្តរមានជ័យមាន ៧.៣%, កោះកុងមាន ៦.១១%, បាត់ដំបង ៥.៩៦% រីឯខេត្តផ្សេងៗទៀតមានកំរិតក្រោម ៥% ។
- ខុមហ្វ្រែលរកឃើញករណីពិសេសចំពោះព័ត៌មានអ្នកបោះឆ្នោតមានបន្ថែមឋានៈកិត្តិយសឧទាហរណ៍ **"សម្តេច"** ភ្ជាប់ជាមួយនាមត្រកូល នៅក្នុងបញ្ជីឈ្មោះបោះឆ្នោត ២០១១ ដែលបានបង្កើត និងបង្ហាញនៅលើវែបសាយរបស់ គជប ដែលខុសពីអ្នកបោះឆ្នោតដទៃទៀត។ ដូច្នេះ គជប មានប្រតិបត្តិការពិសេសខ្លះដែលមិនមានចែងក្នុងនីតិវិធីដោយមានអ្នកបោះឆ្នោតមានបន្ថែមទិន្នន័យ "ឋានៈ" ជាពិសេសនៅក្នុងបញ្ជីឈ្មោះបោះឆ្នោត ២០១១។ (សូមមើលឧបសម្ព័ន្ធ ៣ បញ្ជីឈ្មោះបោះឆ្នោតរបស់គជប)

## ៦. នីតិវិធីនៃការចុះឈ្មោះបោះឆ្នោត

ដំណើការចុះឈ្មោះអ្នកបោះឆ្នោត និងការបង្កើតបញ្ជីឈ្មោះអ្នកបោះឆ្នោតដោយអនុលោមទៅតាមបទដ្ឋានគតិយុត្តនិងនិយាមជាសកលឲ្យបានត្រឹមត្រូវ គឺជាប្រតិបត្តិការយ៉ាងសំខាន់មួយក្នុងចំណោមប្រតិបត្តិការសំខាន់ៗផ្សេងទៀតនៃការរៀបចំដំណើរការបោះឆ្នោតដោយសេរី និងយុត្តិធ៌ម។ ព្រះរាជាណាចក្រកម្ពុជាមានក្របខ័ណ្ឌច្បាប់សំខាន់ៗបី សម្រាប់ឱ្យប្រជាពលរដ្ឋអនុវត្តសិទ្ធិបោះឆ្នោតនេះបានដែលនៅក្នុងនោះមាន រដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្ររបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ រដ្ឋធម្មនុញ្ញបានចែងអំពីសិទ្ធិបោះឆ្នោត និងគោលការណ៍គ្រឹះសម្រាប់អនុវត្តសិទ្ធិបោះឆ្នោត ដែលត្រូវបានបញ្ចូលមកពីច្បាប់សិទ្ធិមនុស្សអន្តរជាតិសំខាន់ៗដែលព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័ន ដូចជាសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ជាដើម។ ចំណែកឯច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំង

តំណាងរាស្ត្រ ជំពូកទី៦ ចែងលំអិតពីលក្ខ័ណ្ឌដែលតម្រូវឱ្យមាន ដើម្បីអនុវត្តសិទ្ធិបោះឆ្នោតដោយស្របច្បាប់ និងសម្រាប់ការសុំចុះឈ្មោះបោះឆ្នោត។ ច្បាប់នេះក៏បានកំណត់ និងប្រគល់ភារកិច្ចនេះទៅអោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលជាស្ថាប័នអព្យាក្រិត្យ និងឯករាជ្យ។ ស្ថាប័ននេះមានសិទ្ធិក្នុងការធ្វើបទបញ្ជា និងនីតិវិធី និងសេចក្តីណែនាំនានា ដើម្បីបង្កើតនូវដំណើរការចុះឈ្មោះបោះឆ្នោត ។

ការចុះឈ្មោះអ្នកបោះឆ្នោត និងការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត ត្រូវបានអនុវត្តទៅតាមនីតិវិធីសំខាន់ៗដូចខាងក្រោមៈ

## I. ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត

នៅក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា បានតម្រូវអោយការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ហើយនិងការធ្វើបច្ចុប្បន្នភាព និងការផ្តល់សុពលភាពលើបញ្ជីបោះឆ្នោតត្រូវធ្វើចាប់ពីថ្ងៃទី០១ ខែតុលា រហូតដល់ថ្ងៃទី៣១ ខែធ្នូ ជារៀងរាល់ឆ្នាំ។ នៅខែវិច្ឆិកាឆ្នាំ២០១១ មានការធ្វើវិសោធនកម្មមាត្រា៤៩ និងមាត្រា៦៤នៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនៅឆ្នាំដែលមានការរៀបចំបោះឆ្នោតជាសកល រយៈពេលខាងលើនេះអាចបន្ថែមយ៉ាងយូរបាន៣០ថ្ងៃទៀត ដូចនេះចំនួនថ្ងៃដើម្បីចុះឈ្មោះពិតប្រាកដបានកើនឡើងពី២០ថ្ងៃទៅ៤៥ថ្ងៃ។

ច្បាប់បានណែនាំអំពីក្រុមទទួលខុសត្រូវប្រតិបត្តិ***មាត្រា៥៣*** *គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវធ្វើប្រតិភូកម្មអំណាចដល់ក្រុមប្រឹក្សាឃុំ សង្កាត់ឲ្យបំពេញតួនាទីជាតំណាងខ្លួន ក្នុងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោតសម្រាប់ឃុំ សង្កាត់និមួយៗ។ ដើម្បីអនុវត្តតួនាទីខាងលើ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវប្រគល់ភារកិច្ចដល់ស្មៀនឃុំ សង្កាត់របស់ខ្លួនឲ្យទទួលជាមន្ត្រីពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតក្នុងបញ្ជីបោះឆ្នោតនិងសៀវភៅបញ្ជីបោះឆ្នោតក្នុងឃុំសង្កាត់របស់ខ្លួន។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវដឹកនាំស្មៀនឃុំ សង្កាត់ ឲ្យអនុវត្តឲ្យបានត្រឹមត្រូវនូវច្បាប់ស្តីពីការបោះឆ្នោត បទបញ្ជា និងនីតិវិធីដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចាត់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនមួយ(១)រូបចំពោះឃុំ សង្កាត់ដែលមានសមាជិកក្រុមប្រឹក្សាប្រាំ(៥)រូប និងពីរ(២)រូប ចំពោះឃុំ សង្កាត់ដែលមានសមាជិកក្រុមប្រឹក្សាចាប់ពីប្រាំពីរ(៧)រូបឡើងទៅឲ្យប្រចាំការពិនិត្យមើលការខុសត្រូវលើស្មៀនឃុំ សង្កាត់ក្នុងកំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលប្រចាំការនេះមិនទទួលប្រាក់កំរៃបន្ថែមឡើយ។*

*គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវធ្វើការពិគ្រោះយោបល់ជាមួយក្រសួងមហាផ្ទៃ អំពីការធ្វើប្រតិភូកម្មអំណាចស្របតាមសមត្ថភាព និងធនធានរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ហើយត្រូវធ្វើការបណ្តុះបណ្តាលកសាងសមត្ថភាព និងផ្គត់ផ្គង់មធ្យោបាយ សម្ភារៈ ថវិកាសមស្របដល់ក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀនឃុំ សង្កាត់ដើម្បីអនុវត្តការទទួលខុសត្រូវនេះ។*

ក្នុងន័យច្បាប់នេះ មានស្ថាប័នជាច្រើនដែលត្រូវទទួលខុសត្រូវចាត់ចែង និងប្រតិបត្តិការលើដំណើរការចុះឈ្មោះបោះឆ្នោត និងធ្វើបច្ចុប្បន្នបញ្ជីឈ្មោះរួមមានៈ គ.ជ.ប ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀនឃុំនិងក្រសួងមហាផ្ទៃ។ ច្បាប់ហាក់ចាប់បង្ខំឱ្យ គ.ជ.ប ត្រូវប្រគល់សិទ្ធិអំណាចឱ្យទៅក្រុមប្រឹក្សាឃុំ សង្កាត់បំពេញតួនាទីជាតំណាងរបស់ខ្លួនក្នុងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ប៉ុន្តែនៅពេលដែលក្រុមប្រឹក្សាឃុំ សង្កាត់ណាម្នាក់ រួមទាំងស្មៀនឃុំ បានប្រព្រឹត្តទង្វើមិនប្រក្រតីធ្ងន់ធ្ងរណាមួយច្បាប់មិនបានដោះស្រាយអំពីការគ្រប់គ្រងថាតើ គ.ជ.ប អាចដកសិទ្ធិអំណាចពីក្រុមប្រឹក្សាឃុំ សង្កាត់ ឬស្មៀនឬទេ ហើយត្រូវដាក់ជំនួសដោយមន្ត្រីណាផ្សេងបានដែរឬទេ? ជាឧទាហរណ៍នៅឆ្នាំ២០០៧ និង២០០៨មានការចេញទំរង់ ១០១៨ខុសនីតិវិធីយ៉ាងច្រើនដោយមេឃុំចៅសង្កាត់ ថាតើ គ.ជ.ប អាចដកសិទ្ធិអំណាចរបស់មេឃុំសង្កាត់ទាំងនោះបានដែរឬទេ?

ជានិច្ចកាល ការធ្វើប្រតិភូកម្មអំណាចនេះត្រូវបានភាគីអ្នកពាក់ព័ន្ធក្នុងដំណើរការរៀបចំការបោះឆ្នោតមានដូចជាអ្នកបោះឆ្នោត អង្គការសង្គមស៊ីវិល និងគណបក្សនយោបាយជាដើម បានចាត់ទុកថាអង្គនៃក្រុមប្រឹក្សានេះមិនអាចជាស្ថាប័នអព្យាក្រិត្យក្នុងការធ្វើកិច្ចការនេះបានឡើយ បើទោះបីជាសមាជិកទាំងនោះកើតឡើងដោយការជាប់ឆ្នោតក៏ដោយក៏សមាជិកនៃអង្គក្រុមប្រឹក្សានេះនឹងអាចបាត់បង់ សមាជិកភាពជាក្រុមប្រឹក្សារបស់ខ្លួនទៅវិញ នៅពេលដែលគណបក្សនយោបាយសាមីដែលបានតែងតាំង ដកសមាជិកភាពគណបក្សនយោបាយរបស់គាត់ចេញពីគណបក្សនយោបាយ បើយោងតាមមាត្រា១៦នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។ ក្នុងការទទួលប្រតិភូកម្មអំណាចពី គ.ជ.ប ក្រុមប្រឹក្សាឃុំ សង្កាត់ធ្វើការពិនិត្យ និងប្រមូលទិន្នន័យដើម្បីធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។ ម្យ៉ាងទៀតមានការពិបាកសម្រាប់រកអ្នកដែលទទួលខុសត្រូវអោយបានជាក់លាក់រវាង គ.ជ.ប និងក្រុមប្រឹក្សាឃុំ សង្កាត់ នៅពេលដែលកំហុសនៅក្នុងបញ្ជីចុងក្រោយដែលបោះពុម្ពដោយ គ.ជ.ប។

## II. ឯកសារបញ្ជាក់អត្តសញ្ញាណ (សញ្ជាតិ និងអាយុ) និងទីលំនៅ

អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ គឺជាឯកសារដ៏សំខាន់សម្រាប់ប្រជាពលរដ្ឋក្នុងការបញ្ជាក់សញ្ជាតិខ្មែរ និងអាយុ រួមទាំងទីលំនៅក្នុងឃុំ សង្កាត់ផងដែរ ប្រសិនបើកំពុងរស់នៅទីលំនៅអចិន្ត្រៃយ៍។

នៅប្រទេសកម្ពុជាប្រជាពលរដ្ឋមានសិទ្ធិបោះឆ្នោត(អាយុ១៨ឆ្នាំឡើងទៅ) ពុំមានអត្តសញ្ញាណប័ណ្ណគ្រប់គ្នានោះទេ។ នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១១ រាជរដ្ឋាភិបាល តាមរយៈក្រសួងមហាផ្ទៃ បានចេញអនុក្រិត្យមួយលេខ១៣២ អនក្រ.បក ដើម្បីបន្តសុពលភាពអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរដែលផុតកំណត់រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣។ ការបន្តសុពលភាពនេះបានជួយឱ្យអ្នកមានសិទ្ធិបោះឆ្នោតប្រហែលជា ៤លាននាក់ ងាយស្រួលប្រើប្រាស់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ពួកគេដែលផុតកំណត់សំរាប់ការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់នៅឆ្នាំ២០១២ និងការជ្រើសតាំងអ្នកតំណាងរាស្ត្រនៅឆ្នាំ២០១៣។

អ្នកសុំចុះឈ្មោះបោះឆ្នោតត្រូវបានតម្រូវអោយបង្ហាញឯកសារ ដែលអាចបញ្ជាក់អត្តសញ្ញាណ(សញ្ជាតិ និងអាយុ) និងទីលំនៅ។ នៅពេលប្រជាពលរដ្ឋមិនមានឯកសារ(ដូចជាអត្តសញ្ញាណប័ណ្ណ ឬឯកសារផ្សេងៗ) ពួកគេអាចអាចស្នើទៅមេឃុំ ចៅសង្កាត់នូវឯកសារបញ្ជាក់អត្តសញ្ញាណ ដូចជា ទម្រង់១០១៨ ឬ១០១៩ជំនួស។ នៅថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០១១ គ.ជ.ប និងក្រសួងមហាផ្ទៃបានធ្វើសេចក្តីណែនាំនិងប្តូឈ្មោះទំរង់១០១៨ទៅជាទំរង់ឈ្មោះថាលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បំរើការបោះឆ្នោត។

លិខិតនេះនឹងត្រូវបានចេញឱ្យប្រើប្រាស់សម្រាប់អ្នកសុំចុះឈ្មោះទាំងឡាយណា ដែលមិនមានឯកសារបញ្ជាក់អត្តសញ្ញាណ អាយុ និងទីលំនៅ ដោយគ្រាន់តែនាំមកជាមួយនូវសាក្សីដែលមានសិទ្ធិបោះឆ្នោតនៅក្នុងឃុំ សង្កាត់នោះចំនួន០២នាក់ និងរូបថតពីរសន្លឹកមកជានានៅចំពោះមុខមេឃុំ ចៅសង្កាត់ ។ សេចក្តីណែនាំរបស់ គ.ជ.ប និងក្រសួងមហាផ្ទៃបានបង្ហាញបែបបទនិងនីតិវិធីគ្រប់គ្រាន់នៃការចេញលិខិតនេះ។ ការចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោតមានគល់បញ្ជីត្រឹមត្រូវ និងតម្រូវឱ្យមានការធ្វើរបាយការណ៍បូកសរុបនៃការចេញលិខិតនេះ។ រីឯលិខិតបញ្ជាក់ទីលំនៅក្នុងឃុំ សង្កាត់(ទម្រង់១០១៩) ក៏ជាឯកសារមួយក្នុងចំណោមឯកសារផ្លូវការសម្រាប់ប្រើប្រាស់ធ្វើជាឯកសារសម្រាប់សុំចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោតបានផងដែរនៅពេលណាដែលអ្នកសុំចុះឈ្មោះនោះមិនមានឯកសារបញ្ជាក់ទីលំនៅក្នុងឃុំ សង្កាត់។

## III. ការបិទបញ្ជីឈ្មោះបោះឆ្នោត

ក្នុងកំឡុងពេល១០ថ្ងៃមុនពេលថ្ងៃចាប់ផ្តើមការពិនិត្យ និងការចុះឈ្មោះបោះឆ្នោត ក្រុមប្រឹក្សាឃុំសង្កាត់ និងស្មៀនឃុំ សង្កាត់ត្រូវបិទផ្សាយនូវបញ្ជីឈ្មោះ ទីតាំងការិយាល័យបោះឆ្នោត និងការិយាល័យចុះឈ្មោះបោះឆ្នោតនៅសាលាឃុំសង្កាត់ និងនៅទីកន្លែងណាមួយក្នុងឃុំ សង្កាត់។

ចំណែកការបិទបញ្ជីឈ្មោះបោះឆ្នោតមានពីរដំណាក់កាលខុសគ្នា ដើម្បីឱ្យប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធទៅពិនិត្យ និងផ្ទៀងផ្ទាត់ទិន្នន័យ ព័ត៌មាន ជាពិសេសគឺឈ្មោះ។

ក្នុងកំឡុងពេលចុះឈ្មោះបោះឆ្នោត ក្រុមប្រឹក្សាឃុំសង្កាត់ និងស្មៀនឃុំត្រូវបិទបញ្ជីបោះឆ្នោតចុងក្រោយ ឧទាហរណ៍ សំរាប់ការចុះឈ្មោះបោះឆ្នោតឆ្នាំ២០១១ បញ្ជីបោះឆ្នោតចុងក្រោយគឺបញ្ជីឆ្នាំ២០១០។ អ្នកបោះឆ្នោត (ឬប្រជាពលរដ្ឋ ដែលមានឈ្មោះខុសបញ្ជីបោះឆ្នោត) ពិនិត្យទិន្នន័យឈ្មោះរបស់ខ្លួនឡើងថាតើត្រឹមត្រូវដែរឬទេ? បើខុសទិន្នន័យ (ឬខុសអក្ខរាវិរុទ្ធនៃឈ្មោះ) អ្នកបោះឆ្នោត(ឬប្រជាពលរដ្ឋនោះ) ស្នើស្មៀនឱ្យកែតម្រូវ តាមឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការដែលយកមកបង្ហាញ។ ក្នុងករណីបាត់ឈ្មោះពួកគេស្នើស្មៀនឱ្យចុះឡើងវិញ។ នៅត្រង់នីតិវិធីនេះ អ្នកបោះឆ្នោត (ឬប្រជាពលរដ្ឋទាំងនោះ)អាចចុះឈ្មោះកើនពីរដង បើសិនការខុសអក្ខរាវិរុទ្ធនៃឈ្មោះរបស់ពួកគេគឺខ្លាំងទាំងស្រុងពេក។ ក្រោយពេលចុះឈ្មោះបោះឆ្នោតភ្លាម បើគ្មានពាក្យបណ្តឹង ក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀនឃុំ/សង្កាត់ត្រូវបិទបញ្ជីបោះឆ្នោតដំបូង។

បញ្ជីបោះឆ្នោតដំបូងគឺបានមកពីការផ្តុំបញ្ចូល បញ្ជីបោះឆ្នោតចុងក្រោយ ដែលបានធ្វើបច្ចុប្បន្នភាពរួច និងបញ្ជីបន្ថែមដែលបានផ្ទៀងផ្ទាត់រួច។ ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ (គណបក្សនយោបាយ) អាចមកពិនិត្យម្តងទៀតក្នុងគោលដៅកែតម្រូវបញ្ជីបោះឆ្នោតដំបូងតាមរយៈការប្តឹងតវ៉ា ដោយសារមិនឃើញឈ្មោះ ឬខុសទិន្នន័យ និងអក្ខរាវិរុទ្ធ ឬមានឈ្មោះប៉ុន្តែឈ្មោះនៅក្នុងការិយាល័យផ្សេង។ ប្រជាពលរដ្ឋ ឬអ្នកពាក់ព័ន្ធអាចពិនិត្យ និងប្តឹងជំទាស់ មានឈ្មោះក្នុងបញ្ជីបោះឆ្នោតតែជននោះគ្មានសិទ្ធិដូចក្នុងលក្ខ័ណ្ឌ។

## IV. ការប្តឹងតវ៉ា ឬជំទាស់ និងការដោះស្រាយ

វិសោធនកម្មនៃច្បាប់ជ្រើសតាំងតំណាងរាស្ត្រនៅខែវិច្ឆិកា ឆ្នាំ២០១១ ក៏បានបន្ថែមថ្ងៃសម្រាប់ការប្តឹងតវ៉ា ឬការប្តឹងជំទាស់លើបញ្ជីបោះឆ្នោតដំបូងចំនួន៥ថ្ងៃ ដែលសរុបរយៈពេលទាំងអស់គឺ១០ថ្ងៃ។ រយៈពេលនេះអាចជួយធានាប្រជាពលរដ្ឋក៏ដូចជាគណបក្សនយោបាយមានពេលវេលាក្នុងការពិនិត្យឈ្មោះ និងប្តឹងតវ៉ាអំពីការបាត់ឈ្មោះ ឬជំទាស់ការចុះឈ្មោះ ឬរក្សាទុកឈ្មោះ មិនស្របច្បាប់ក្នុងបញ្ជីបោះឆ្នោត។ ខាងក្រោមបង្ហាញអំពីនីតិវិធីការប្តឹងតវ៉ា ក្នុងដំណាក់កាលនៃការចុះឈ្មោះបោះឆ្នោត និងការប្តឹងតវ៉ា ឬការប្តឹងជំទាស់ក្នុងដំណាក់កាលបិទផ្សាយបញ្ជីដំបូង។

### 1. ការប្តឹងតវ៉ាក្នុងដំណាក់កាលចុះឈ្មោះបោះឆ្នោត

នៅពេលដែលការសុំចុះឈ្មោះបោះឆ្នោតត្រូវបានបដិសេធដោយស្មៀនឃុំ សង្កាត់ អ្នកសុំចុះឈ្មោះមានសិទ្ធិប្តឹងតវ៉ាទៅក្រុមប្រឹក្សាឃុំ សង្កាត់នៃទីកន្លែងដែលបានសុំចុះឈ្មោះក្នុងរយៈពេល៣ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃទទួលសេចក្តីសម្រេចបដិសេធពីស្មៀនឃុំ សង្កាត់។ ប្រសិនបើអ្នកសុំចុះឈ្មោះមិនពេញចិត្តទៅនឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា ឃុំ សង្កាត់ អ្នកសុំចុះឈ្មោះនោះអាចដាក់ពាក្យបណ្តឹងតវ៉ារបស់ខ្លួនទៅ គ.ជ.ប ក្នុងរយៈពេល៥ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងបដិសេធ។ ក្នុងករណីដែលអ្នកប្តឹងតវ៉ា នៅតែមិនពេញចិត្តទៅនឹងសេចក្តីសម្រេចរបស់ គ.ជ.ប អ្នកសុំចុះឈ្មោះនោះអាចដាក់ពាក្យបណ្តឹងតវ៉ារបស់ខ្លួនទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល៥ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងបដិសេធពី គ.ជ.ប។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញគឺជាសេចក្តីសម្រេចចុងក្រោយបិទផ្លូវតវ៉ា។

2. **ការប្តឹងតវ៉ា ឬ/និងជំទាស់ទៅនឹងការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង**

នៅពេលដែលរយៈពេលពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ហើយការប្តឹងតវ៉ាទៅនឹងការចុះឈ្មោះបានបញ្ចប់ បញ្ជីបោះឆ្នោតដំបូងនឹងត្រូវបានបិទផ្សាយជាសាធារណៈនៅតាមឃុំ សង្កាត់និមួយៗ។ ចំពោះឃុំ សង្កាត់ ដែលមានសេចក្តីសម្រេចចេញពី ក្រុមប្រឹក្សាឃុំ សង្កាត់ គ.ជ.ប និងក្រុមប្រឹក្សាធម្មនុញ្ញ ទាក់ទងទៅនឹងការប្តឹងតវ៉ាទៅនឹងការចុះឈ្មោះបោះឆ្នោតនេះ ទិន្នន័យដែលមាននៅក្នុងបញ្ជីបោះឆ្នោតដំបូងនៃឃុំ សង្កាត់នោះ ត្រូវផ្អែកទៅលើសេចក្តីសម្រេចទាំងនោះ។ ក្នុងរយៈពេល៥ថ្ងៃបន្ទាប់ពីការបិទផ្សាយនូវបញ្ជីបោះឆ្នោតដំបូងនេះមក ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិប្តឹងតវ៉ា ឬ/និងប្តឹងជំទាស់ទៅនឹងទិន្នន័យដែលមាននៅក្នុងបញ្ជីបោះឆ្នោតដំបូងនោះទៅ ក្រុមប្រឹក្សាឃុំ សង្កាត់ និងជាបន្តបន្ទាប់ទៅគ.ជ.ប និងក្រុមប្រឹក្សាធម្មនុញ្ញ។ ចំពោះឆ្នាំដែលមានការរៀបចំការបោះឆ្នោតជាសកល រយៈពេលប្តឹងតវ៉ា ឬ/និងប្តឹងជំទាស់នេះមានរយៈពេល១០ថ្ងៃ បន្ទាប់ពីថ្ងៃបិទផ្សាយនូវបញ្ជីបោះឆ្នោតដំបូង។ រាល់កម្មវត្ថុនៃការប្តឹងតវ៉ា ឬ/និងប្តឹងជំទាស់ទៅនឹងទិន្នន័យក្នុងបញ្ជីបោះឆ្នោតដំបូង ត្រូវតែអនុលោមទៅតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប បើពុំដូច្នោះទេ រាល់បណ្តឹងទាំងនោះនឹងត្រូវបដិសេធចោលដោយក្រុមប្រឹក្សាឃុំ សង្កាត់។

បើទោះបីជាស្ថាប័នក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវបានច្បាប់កំណត់អោយជាស្ថាប័នកំពូលក្នុងការដោះស្រាយវិវាទក្នុងការបោះឆ្នោតក៍ដោយក៍មានភាគីពាក់ព័ន្ធមួយចំនួនយល់ថា ការដោះស្រាយដោយស្ថាប័ននេះ នៅតែមិនអាចទទួលយកបាននៅឡើយ ពីព្រោះមិនមានក្របខ័ណ្ឌច្បាប់ជាក់លាក់ សម្រាប់បង្ហាញពីតំណើរការស៊ើបអង្កេតអោយបានច្បាស់លាស់ទៅលើបណ្តឹងដែលស្ថាប័ននេះទទួលបន្ទុកដោះស្រាយ ដូចជាបណ្តឹងទាក់ទងទៅនឹងការសុំចុះឈ្មោះបោះឆ្នោត បណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ទៅនឹងបញ្ជីបោះឆ្នោតដំបូងជាដើម ពីព្រោះស្ថាប័ននេះនឹងវិនិច្ឆ័យដោយផ្អែកទៅលើអ្វីដែលក្រុមប្រឹក្សាឃុំ សង្កាត់ និង គ.ជ.ប បានធ្វើការវិនិច្ឆ័យរួចមកហើយ។

V. **ការផ្តល់សុពលភាពលើបញ្ជីបោះឆ្នោត**

បន្ទាប់ពីដំណើរការនៃបណ្តឹងទាំងនេះចប់ជាស្ថាពរហើយ គ.ជ.ប នឹងបញ្ជាអោយមជ្ឈមណ្ឌលកុំព្យូទ័ររៀបចំកែតម្រូវទិន្នន័យដែលមាននៅក្នុងកុំព្យូទ័រ និងបញ្ចូលទិន្នន័យថ្មីទៅក្នុងកុំព្យូទ័រ ដោយផ្អែកទៅលើសេចក្តីសម្រេចជាស្ថាពរនៃបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ និងរបាយការណ៍របស់ស្មៀនឃុំ សង្កាត់ ក្នុងការរៀបចំបោះពុម្ពបញ្ជីបោះឆ្នោតតាមការិយាល័យបោះឆ្នោតនិមួយៗ ដើម្បីជាក់ជូន គ.ជ.ប ផ្តល់សុពលភាពជាបញ្ជីបោះឆ្នោតផ្លូវការប្រចាំឆ្នាំនិងរក្សាទុកជាសៀវភៅបញ្ជីបោះឆ្នោតអចិន្ត្រៃយ៍នៅឃុំ សង្កាត់សម្រាប់ជាកម្មវត្ថុបម្រើសាធារណជន។ *ប្រការ៤.២៩ នៃបទបញ្ជា និងនីតិវិធីសម្រាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្ររបស់ គ.ជ.ប៖ បន្ទាប់ពីការប្តឹងតវ៉ា ឬ/និង ការប្តឹងជំទាស់ទាក់ទងទៅនឹងការបិទផ្សាយបញ្ជីបោះឆ្នោតដំបូងត្រូវបានដោះស្រាយតាមលំដាប់ថ្នាក់ រួចរាល់ជាស្ថាពរហើយ គ.ជ.ប ត្រូវចាត់ចែងឲ្យមជ្ឈមណ្ឌលកុំព្យូទ័រកែតម្រូវបញ្ជីបោះឆ្នោត ដោយផ្អែកលើរាល់សេចក្តីសម្រេចដោះស្រាយបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ និងរបាយការណ៍របស់ស្មៀនឃុំ សង្កាត់ដែលបានផ្ញើជូន ដូចមានចែងក្នុងចំណុច ៤.២៧.១០ ខាងលើ។ មជ្ឈមណ្ឌលកុំព្យូទ័រត្រូវរៀបចំ និងបោះពុម្ពបញ្ជីបោះឆ្នោតតាមការិយាល័យបោះឆ្នោតនីមួយៗ រួចដាក់ជូន គ.ជ.ប ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រាផ្តល់សុពលភាពជាបញ្ជីបោះឆ្នោតផ្លូវការប្រចាំឆ្នាំ។*

បញ្ហាមួយដែលគួរអោយកត់សម្គាល់នៅក្នុងតំណាក់កាលនេះ គឺនៅពេលដែលមានកំហុសនៅក្នុងបញ្ជីបោះឆ្នោតដែល គ.ជ.ប បានផ្តល់សុពលភាព ដែលបញ្ជីនេះត្រូវបានរៀបចំផលិត និងបញ្ចូលទិន្នន័យដោយមជ្ឈមណ្ឌលកុំព្យូទ័ររបស់ គ.ជ.ប ខុសគ្នាជាមួយនឹងបញ្ជីចុងក្រោយរបស់ស្មៀនឃុំ សង្កាត់ដែលកត់ត្រាដោយដៃមុននឹងបញ្ជូនមកមជ្ឈមណ្ឌលកុំព្យូទ័ររបស់ គ.ជ.ប ដែលធ្វើអោយមានការពិបាកក្នុងការរកអ្នកទទួលខុសត្រូវអោយបានពិតប្រាកដ បើទោះជាមានប្រតិភូកម្មអំណាចពី គ.ជ.ប ក៍ដោយ។ ជាគោលការណ៍នៃការធ្វើប្រតិភូកម្មអំណាច ប្រតិភូទទួលអំណាចមានសិទ្ធិផ្តាច់មុខ និងទទួល

ខុសត្រូវយ៉ាងពេញលេញនូវអ្វីដែលអ្នកធ្វើប្រតិភូបានធ្វើប្រតិភូអំណាចមកអោយ ហើយអ្នកធ្វើប្រតិភូ មិនអាចអនុវត្តនូវកិច្ចការដែលបានធ្វើប្រតិភូកម្មអំណាចបានទៀតឡើយ។

**៧. អានុសាសន៍**

មានជំរើសេ២ប្រភេទ

- **ជំរើសទី១៖ សំដៅលើការផ្លាស់ប្តូរប្រព័ន្ធចុះឈ្មោះបោះឆ្នោត** ការចុះឈ្មោះបោះឆ្នោត និងការធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះអ្នកបោះឆ្នោត គួរតែផ្លាស់ប្តូរទាំងស្រុងដើម្បីឲ្យការចុះឈ្មោះបោះឆ្នោតមានភាពងាយស្រួល និងសាមញ្ញ ហើយនឹងជានាគុណភាពនៃបញ្ជីឈ្មោះបោះឆ្នោត។ ប្រព័ន្ធថ្មី គឺធ្វើឡើងដើម្បីឲ្យពេលវេលានៃការចុះឈ្មោះបោះឆ្នោតមានលក្ខណៈអចិន្ត្រៃយ៍ (សំរាប់អ្នកមានអាយុ១៨ឆ្នាំ ឬក៏អ្នកដែលដូរទីលំនៅ អាចចុះឈ្មោះបោះឆ្នោតនៅក្នុងម៉ោងធ្វើការបាន)។រាជរដ្ឋាភិបាលគួរធ្វើវិសោធនកម្មលើនិតិវិធីក្នុងការធ្វើអត្តសញ្ញាណប័ណ្ណសំរាប់ប្រើបានអស់មួយជីវិត។ ប្រជាពលរដ្ឋត្រូវបានជំរុញឲ្យប្តូររូបថតរបស់ពួកគាត់បន្ទាប់ពីប្រើប្រាស់អត្តសញ្ញាណប័ណ្ណ២០ឆ្នាំរួចមក។ ក្រសួងមហាផ្ទៃសហប្រតិបត្តិការជាមួយនឹងអ្នកជំនាញ និងម្ចាស់ជំនួយ កំពុងប្រឹងប្រែងក្នុងការផលិតកម្មវិធី ដើម្បីបង្កើតប្រព័ន្ធទិន្នន័យអត្តសញ្ញាណជីវសញ្ញាមួយ ខណៈពេលដែលប្រជាពលរដ្ឋម្នាក់ៗ មានលេខអត្តសញ្ញាណប័ណ្ណអចិន្ត្រៃយ៍មួយផ្ទាល់ខ្លួន។បញ្ជីឈ្មោះបោះឆ្នោតគួរតែត្រូវបានរួមបញ្ចូលជាមួយនឹងប្រព័ន្ធទិន្នន័យអត្តសញ្ញាណជីវសញ្ញា ហើយនឹងលេខអចិន្ត្រៃយ៍ អត្តសញ្ញាណប័ណ្ណរបស់ប្រជាពលរដ្ឋម្នាក់ៗ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គួរប្រើប្រព័ន្ធទិន្នន័យរបស់អត្តសញ្ញាណប័ណ្ណ ដើម្បីបង្កើតបញ្ជីឈ្មោះបោះឆ្នោត។
- **ជំរើសទី២៖ សំដៅលើការធ្វើឲ្យប្រព័ន្ធបច្ចុប្បន្នកាន់តែប្រសើរឡើង**

ប្រព័ន្ធចុះឈ្មោះនេះគឺរក្សាទុកដដែល ក៏ប៉ុន្តែគ្រាន់តែធ្វើឲ្យប្រសើរឡើងនូវបច្ចុប្បន្នភាពបញ្ជីឈ្មោះបោះឆ្នោត ការចែកចាយប័ណ្ណព័ត៌មានរបស់អ្នកបោះឆ្នោត (VIN) ការធ្វើ/ចេញអត្តសញ្ញាណប័ណ្ណ និងលិខិតបញ្ជាក់អត្តសញ្ញាណសំរាប់បំរើឲ្យការបោះឆ្នោត។

**ក. <u>បច្ចុប្បន្នភាពបញ្ជីឈ្មោះបោះឆ្នោត</u>**

ដើម្បីធ្វើឲ្យគុណភាពបញ្ជីឈ្មោះបោះឆ្នោតកាន់តែប្រសើរឡើង ការធ្វើបច្ចុប្បន្នភាព បញ្ជីចុះឈ្មោះបោះឆ្នោត គួរត្រូវបានធ្វើឡើងដោយគណកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយសហប្រតិបត្តិការជាមួយក្រុមប្រឹក្សាឃុំ។

មុនពេលធ្វើបច្ចុប្បន្នភាព ឬលុបឈ្មោះអ្នកបោះឆ្នោតដែលគាត់បានផ្លាស់ប្តូរទីលំនៅទៅកាន់ឃុំដទៃ ឬស្លាប់ចេញពីបញ្ជីឈ្មោះបោះឆ្នោត ក្រុមប្រឹក្សាឃុំត្រូវមានឯកសារបញ្ជាក់។ ផ្ទុយទៅវិញ អាស្រ័យដោយការបោះឆ្នោតធ្វើឡើងរៀងរាល់ ៥ឆ្នាំម្តង ក្នុងកំឡុងពេលនៃឆ្នាំបោះឆ្នោត គណកម្មការជាតិរៀបចំការបោះឆ្នោតដោយធ្វើការសហប្រតិបត្តិការជាមួយប្រធានឃុំ និងសមាជិកក្រុមប្រឹក្សាឃុំ (សមាជិកក្រុមប្រឹក្សាឃុំ ២នាក់ មកពីគណបក្សនយោបាយផ្សេងៗគ្នា) ស្មៀនឃុំ និងអង្គាធរដែនដី ត្រូវតែទទួលខុសត្រូវក្នុងការរៀបចំបញ្ជីបោះឆ្នោតពិសេសមួយដែលធ្វើបច្ចុប្បន្នភាពយ៉ាងជាក់លាក់មួយសំរាប់ឆ្នាំបោះឆ្នោត។ គណកម្មាធិការជាតិរៀបចំការបោះឆ្នោត គួរតែតែងតាំងបុគ្គលិករបស់ខ្លួនជាប្រធានក្នុងការរៀបចំការចុះឈ្មោះបោះឆ្នោត និងការបច្ចុប្បន្នភាពបញ្ជីឈ្មោះបោះឆ្នោតថ្នាក់ឃុំ ចំណែកឯក្រុមប្រឹក្សាថ្នាក់ឃុំ និងស្មៀនឃុំត្រូវធ្វើជាជំនួយការរបស់ប្រធាន។

ដំណើរការធ្វើបច្ចុប្បន្នភាព បញ្ជីឈ្មោះគួរត្រូវបានផ្លាស់ប្តូរ។ គណកម្មាធិការជាតិរៀបចំការបោះឆ្នោត គួរប្រើបញ្ជីចុះឈ្មោះបោះឆ្នោតចុងក្រោយ ហើយធ្វើការស្វែងរកអ្នកបោះឆ្នោតទាំងឡាយណាមិនបានទៅបោះឆ្នោតនូវការបោះឆ្នោតចុង

ក្រោយនេះ។ ដូចនេះហើយ គណកម្មាធិការជាតិរៀបចំការបោះឆ្នោត គួរតែយកចិត្តទុកដាក់ខ្លាំងតែលើប្រជាពលរដ្ឋណាដែលមិនបានបោះឆ្នោតនៅពេលបោះឆ្នោតចុងក្រោយ ហើយមិនចាំបាច់យកចិត្តទុកដាក់លើប្រជាពលរដ្ឋទាំងឡាយណាដែលបានបោះឆ្នោតក្នុងពេលបោះឆ្នោតចុងក្រោយនោះទេ។

**ខ.** **<u>សមាហរណកម្មនៃលេខអត្តសញ្ញាណប័ណ្ណ</u>**

លេខអត្តសញ្ញាណប័ណ្ណ គួរតែត្រូវបានបន្ថែមនៅក្នុងបញ្ជីឈ្មោះបោះឆ្នោត ដែលធ្វើឲ្យវាងាយស្រួលសម្រាប់អ្នកបោះឆ្នោត ក្នុងការស្វែងរកឈ្មោះរបស់ពួកគេ នៅក្នុងករណីដែលឈ្មោះ ថ្ងៃខែឆ្នាំកំណើត ភេទ និងអាស័យដ្ឋានមិនត្រឹមត្រូវ។

បញ្ជីចុះឈ្មោះបោះឆ្នោតអាចត្រូវបានធ្វើការផ្ទៀងផ្ទាត់ (ឈ្មោះ ថ្ងៃខែឆ្នាំកំណើត និងភេទ) ជាមួយលេខអត្តសញ្ញាណប័ណ្ណ។

លេខអត្តសញ្ញាណប័ណ្ណនេះអាចដាក់ជំនួសលេខប័ណ្ណ-បង្កាន់ដៃ(ចុះឈ្មោះបោះឆ្នោត) ។ គួរបន្ថែមបន្ទាត់ជួរឈរ (កូលោន) មួយទៀត នៅក្នុងបញ្ជីឈ្មោះបោះឆ្នោតសំរាប់កំនត់សំគាល់ករណីពិសេសចំពោះអ្នកបោះឆ្នោត ។

**គ.** **<u>ប័ណ្ណព័ត៌មានអ្នកបោះឆ្នោត (VIN)</u>**

ប័ណ្ណព័ត៌មានអ្នកបោះឆ្នោត (VIN) គួរត្រូវបានចេញ និងចែកចាយជូនអ្នកដែលបានចុះឈ្មោះបោះឆ្នោត ជាពិសេសអ្នកចុះឈ្មោះបោះឆ្នោតទាំងឡាយណាដែលស្ថានីយ ឬទីតាំងបោះឆ្នោតរបស់ពួកគេ ត្រូវបានផ្លាស់ប្តូរដោយសារការធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះបោះឆ្នោតរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ហើយការបង្ហាញព័ត៌មានយ៉ាងច្បាស់លាស់ពីស្ថានីយបោះឆ្នោត ប្រសិនបើប័ណ្ណព័ត៌មានអ្នកបោះឆ្នោតត្រូវបានលុបចោល បញ្ជីចុះឈ្មោះបោះឆ្នោតត្រូវតែបិទបង្ហាញនៅក្នុងភូមិនីមួយៗ ។ ការចែកចាយប័ណ្ណព័ត៌មានអ្នកបោះឆ្នោត គួរតែបន្តធ្វើឡើងដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយសហប្រតិបត្តិការជាមួយមេឃុំ សមាជិកក្រុមប្រឹក្សាឃុំ (សមាជិកក្រុមប្រឹក្សា ២នាក់ មកពីគណបក្សផ្សេងគ្នា) ស្មៀនឃុំ អង្គការសង្កេតការបោះឆ្នោត និងគណបក្សនយោបាយចូលរួមការប្រកួតប្រជែងក្នុងការបោះឆ្នោត ដែលតំរូវឲ្យទទួលខុសត្រូវក្នុងការងារដើម្បីឲ្យអ្នកចុះឈ្មោះបោះឆ្នោតទាំង១០០%ទទួលបាននូវប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ។

**ឃ.** **<u>អត្តសញ្ញាណប័ណ្ណ និងលិខិតបញ្ជាក់អត្តសញ្ញាណបំរើឲ្យការបោះឆ្នោត</u>**

សំរាប់សកម្មភាពបន្ទាន់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតគួរតែបន្តអំពាវនាវជាសាធារណៈ និងជាញឹកញាប់អំពីសេចក្តីណែនាំក្នុងការអនុញ្ញាតឲ្យប្រើប្រាស់អត្តសញ្ញាណប័ណ្ណដែលអស់សុពលភាព ជាឯកសារសំគាល់ក្នុងថ្ងៃបោះឆ្នោត។

មេឃុំគួរតែត្រូវបានណែនាំ ឲ្យមានតម្លាភាពក្នុងការចេញអត្តសញ្ញាណប័ណ្ណ និងលិខិតបញ្ជាក់អត្តសញ្ញាណបំរើឲ្យការបោះឆ្នោត។ ស្ថាប័នពាក់ព័ន្ធនឹងការបោះឆ្នោតទាំងអស់ រួមមានអង្គការសង្កេតការបោះឆ្នោត ហើយនិងគណបក្សនយោបាយចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោត អាចត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងធ្វើសវនកម្មលើការចេញអត្តសញ្ញាណប័ណ្ណ និងលិខិតបញ្ជាក់អត្តសញ្ញាណបំរើឲ្យការបោះឆ្នោត។

**ង.** **<u>ការចុះឈ្មោះបោះឆ្នោត</u>**

ក្រុមប្រឹក្សាឃុំសង្កាត់ និងគជប ត្រូវពង្រឹងការអនុវត្តន៍ដំណើរការនៃការចុះឈ្មោះបោះឆ្នោត ដែលអ្នកមានសិទ្ធិបោះឆ្នោតគួរតែទៅចុះឈ្មោះបោះឆ្នោតត្រូវបង្ហាញខ្លួននៅការិយាល័យបោះឆ្នោត និងបង្ហាញឯកសារនានាដែលតំរូវដោយនីតិវិធីចុះឈ្មោះបោះឆ្នោត។

# ៨. ទិភាគទិន្នន័យ

## ៨.១ ការចុះឈ្មោះបោះឆ្នោត

### ៨.១.១ កំរិតនៃការចុះឈ្មោះបោះឆ្នោតតាមភេទ និងអាយុ

តារាងទី ២ បង្ហាញថា ៩៤.២% នៃអ្នកមានសិទ្ធិបោះឆ្នោតបានចុះឈ្មោះបោះឆ្នោត ។ ប្រសិនបើចំនួននៃការប៉ាន់ប្រមាណអ្នកមានសិទ្ធិបោះឆ្នោតដោយ គ.ជ.ប មានភាពត្រឹមត្រូវនោះ គ.ជ.ប បានធ្វើការចុះឈ្មោះអ្នកមានសិទ្ធិបោះឆ្នោតរហូតដល់ប្រមាណ ១០៤% ។ តួលេខដែល គ.ជ.ប បានធ្វើការចុះឈ្មោះអ្នកមានសិទ្ធិបោះឆ្នោតនោះបាន ៩,២០៣,៤៩៣ នាក់ ដែលលើសពីចំនួនប៉ាន់ប្រមាណអ្នកមានសិទ្ធិបោះឆ្នោត សរុប ៨,៨៩៤,៧១៩ នាក់ ។ ទាំងនេះអាចធ្វើការប៉ាន់ប្រមាណថា ភាពមិនត្រឹមត្រូវនេះអាចបណ្ដាលមកពីមានឈ្មោះខ្មោច ឬ/និងឈ្មោះស្ទួន និងម្យ៉ាងទៀតអាច ដោយសារតែបញ្ហាបច្ចេកទេសក្នុងការប៉ាន់ប្រមាណរបស់ គជប ។

បើសិនជាបែងចែងការចុះឈ្មោះបោះឆ្នោតតាមភេទវិញ ភាគរយនៃស្ត្រីដែលបានចុះឈ្មោះបោះឆ្នោត ៩៤.១% បានចុះឈ្មោះបោះឆ្នោត ភាគរយនេះមានប្រហាក់ប្រហែលនឹងភាគរយបុរសដែលបានចុះឈ្មោះបោះឆ្នោត ៩៤.៤% ដែរ។

សំរាប់អ្នកចុះឈ្មោះបោះឆ្នោតជាយុវជនវិញ (អាយុពី ១៨ ទៅ ៣០ឆ្នាំ) ចំនួនអ្នកដែលមានវ័យចំណាស់ដែលបានផ្ដល់បទសម្ភាសន៍មានច្រើនជាង ៣ ដងនៃចំនួនយុវជន ប៉ុន្តែកំរិតភាគរយយុវជនដែលមិនបានចុះឈ្មោះបោះឆ្នោតមាន ១១.៣% ច្រើនជាងភាគរយនៃអ្នកដែលមានវ័យចំណាស់ ៣.៧% ។

**តារាងទី ២ កំរិតនៃការចុះឈ្មោះបោះឆ្នោតតាមភេទ និងអាយុ**

| ការចុះឈ្មោះបោះឆ្នោត | សរុប | | តាមភេទ | | | | តាមអាយុ | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | ស្ត្រី | | បុរស | | យុវជន | | វ័យចំណាស់ | |
| | ចំនួន | % | ចំនួន | % | ចំនួន | % | ចំនួន | % | ចំនួន | % |
| បានចុះឈ្មោះ | ៨១៧១ | ៩៤,២ | ៤៩៣៥ | ៩៤,១ | ៣២៣៦ | ៩៤,៤ | ២០៩៥ | ៨៨,៧ | ៦០៧៦ | ៩៦,៣ |
| មិនបានចុះឈ្មោះ | ៥០១ | ៥,៨ | ៣០៨ | ៥,៩ | ១៩៣ | ៥,៦ | ២៦៦ | ១១,៣ | ២៣៥ | ៣,៧ |
| សរុប | ៨៦៧២ | ១០០ | ៥២៤៣ | ១០០ | ៣៤២៩ | ១០០ | ២៣៦១ | ១០០ | ៦៣១១ | ១០០ |

### ៨.១.២ អ្នកមានសិទ្ធិបោះឆ្នោតដែលមិនបានទៅចុះឈ្មោះបោះឆ្នោត តាមខេត្ត និងអាយុ

តារាងទី ៣ បង្ហាញពីកំរិតនៃការចុះឈ្មោះបោះឆ្នោតនៅខេត្តនីមួយៗ ។ ខេត្តប៉ៃលិន មាន ២១,៧% និងខេត្តរតនគិរី មាន ២១,១% គឺជាខេត្តដែលមានភាគរយខ្ពស់ជាងគេនៃអ្នកមានសិទ្ធិបោះឆ្នោតដែលមិនបានទៅចុះឈ្មោះបោះឆ្នោត ។ ផ្ទុយទៅវិញ ខេត្តកណ្ដាល មាន ០,៥% ស្វាយរៀង ១,១% និងខេត្តកំពង់ចាមមាន ១,៣% មានកំរិតភាគរយទាបជាងគេនៃអ្នកមានសិទ្ធិបោះឆ្នោតមិនបានទៅចុះឈ្មោះបោះឆ្នោត ។

សង្កេតមើលពីការចូលរួមរបស់យុវជនទៅតាមខេត្តនីមួយៗ ខេត្តរតនគិរី ៤១,១% និងខេត្តប៉ៃលិន ២៤,៨% គឺជាខេត្តដែលមានភាគរយខ្ពស់នៃយុវជនមិនបានចុះឈ្មោះបោះឆ្នោត ប៉ុន្តែភាគរយដែលមានកំរិតទាបដូចជាខេត្តកំពង់ស្ពឺ ១,៥% ខេត្តកណ្ដាល ២,៨% ខេត្តកែប ២,១% ខេត្តកំពង់ចាម ០,៨% និងខេត្តតាកែវ ០,៨% ។

**តារាងទី ៣ អ្នកមានសិទ្ធិបោះឆ្នោតដែលមិនបានចុះឈ្មោះបោះឆ្នោត**

| លេរ | ខេត្ត | អ្នកចុះឈ្មោះបោះឆ្នោតនៃខេត្តនីមួយៗ | | អ្នកមិនបានចុះឈ្មោះបោះឆ្នោតតាមខេត្តនីមួយៗ | | យុវជនមិនបានចុះឈ្មោះបោះឆ្នោតតាមខេត្តនីមួយៗ | |
|---|---|---|---|---|---|---|---|
| | | ចំនួន | % | ចំនួន | % | ចំនួន | % |
| ១ | បន្ទាយមានជ័យ | ៣៤៨ | ៩២,៦ | ២៨ | ៧,៤ | ១៥ | ១៥,៨ |
| ២ | បាត់ដំបង | ៣៦០ | ៩៥ | ១៩ | ៥ | ១៤ | ១៣,៧ |
| ៣ | កំពង់ចាម | ៣៧៧ | ៩៨,៧ | ៥ | ១,៣ | ៣ | ៤,៥ |
| ៤ | កំពង់ឆ្នាំង | ៣៦៤ | ៩៧,៦ | ៩ | ២,៤ | ៤ | ៤,៤ |
| ៥ | កំពង់ស្ពឺ | ៣៦៦ | ៩៧,៣ | ១០ | ២,៧ | ១ | ១,៥ |
| ៦ | កំពង់ធំ | ៣៦៩ | ៩៧,១ | ១១ | ២,៩ | ៧ | ៦,៦ |
| ៧ | កំពត | ៣៦៣ | ៩៥,៨ | ១៦ | ៤,២ | ១២ | ១០,៣ |
| ៨ | កណ្តាល | ៣៧៩ | ៩៩,៥ | ២ | ០,៥ | ២ | ២,៨ |
| ៩ | កោះកុង | ៣៣៣ | ៩៨,៥ | ៥ | ១,៥ | ៤ | ៤,៤ |
| ១០ | ក្រចេះ | ៣៤៧ | ៩៤,៦ | ២០ | ៥,៤ | ១២ | ១៦ |
| ១១ | មណ្ឌលគិរី | ២៤៨ | ៩០,២ | ២៧ | ៩,៨ | ១៦ | ១៧ |
| ១២ | ភ្នំពេញ | ៣៧០ | ៩៦,៦ | ១៣ | ៣,៤ | ៩ | ៥,៨ |
| ១៣ | ព្រះវិហារ | ៣២៦ | ៩៣,៩ | ២១ | ៦,១ | ១៨ | ១៤,១ |
| ១៤ | ព្រៃវែង | ៣៥៦ | ៩៣,៧ | ២៤ | ៦,៣ | ៥ | ៦,៣ |
| ១៥ | ពោធិ៍សាត់ | ៣១៩ | ៨៦,៤ | ៥០ | ១៣,៦ | ១៧ | ១៣,១ |
| ១៦ | រតនគិរី | ២៦៦ | ៧៨,៩ | ៧១ | ២១,១ | ៥១ | ៤១,១ |
| ១៧ | សៀមរាប | ៣៥១ | ៩៣,១ | ២៦ | ៦,៩ | ១១ | ១២,៩ |
| ១៨ | ព្រះសីហនុ | ៣៣៨ | ៩៥,៥ | ១៦ | ៤,៥ | ៩ | ១០,៥ |
| ១៩ | ស្ទឹងត្រែង | ៣៣៣ | ៩២,៨ | ២៦ | ៧,២ | ១០ | ៨,៧ |
| ២០ | ស្វាយរៀង | ៣៧២ | ៩៨,៩ | ៤ | ១,១ | ៤ | ៤,២ |
| ២១ | តាកែវ | ៣៧២ | ៩៨,៤ | ៦ | ១,៦ | ៣ | ៣,៤ |
| ២២ | ឧត្តរមានជ័យ | ៣៤៣ | ៩៥,៣ | ១៧ | ៤,៧ | ១២ | ១១,៥ |
| ២៣ | កែប | ៣១៨ | ៩៨,៥ | ៥ | ១,៥ | ២ | ២,១ |
| ២៤ | ប៉ៃលិន | ២៥៣ | ៧៨,៣ | ៧០ | ២១,៧ | ២៥ | ២៤,៨ |

**៨.១.៣ អ្នកមានសិទ្ធិចុះឈ្មោះបោះឆ្នោតដែលមិនបានចុះឈ្មោះបោះឆ្នោតប្រៀបធៀបជាមួយកំរិតអប់រំ**

អ្នកផ្តល់បទសម្ភាសន៍ត្រូវបានសួរពីកំរិតនៃការសិក្សាដែលពួកគេសំរេចបាន ហើយការសិក្សាបង្ហាញពីទំនាក់ទំនងយ៉ាងសំខាន់រវាងកំរិតអប់រំ និងការចុះឈ្មោះបោះឆ្នោត (រូបភាពទី ១) ។ ភាគរយខ្ពស់នៃអ្នកដែលមិនបានចុះឈ្មោះបោះឆ្នោត គឺជាអ្នកដែលមានកំរិតសិក្សាទាប ដែលក្នុងនោះ ៣៧,៨% នៃអ្នកដែលមិនបានចុះឈ្មោះបោះឆ្នោតចេះអាន និងសរសេរអក្សរ និងរៀនបានត្រឹមបឋមសិក្សា (ថ្នាក់ទី ១ ដល់ទី ៦) និង៣២,៥% គឺជាអ្នកដែលមិនបានចុះឈ្មោះបោះឆ្នោតដែលមិនបានទៅសាលារៀនទាល់តែសោះ ។ ប៉ុន្តែផ្ទុយទៅវិញ ភាគរយនៃអ្នកដែលមិនបានចុះឈ្មោះបោះឆ្នោត ១,៨% គឺអ្នកដែលមានកំរិតសិក្សាខ្ពស់ (រៀនលើសថ្នាក់មធ្យមសិក្សាទុតិយភូមិ ឬថ្នាក់ឧត្តម និងក្រោយឧត្តម)។

**រូបភាពទី ១ អ្នកមានសិទ្ធិចុះឈ្មោះបោះឆ្នោតដែលមិនបានចុះឈ្មោះបោះឆ្នោតធៀបកំរិតអប់រំ**




### ៨.១.៤ អ្នកដែលមានសិទ្ធិចុះឈ្មោះបោះឆ្នោតដែលមិនបានចុះឈ្មោះបោះឆ្នោតប្រៀបធៀបជាមួយមុខរបរ

រូបភាពទី ២ បង្ហាញពីទំនាក់ទំនងរវាង ការចុះឈ្មោះបោះឆ្នោត និងមុខរបរការងារ ។ ក្នុងចំណោមអ្នកមានសិទ្ធិចុះឈ្មោះបោះឆ្នោតដែលមិនបានចុះឈ្មោះបោះឆ្នោត ៨០,៩% គឺជាអ្នកដែលមានមុខរបរផ្ទាល់ខ្លួន និងមាន ៦% គឺជាអ្នកដែលមិនមានការងារធ្វើក្នុងរយៈពេល ១២ ខែចុងក្រោយ ហើយអ្នកដែលមានការងារដែលមានប្រាក់ខែជាប្រចាំ មាន ៣% រីឯអ្នកដែលធ្វើកសិកម្ម មាន ២,៦% ។

ការវិភាគដើម្បីកំនត់ទំនាក់ទំនង (Chi-Square) បានបង្ហាញអោយឃើញថាកំរិតមុខរបរអាចមានឥទ្ធិពលយ៉ាងខ្លាំងទៅលើការចុះឈ្មោះបោះឆ្នោត។ អ្វីដែលគួរឲ្យចាប់អារម្មណ៍ គឺអ្នកមានសិទ្ធិបោះឆ្នោតដែលមានមុខរបរកសិកម្មមិនបានចុះឈ្មោះបោះឆ្នោតតិចជាងអ្នកដែលមានប្រាក់ខែទៀងទាត់ទៅវិញ ។

**រូបភាពទី ២ អ្នកមានសិទ្ធិបោះឆ្នោតមិនបានចុះឈ្មោះបោះឆ្នោតធៀបជាមួយមុខរបរ**




### ៨.១.៥ មូលហេតុដែលមិនបានចុះឈ្មោះបោះឆ្នោត

អ្នកមានសិទ្ធិចុះឈ្មោះបោះឆ្នោត ដែលមិនបានចុះឈ្មោះបោះឆ្នោតត្រូវបានសួរពីមូលហេតុដូចមាននៅក្នុងរូបភាពទី៣ ។ ២៣,៦% នៃអ្នកមិនបានទៅចុះឈ្មោះបោះឆ្នោតបានជឿជាក់ថា ឈ្មោះរបស់ពួកគាត់មាននៅក្នុងបញ្ជីឈ្មោះបោះ

ឆ្នោតរួចរាល់ហើយ (អ្នកមានសិទ្ធិបោះឆ្នោតទាំងនេះអាចមានអ្នកដទៃជួយចុះឈ្មោះបោះឆ្នោតឲ្យ) ។ បន្ទាប់ពីនេះដែរ មាន ១៥,១% ពួកគាត់ថា មិនបានទទួលព័ត៌មានស្តីពីការចុះឈ្មោះបោះឆ្នោត។ ការប៉ាន់ស្មានបានលើកឡើងថា ២៣,៦% អ្នកមិនបានទៅចុះឈ្មោះបោះឆ្នោតដែលថា ឈ្មោះពួកគាត់មានរួចហើយនៅក្នុងបញ្ជីឈ្មោះបោះឆ្នោត ជាមូលហេតុដែលមិនបានចុះឈ្មោះបោះឆ្នោត អាចជាចំនុចដែលគួរឲ្យព្រួយបារម្ភ ព្រោះថាអ្នកមានសិទ្ធិបោះឆ្នោតទាំងនេះអាចប្រឈម នឹងការមិនបានបោះឆ្នោតសំរាប់ការបោះឆ្នោតនាពេលខាងមុខ ។ រីឯ ៤,២% នៃអ្នកមានសិទ្ធិបោះឆ្នោត មិនបានទៅចុះឈ្មោះបោះឆ្នោត ដោយសារមូលហេតុមិនដឹងថាមានសិទ្ធិចុះឈ្មោះបោះឆ្នោត។

**រូបភាពទី ៣ មូលហេតុដែលមិនបានចុះឈ្មោះបោះឆ្នោត**




**៨.១.៦ អ្នកចុះឈ្មោះបោះឆ្នោតបានចុះឈ្មោះបោះឆ្នោតដោយមិនបានទៅដោយផ្ទាល់**

រូបភាពទី ៤ បានបង្ហាញថា ៩៧,៦% នៃអ្នកបានចុះឈ្មោះបោះឆ្នោត ដែលបានបង្ហាញមុខនៅការិយាល័យបោះឆ្នោត ឬទៅចុះឈ្មោះដោយផ្ទាល់។ ទោះបីជាយ៉ាងណា ២,៤% នៃអ្នកបានចុះឈ្មោះបោះឆ្នោតបានចុះឈ្មោះបោះឆ្នោតដោយមានអ្នកចុះឈ្មោះឲ្យ ។ បើតាមនីតិវិធីបានលើកឡើងថា អ្នកមានសិទ្ធិចុះឈ្មោះបោះឆ្នោតត្រូវចុះឈ្មោះបោះឆ្នោតដោយបង្ហាញមុខចំពោះមុខស្មៀន ឃុំនៅពេលចុះឈ្មោះបោះឆ្នោត ។

**រូបភាពទី ៤ អ្នកចុះឈ្មោះបោះឆ្នោតបានចុះឈ្មោះបោះឆ្នោតមិនបានចុះឈ្មោះដោយផ្ទាល់**



### ៨.១.៧ អ្នកមានសិទ្ធិបោះឆ្នោតដែលជួបការលំបាកក្នុងការចុះឈ្មោះ និងពិនិត្យបញ្ជីឈ្មោះបោះឆ្នោត

អ្នកមានសិទ្ធិបោះឆ្នោតត្រូវបានសួរពីភាពលំបាករបស់គាត់ ដូចជា "មិនលំបាកទាល់តែសោះ, មិនលំបាក, លំបាក, លំបាកខ្លះដែរ និងលំបាកខ្លាំងណាស់" ។ រូបភាពទី ៥ បង្ហាញថា ៩៧,៤% នៃអ្នកផ្តល់ចម្លើយបានជ្រើសរើស " មិនលំបាកទាល់តែសោះ និងមិនលំបាក" ។ ទោះបីយ៉ាងណាក៏ដោយ ២,៦% នៃអ្នកមានសិទ្ធិបោះឆ្នោត បានបង្ហាញពីភាពលំបាកខ្លះដែរ ។

លទ្ធផលមិនបានបង្ហាញពីហេតុផលដែលមិនបានចុះឈ្មោះបោះឆ្នោតមានភាពខុសគ្នាខ្លាំង រវាងស្ត្រី និងបុរស នោះទេ ។ ទោះបីយ៉ាងណា ខុមហ្វ្រែល បានកត់សំគាល់ឃើញថា ទំនាក់ទំនងរវាងអ្នកមានសិទ្ធិចុះឈ្មោះបោះឆ្នោតដែលមិនបានទៅចុះឈ្មោះបោះឆ្នោតជាមួយនឹងកំរិតនៃការអប់រំ ហើយក្នុងនោះឃើញថា អត្រានៃអ្នកចេះអាន និងសរសេរ មានភាពខុសគ្នា រវាងស្ត្រី និងបុរស ដោយអាត្រាចេះអាន និងសរសេររបស់ស្ត្រីមាន ៧១% និងអាត្រានៃការចេះអាន និងសរសេររបស់បុរសមាន ៨៥,១% (UNESCO) ។ ទាំងនេះអាចជាអាត្រាដែលគួរឲ្យចាប់អារម្មណ៍ក្នុងការសង្កេត ថាតើស្ត្រីជួបការលំបាកច្រើនជាងបុរសកំឡុងពេលដំណើរការចុះឈ្មោះបោះឆ្នោត ដោយសារកំរិតវប្បធម៌មានកំរិតទាប។

**រូបភាពទី ៥ អ្នកមានសិទ្ធិបោះឆ្នោតជួបការលំបាកក្នុងការចុះឈ្មោះ និងពិនិត្យបញ្ជីឈ្មោះបោះឆ្នោត**




### ៨.១.៨ អ្នកមានសិទ្ធិបោះឆ្នោតជួបការលំបាកក្នុងការចុះឈ្មោះបោះឆ្នោតតាមខេត្តនីមួយៗ

ការលំបាកដែលអ្នកមានសិទ្ធិបោះឆ្នោតបានជួបការលំបាកនៅតាមខេត្តនីមួយៗត្រូវបានធ្វើការវិភាគ ។ ១៤.២៩% នៃអ្នកចុះឈ្មោះបោះឆ្នោតនៅខេត្តរតនគិរីបានជួបការលំបាកសំរាប់ក្រុមអាយុទាំងអស់នៅក្នុងការចុះឈ្មោះ និងពិនិត្យបញ្ជីឈ្មោះបោះឆ្នោត ។ ទោះបីយ៉ាងណា នៅខេត្តរតនគិរី ភាគរយស្ត្រីដែលបានចុះឈ្មោះបោះឆ្នោត បានបង្ហាញពីការលំបាកក្នុងការចុះឈ្មោះ និងពិនិត្យបញ្ជីឈ្មោះបោះឆ្នោត ដែលមាន ៩,២៨% ទាបជាង បុរស ២០,៥១% ។ ផ្ទុយមកវិញ នៅខេត្តក្រចេះ ១១,៤៣% នៃអ្នកចុះឈ្មោះបោះឆ្នោតបានធ្វើការត្អូញត្អែរពីដំណើរការនៃការចុះឈ្មោះ និងពិនិត្យបញ្ជីឈ្មោះ ដែលក្នុងនោះចំនួនអ្នកបោះឆ្នោតជាស្ត្រីបានត្អូញត្អែរច្រើនជាងបុរស ។

**តារាងទី ៤ អ្នកមានសិទ្ធិបោះឆ្នោតជួបការលំបាកក្នុងការចុះឈ្មោះបោះឆ្នោតតាមខេត្ត**

| រៀងលេខ | ខេត្ត | អ្នកចុះឈ្មោះបោះឆ្នោតតាមភេទ | | | | សរុប | |
|---|---|---|---|---|---|---|---|
| | | ស្ត្រី | | បុរស | | | |
| | | ចំនួន | % | ចំនួន | % | ចំនួន | % |
| ១ | បន្ទាយមានជ័យ | ៧ | ៧,២២ | ១១ | ១៤,០១ | ១៨ | ១០,២៩ |
| ២ | បាត់ដំបង | ៥ | ៥,១៥ | ៦ | ៧,៦៩ | ១១ | ៦,២៩ |
| ៣ | កំពង់ចាម | ១ | ១,០៣ | ៤ | ៥,១៣ | ៥ | ២,៨៦ |
| ៤ | កំពង់ឆ្នាំង | ៥ | ៥,១៥ | ៣ | ៣,៨៥ | ៨ | ៤,៥៧ |
| ៥ | កំពង់ស្ពឺ | ៧ | ៧,២២ | ៤ | ៥,១៣ | ១១ | ៦,២៩ |
| ៦ | កំពត | ០ | ០ | ២ | ២,៥៦ | ២ | ១,១៤ |
| ៧ | កណ្ដាល | ៣ | ៣,០៩ | ៣ | ៣,៨៥ | ៦ | ៣,៤៣ |
| ៨ | កោះកុង | ២ | ២,០៦ | ១ | ១,២៨ | ៣ | ១,៧១ |
| ៩ | ក្រចេះ | ១៧ | ១៧,៥៣ | ៣ | ៣,៨៥ | ២០ | ១១,៤៣ |
| ១០ | មណ្ឌលគិរី | ៥ | ៥,១៥ | ៤ | ៥,១៣ | ៩ | ៥,១៤ |
| ១១ | ភ្នំពេញ | ៨ | ៨,២៥ | ១ | ១,២៨ | ៩ | ៥,១៤ |
| ១២ | ព្រះវិហារ | ១ | ១,០៣ | ៤ | ៥,១៣ | ៥ | ២,៨៦ |
| ១៣ | ព្រៃវែង | ០ | ០ | ១ | ១,២៨ | ១ | ០,៥៧ |
| ១៤ | ពោធិសាត់ | ៤ | ៤,១២ | ២ | ២,៥៦ | ៦ | ៣,៤៣ |
| ១៥ | រតនគិរី | ៩ | ៩,២៨ | ១៦ | ២០,៥១ | ២៥ | ១៤,២៩ |
| ១៦ | សៀមរាប | ៣ | ៣,០៩ | ២ | ២,៥៦ | ៥ | ២,៨៦ |
| ១៧ | ព្រះសីហនុ | ៣ | ៣,០៩ | ៤ | ៥,១៣ | ៧ | ៤ |
| ១៨ | ស្ទឹងត្រែង | ០ | ០ | ២ | ២,៥៦ | ២ | ១,១៤ |
| ១៩ | ស្វាយរៀង | ៤ | ៤,១២ | ១ | ១,២៨ | ៥ | ២,៨៦ |
| ២០ | តាកែវ | ៥ | ៥,១៥ | ១ | ១,២៨ | ៦ | ៣,៤៣ |
| ២១ | ឧត្ដរមានជ័យ | ៥ | ៥,១៥ | ១ | ១,២៨ | ៦ | ៣,៤៣ |
| ២២ | ក្រុងកែប | ១ | ១,០៣ | ២ | ២,៥៦ | ៣ | ១,៧១ |
| ២៣ | ប៉ៃលិន | ២ | ២,០៦ | ០ | ០ | ២ | ១,១៤ |
| សរុប | | ៩៧ | ១០០ | ៧៨ | ១០០ | ១៧៥ | ១០០ |

## ៤.២ ព័ត៌មាននៃការចុះឈ្មោះបោះឆ្នោត

### ៤.២.១ ប្រភពព័ត៌មាននៃការចុះឈ្មោះបោះឆ្នោត

អ្នកបោះឆ្នោតភាគច្រើនបានទទួលព័ត៌មានពីការចុះឈ្មោះ និងពិនិត្យបញ្ជីឈ្មោះបោះឆ្នោតតាមរយៈប្រធានភូមិមាន៨០,៦% និងវិទ្យុ ទូរទស្សន៍ ៣៥,៣%។ ប្រភពព័ត៌មានដែលទទួលបានពី វេទិការសាធារណៈរបស់អង្គការសង្គមស៊ីវិលមានតិចតួចគឺ ០,៥%។ ប៉ុន្តែផ្ទុយទៅវិញ ២១,៩% ព័ត៌មានបានមកពីអាជ្ញាធរ ដែលទាំងនេះអាចកត់សំគាល់ឃើញថាអ្នកផ្ដល់បទសម្ភាសន៍អាចផ្ដល់ចម្លើយពីរដងទាក់ទងទៅនឹងការទទួលព័ត៌មានពីប្រធានភូមិនេះ អាចពិចារណាបានថាពួកគេគិតថាប្រធានភូមិជាអាជ្ញាធរ។ ព័ត៌មានស្ដីពីការចុះឈ្មោះ និងពិនិត្យបញ្ជីឈ្មោះបោះឆ្នោត ដែលបានមកពីអ្នកជិតខាង និងក្រុមសហគមន៍ ១៩% និង តាមរយៈមេក្រូ ១៣,៤% ក៏ជាប្រភពព័ត៌មានដ៏សំខាន់មួយដែរ (រូបភាពទី ៦)។

ការវិភាគដើម្បីកំណត់ទំនាក់ទំនង (Chi Square) បានបង្ហាញថា ប្រភពព័ត៌មាននៃការចុះឈ្មោះបោះឆ្នោត មិនបានជះឥទ្ធិពលទៅលើការសំរេចចិត្តរបស់អ្នកមានសិទ្ធិបោះឆ្នោតក្នុងការចុះឈ្មោះ និងពិនិត្យបញ្ជីឈ្មោះបោះឆ្នោតនោះទេ។

### រូបភាពទី ៦ ប្រភពព័ត៌មាននៃការចុះឈ្មោះបោះឆ្នោត




#### ៨.២.២ ប្រភពព័ត៌មានពីការបោះឆ្នោត

អ្នកផ្តល់បទសម្ភាសន៍ ត្រូវបានសួរពីប្រភពព័ត៌មានពីការបោះឆ្នោតដែលពួកគេបានទទួល (តារាងទី៥) ។ ៧៨,៥% នៃអ្នកមានសិទ្ធិបោះឆ្នោតបានទទួលព័ត៌មានពី មេភូមិ និង ៣២,៥% បានទទួលពីវិទ្យុ និងទូរទស្សន៍ ។ ប៉ុន្តែ ១,៦% ពួកគេលើកឡើងថា មិនបានទទួលព័ត៌មានពីការបោះឆ្នោត និង ១,៥% បានទទួលព័ត៌មានពីការឃោសនា ការប្រជុំសាធារណៈ ។

តារាងទី ៥ បង្ហាញថា ក្នុងចំណោមអ្នកចុះឈ្មោះបោះឆ្នោត ៧៩,២% បានទទួលព័ត៌មានពីមេភូមិ និង ៣២,៥% បានទទួលពីវិទ្យុ និងទូរទស្សន៍។ ហើយក្នុងចំណោមអ្នកមិនបានចុះឈ្មោះបោះឆ្នោត ៦៧,៣% បានទទួលព័ត៌មានពីមេភូមិ និង ៣២.៧% បានពីទូរទស្សន៍ ។

### តារាងទី ៥ ប្រភពព័ត៌មានពីការបោះឆ្នោត

| លេ | ប្រភពព័ត៌មាន | អ្នកមានសិទ្ធិបោះឆ្នោត | | ៨៤៦៦ អ្នកផ្តល់បទសម្ភាសន៍ | | | |
|---|---|---|---|---|---|---|---|
| | | | | ៨០១០ អ្នកចុះឈ្មោះបោះឆ្នោត | | ៤៥៦ មិនបានចុះឈ្មោះបោះឆ្នោត | |
| | | ចំនួន | % | ចំនួន | % | ចំនួន | % |
| ១ | យុទ្ធនាការផ្សព្វផ្សាយការបោះឆ្នោតរបស់គណៈកម្មការរៀបចំការបោះឆ្នោតនៅក្នុងឃុំ/ខេត្ត | ២០២៥ | ២៣,៩ | ១៩៧៨ | ២៤,៧ | ៤៧ | ១០,៣ |
| ២ | វិទ្យុ/ទូរទស្សន៍ | ២៧៥១ | ៣២,៥ | ២៦០២ | ៣២,៥ | ១៤៩ | ៣២,៧ |
| ៣ | គណបក្សនយោបាយ | ៤៨៤ | ៥,៧ | ៤៧៣ | ៥,៩ | ១១ | ២,៤ |
| ៤ | កាសែត | ៣៤៣ | ៤,១ | ៣២៩ | ៤,១ | ១៤ | ៣,១ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៥ | ខ្ញុំមិនបានទទួលព័ត៌មានអ្វីទាំងអស់ពីដំណើរការ នៃការបោះឆ្នោត | ១៣៥ | ១,៦ | ៨៦ | ១,១ | ៤៩ | ១០,៧ |
| ៦ | អ្នកជិតខាង/សមាជិកសហគមន៍ គ្រួសារ/មិត្តភ័ក្តិ | ១៥៣១ | ១៨,១ | ១៤៥០ | ១៨,១ | ៨១ | ១៧,៨ |
| ៧ | ប្រជុំ/កិច្ចប្រជុំសាធារណៈ/យុទ្ធនាការ | ១២៨ | ១,៥ | ១២៨ | ១,៦ | ០ | ០ |
| ៨ | មេភូមិ | ៦៦៤៧ | ៧៨,៥ | ៦៣៤០ | ៧៩,២ | ៣០៧ | ៦៧,៣ |
| ៩ | អាជ្ញាធរ | ១៩៦៧ | ២៣,២ | ១៩៣០ | ២៤,១ | ៣៧ | ៨,១ |

### ៨.២.៣ ប្រភពព័ត៌មានពីការបោះឆ្នោតជាមួយការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ ២០១២

ការវិភាគដើម្បីកំណត់ទំនាក់ទំនង (Chi-Square) បង្ហាញថា ប្រភពព័ត៌មានស្តីពីការបោះឆ្នោតជាកត្តាសំខាន់ដែលមានឥទ្ធិពលយ៉ាងខ្លាំងទៅលើ ការសំរេចចិត្តថាតើអ្នកបោះឆ្នោតទៅ ឬមិនទៅសំរាប់ការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់នៅឆ្នាំ២០១២ គឺអាស្រ័យទៅលើការផ្សព្វផ្សាយ ដូចជាយុទ្ធនាការផ្សព្វផ្សាយការបោះឆ្នោតរបស់គណៈកម្មការរៀបចំការបោះឆ្នោតនៅក្នុងឃុំ/ខេត្ត វិទ្យុ/ទូរទស្សន៍ គណបក្សនយោបាយ កាសែត/ខិត្តប័ណ្ណ/រូបភាពផ្ទាំងធំ មេភូមិ អាជ្ញាធរ និងចំណុចមួយទៀតគឺពួកគាត់មិនបានទទួលព័ត៌មានអ្វីទាំងអស់ពីដំណើរការនៃការបោះឆ្នោត ។

តារាងទី៦ បង្ហាញថា ព័ត៌មានពីការបោះឆ្នោតដែលទទួលបានពីមេភូមិ គឺជាព័ត៌មានដ៏សំខាន់ដែលអាចធ្វើឲ្យ ៧៧,៣២% នៃអ្នកមានសិទ្ធិបោះឆ្នោតទៅបោះឆ្នោត និងតាមរយៈវិទ្យុ/ទូរទស្សន៍ ៣២,០៤% នៃអ្នកមានសិទ្ធិបោះឆ្នោតទៅបោះឆ្នោត ។

**តារាងទី ៦ ប្រភពព័ត៌មានពីការបោះឆ្នោតជាមួយការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ ២០១២**

| លេ | ប្រភពព័ត៌មានពីការបោះឆ្នោត | ការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ ២០១២ | | | | | |
|---|---|---|---|---|---|---|---|
| | | មិនទៅបោះឆ្នោត | | ទៅបោះឆ្នោត | | សរុប | |
| | | ចំនួន | % | ចំនួន | % | ចំនួន | % |
| ១ | យុទ្ធនាការផ្សព្វផ្សាយការបោះឆ្នោតរបស់គណៈកម្មការរៀបចំការបោះឆ្នោតនៅក្នុងឃុំ/ខេត្ត | ៣៥ | ១៤,៨៣ | ១៩៧៦ | ២៣,៦៨ | ២០១១ | ២៣,៤៤ |
| ២ | វិទ្យុ/ទូរទស្សន៍ | ៦០ | ២៥,៤២ | ២៦៨៩ | ៣២,២២ | ២៧៤៩ | ៣២,០៤ |
| ៣ | គណបក្សនយោបាយ | ៥ | ២,១២ | ៤៧៧ | ៥,៧២ | ៤៨២ | ៥,៦២ |
| ៤ | កាសែត | ៣ | ១,២៧ | ៣៣៩ | ៤,០៦ | ៣៤២ | ៣,៩៩ |
| ៥ | ខ្ញុំមិនបានទទួលព័ត៌មានអ្វីទាំងអស់ពីដំណើរការនៃការបោះឆ្នោត | ២១ | ៨,៩ | ១១២ | ១,៣៤ | ១៣៣ | ១,៥៥ |
| ៦ | អ្នកជិតខាង/សមាជិកសហគមន៍ គ្រួសារ/មិត្តភ័ក្តិ | ៣៨ | ១៦,១ | ១៤៩២ | ១៧,៨៨ | ១៥៣០ | ១៧,៨៣ |
| ៧ | ប្រជុំ/កិច្ចប្រជុំសាធារណៈ/យុទ្ធនាការ | ១ | ០,៤២ | ១២៧ | ១,៥២ | ១២៨ | ១,៤៩ |
| ៨ | មេភូមិ | ១០៧ | ៤៥,៣៤ | ៦៥២៨ | ៧៨,២៣ | ៦៦៣៥ | ៧៧,៣២ |
| ៩ | អាជ្ញាធរ | ៣១ | ១៣,១៤ | ១៩៣៤ | ២៣,១៨ | ១៩៦៥ | ២២,៩០ |
| | សរុប | ២៣៦ | ២,៧៥ | ៨៣៤៥ | ៩៧,២៥ | ៨៥៨១ | ១០០ |

### ៨.២.៤ បញ្ជីឈ្មោះបោះឆ្នោតដំបូង

បញ្ជីឈ្មោះបោះឆ្នោតដំបូង ត្រូវបានគេផ្គុំបញ្ចូលគ្នារវាងបញ្ជីបោះឆ្នោតចុងក្រោយដែលធ្វើបច្ចុប្បន្នភាពរួច ជាមួយបញ្ជីចុះឈ្មោះបោះឆ្នោតបន្ថែម។ ហើយបញ្ជីនេះ ត្រូវបានគេបិទផ្សាយនៅការិយាល័យនៅសាលាឃុំសង្កាត់ និងកន្លែងផ្សេងទៀតនៅក្នុងឃុំសង្កាត់ បន្ទាប់ពីបញ្ចប់ការចុះឈ្មោះ និងពិនិត្យបញ្ជីឈ្មោះបោះឆ្នោតដើម្បីទទួលបណ្តឹងទាក់ទងទៅនឹងបញ្ជីឈ្មោះបោះឆ្នោត ។

រូបភាពទី ៧ បានបង្ហាញថា ភាគរយនៃការយល់ដឹងរបស់អ្នកចុះឈ្មោះបោះឆ្នោត ទៅលើបញ្ជីឈ្មោះបោះឆ្នោតដំបូងគឺមានកំរិតទាប។ នេះក៏អាចចាប់អារម្មណ៍បានថា អ្នកចុះឈ្មោះបោះឆ្នោតមិនមានការដឹងច្រើនទៅលើបញ្ជីឈ្មោះបោះឆ្នោតដំបូងនោះទេ។ ទាំងនេះនឹងត្រូវពិចារណាថា អ្នកចុះឈ្មោះបោះឆ្នោត នឹងគួរតែអាចទទួលបាននូវព័ត៌មានពីដំណើរការនៃការចុះឈ្មោះ និងពិនិត្យបញ្ជីឈ្មោះបោះឆ្នោត ។

**រូបភាពទី ៧ បញ្ជីបោះឆ្នោតដំបូង**




### ៨.២.៥ ទំរង់ ១០១៨ សំរាប់បំរើឲ្យការបោះឆ្នោតនាពេលអនាគត

តារាងទី ៧ បង្ហាញថា ៦៦,២% នៃអ្នកមានសិទ្ធិបោះឆ្នោតមិនស្គាល់ពីទំរង់ ១០១៨ ។ ១៥,៨% នៃអ្នកមានសិទ្ធិបោះឆ្នោតបានយល់ដឹងថា ទំរង់១០១៨អាចប្រើប្រាស់សំរាប់ការបោះឆ្នោតនាពេលអនាគត។ មានត្រឹមតែ ១៨,១% នៃអ្នកមានសិទ្ធិបោះឆ្នោតបាននិយាយថា ទំរង់ ១០១៨ នឹងមិនអាចប្រើប្រាស់សំរាប់ការបោះឆ្នោតនាពេលខាងមុខទេ ។

មានការព្រួយបារម្ភ ដែល ៦៥,៤% នៃអ្នកចុះឈ្មោះបោះឆ្នោតមិនស្គាល់ពីទំរង់ ១០១៨ ដែលនេះជាភាគរយខ្ពស់បើធៀបជាមួយអ្នកដែលបានផ្តល់បទសម្ភាសន៍ទាំងអស់ ។ ផ្ទុយទៅវិញ ១៦,១% នៃអ្នកចុះឈ្មោះបោះឆ្នោតដឹងថា ទំរង់ ១០១៨ នៅតែអាចប្រើប្រាស់បាន និងមាន ១៨,៥% ប៉ុណ្ណោះដែលថាទំរង់នេះមិនអាចប្រើប្រាស់បានទេ សំរាប់ការបោះឆ្នោតនាពេលខាងមុខ ។

ក្នុងចំណោមអ្នកមានសិទ្ធិបោះឆ្នោត មិនបានចុះឈ្មោះបោះឆ្នោត ៧៨,៨% មិនស្គាល់ពីទំរង់ ១០១៨ ១១,៤% បានលើកឡើងថា ទំរង់នេះមិនអាចប្រើប្រាស់បានទេ និង ៩,៨% និយាយថាទំរង់នេះនៅតែអាចប្រើប្រាស់បានសំរាប់ការបោះឆ្នោតនាពេលខាងមុខ ។

បើប្រៀបធៀបលទ្ធផលរវាងអ្នកចុះឈ្មោះបោះឆ្នោត និងអ្នកដែលមិនបានចុះឈ្មោះបោះឆ្នោត ភាគរយនៃអ្នកមិនបានចុះឈ្មោះបោះឆ្នោត មិនស្គាល់ពីទំរង់១០១៨ ច្រើនជាងអ្នកដែលបានចុះឈ្មោះបោះឆ្នោត។ មានន័យថាអ្នកចុះឈ្មោះបោះឆ្នោតបានទទួលព័ត៌មានច្រើនជាងពីទំរង់ ១០១៨ ។

នៅថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០១១ គជប រួមជាមួយក្រសួងមហាផ្ទៃ បានចេញសេចក្ដីណែនាំពីការប្រើប្រាស់លិខិតបញ្ជាក់អត្តសញ្ញាណសំរាប់បំរើឲ្យការបោះឆ្នោត ជំនួសទំរង់ ១០១៨ ។ ឯកសារថ្មីនេះ គឺត្រូវបានចេញឲ្យប្រជាពលរដ្ឋណាដែលមិនមានឯកសារបញ្ជាក់អត្តសញ្ញាណផ្សេងទៀត ប៉ុន្តែពួកគេមានឈ្មោះក្នុងបញ្ជីបោះឆ្នោតរួចហើយ ។

**តារាងទី ៧ អ្នកមានសិទ្ធិបោះឆ្នោតយល់ដឹងថា ទំរង់ ១០១៨អាចប្រើសំរាប់ការបោះឆ្នោតនាពេលអនាគត**

| លេខរៀង | ចម្លើយ | អ្នកផ្ដល់បទសម្ភាសន៍ | | អ្នកចុះឈ្មោះបោះឆ្នោត | | មិនបានចុះឈ្មោះបោះឆ្នោត | |
|---|---|---|---|---|---|---|---|
| | | ចំនួន | % | ចំនួន | % | ចំនួន | % |
| ១ | អាចប្រើបាន | ១៣៦៧ | ១៥,៨ | ១៣១៨ | ១៦,១ | ៤៩ | ៩,៨ |
| ២ | មិនអាចប្រើ | ១៥៦៥ | ១៨,១ | ១៥០៨ | ១៨,៥ | ៥៧ | ១១,៤ |
| ៣ | មិនស្គាល់ | ៥៧៣០ | ៦៦,២ | ៥៣៣៥ | ៦៥,៤៦ | ៣៩៥ | ៧៨,៨ |
| សរុប | | ៨៦៦២ | ១០០ | ៨១៦១ | ១០០ | ៥០១ | ១០០ |

### ៨.២.៦ អត្តសញ្ញាណប័ណ្ណដែលផុតសុពលភាព

នៅថ្ងៃទី ០១ ខែកក្កដា ឆ្នាំ ២០១១ គជប រួមជាមួយក្រសួងមហាផ្ទៃ បានចេញសេចក្ដីណែនាំក្នុងការបន្តប្រើអត្តសញ្ញាណប័ណ្ណដែលអស់សុពលភាពរហូតដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៣ សំរាប់គោលបំណងនៃការចុះឈ្មោះបោះឆ្នោត និងសំរាប់ការបោះឆ្នោត ២០១២ និង ២០១៣ ។

តារាងទី៨ បង្ហាញថា ៥៥,៣% នៃអ្នកមានសិទ្ធិបោះឆ្នោតយល់ថា អត្តសញ្ញាណប័ណ្ណដែលអស់សុពលភាពអាចប្រើសំរាប់ការបោះឆ្នោត ២០១២ និង ២០១៣ ។ ៣៧,១% នៃអ្នកមានសិទ្ធិបោះឆ្នោតនិយាយថា អត្តសញ្ញាណប័ណ្ណ ដែលអស់សុពលភាពមិនអាចប្រើប្រាស់បានទេ ជាពិសេសនោះ ៧,៥% នៃអ្នកមានសិទ្ធិបោះឆ្នោតមិនបានដឹងពីការអស់សុពលភាពនៃអត្តសញ្ញាណប័ណ្ណទេ ។

សំរាប់អ្នកបានចុះឈ្មោះបោះឆ្នោតវិញ ៥៦,៧% បានដឹងថា អត្តសញ្ញាណប័ណ្ណដែលអស់សុពលភាពអាចបន្តប្រើប្រាស់បាន ប៉ុន្តែ ៣៦,៦% បាននិយាយថា ប័ណ្ណនេះមិនអាចប្រើប្រាស់បានទេសំរាប់ការបោះឆ្នោត ២០១២ និង ២០១៣ ។ និង ៦,៨% មិនដឹងថា អត្តសញ្ញាណប័ណ្ណអស់សុពលភាពទេ ។

**តារាងទី៨ អ្នកមានសិទ្ធិបោះឆ្នោតយល់ដឹងពីអត្តសញ្ញាណប័ណអស់សុពលភាពអាចប្រើសំរាប់ការបោះឆ្នោត**

| លេខរៀង | ចម្លើយ | អ្នកផ្ដល់បទសម្ភាសន៍ | | អ្នកចុះឈ្មោះបោះឆ្នោត | | មិនបានចុះឈ្មោះបោះឆ្នោត | |
|---|---|---|---|---|---|---|---|
| | | ចំនួន | % | ចំនួន | % | ចំនួន | % |
| ១ | អាចប្រើបាន | ៤៧៨៣ | ៥៥,៣ | ៤៦១៤ | ៥៦,៧ | ២៣២ | ៤៦,៣ |
| ២ | មិនអាចប្រើ | ៣២០៩ | ៣៧,១ | ២៩៧៧ | ៣៦,៦ | ១៦៩ | ៣៣,៧ |
| ៣ | មិនស្គាល់ | ៦៥២ | ៧,៥ | ៥៥២ | ៦,៨ | ១០០ | ២០ |
| សរុប | | ៨៦៤៤ | ១០០ | ៨១៤៣ | ១០០ | ៥០១ | ១០០ |

## ៨.៣ ការពិនិត្យបញ្ជីឈ្មោះបោះឆ្នោត

### ៨.៣.១ អ្នកបានចុះឈ្មោះបោះឆ្នោតបានពិនិត្យឈ្មោះនៅក្នុងបញ្ជីឈ្មោះ ២០១០

បញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០១០ ត្រូវបានធ្វើការបិទផ្សាយនៅសាលាឃុំសង្កាត់ ដើម្បីឲ្យប្រជាពលរដ្ឋដែលបានចុះឈ្មោះហើយកាលពីឆ្នាំមុនធ្វើការពិនិត្យ និងផ្ទៀងផ្ទាត់ឈ្មោះ បើក្នុងករណីមានទិន្នន័យខុសត្រង់កន្លែងណាមួយនោះ ប្រជាពលរដ្ឋអាចជួបស្មៀនឃុំ ដើម្បីធ្វើការកែសំរួល ។

រូបភាពទី ៨ បង្ហាញថា មាន ៦២,៤% នៃអ្នកបានចុះឈ្មោះបោះឆ្នោតបានពិនិត្យ និងផ្ទៀងផ្ទាត់ឈ្មោះនៅក្នុងបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០១០។ ប៉ុន្តែ ៣៧,៦% មិនបានធ្វើការផ្ទៀងផ្ទាត់ និងពិនិត្យឈ្មោះក្នុងបញ្ជី ហើយក៏អាចធ្វើការពិចារណាបានថាក្នុងចំណោមអ្នកទាំងនេះ អាចមានអ្នកចុះឈ្មោះខ្លះមានទិន្នន័យណាមួយខុសក្នុងបញ្ជីដែលអាចប្រឈមនឹងការបោះបង់សិទ្ធិ ឬជួបបញ្ហានៅក្នុងការបោះឆ្នោតនាពេលខាងមុខ ។

**រូបភាពទី ៨ អ្នកចុះឈ្មោះបោះឆ្នោតបានពិនិត្យបញ្ជីឈ្មោះបោះឆ្នោត**




### ៨.៣.២ មូលហេតុដែលអ្នកបានចុះឈ្មោះបោះឆ្នោតមិនបានពិនិត្យឈ្មោះនៅក្នុងបញ្ជីឈ្មោះ ២០១០

រូបភាពទី ៩ បង្ហាញថា ក្នុងចំណោមអ្នកចុះឈ្មោះបោះឆ្នោតមិនបានទៅពិនិត្យឈ្មោះ មាន ៥១,៣% មិនបានពិនិត្យឈ្មោះ ឬផ្ទៀងផ្ទាត់ឈ្មោះក្នុងបញ្ជីដោយសារពួកគាត់គិតថា ឈ្មោះរបស់ពួកគាត់មានក្នុងបញ្ជីបោះឆ្នោតរួចហើយ។ ២៣,៩% មិនបានទទួលព័ត៌មានពីការចុះឈ្មោះ និងពិនិត្យបញ្ជីឈ្មោះបោះឆ្នោត និង ១៨,៧% ពួកគេមិនមានពេលគ្រប់គ្រាន់ក្នុងការពិនិត្យបញ្ជីឈ្មោះបោះឆ្នោត។

ទោះបីជាភាគរយនេះមានកំរិតទាប ប៉ុន្តែក៏គួរឲ្យកត់សំគាល់ជាមួយនឹងអ្នកដែលបានចុះឈ្មោះបោះឆ្នោត ៣,២% ប្រាប់ពីមូលហេតុដែលមិនបានទៅពិនិត្យឈ្មោះដោយសារតែមន្ត្រីចុះឈ្មោះបោះឆ្នោតមិនមានភាពរាក់ទាក់ ជាមួយគ្នានេះដែរ ២,៤% នៃអ្នកចុះឈ្មោះបោះឆ្នោតមិនបានដឹងថា ពួកគាត់អាចមានសិទ្ធិក្នុងការចូលរួមពិនិត្យបញ្ជីឈ្មោះ។

### រូបភាពទី ៩ មូលហេតុដែលមិនបានពិនិត្យឈ្មោះក្នុងបញ្ជីបោះឆ្នោត ២០១០




## ៨.៤ ភាពមិនប្រក្រត

### ៨.៤.១ អត្តសញ្ញាណប័ណ្ណត្រូវបានគេដកហូត

រូបភាពទី ១០ បង្ហាញថា ៩៥,៣% អត្តសញ្ញាណប័ណ្ណជាតិខ្មែរមិនត្រូវបានគេដកហូតទេ ប៉ុន្តែ ៤,៧% នៃអ្នកមានសិទ្ធិបោះឆ្នោតដែលអត្តសញ្ញាណប័ណ្ណត្រូវបានគេដកហូត ។ ក្នុងនោះអត្តសញ្ញាណប័ណ្ណដែលត្រូវដកហូត ភាគច្រើនដោយអាជ្ញាធរ និងក្នុងគោលបំណងសំរាប់ការចុះឈ្មោះ និងពិនិត្យបញ្ជីឈ្មោះបោះឆ្នោត។ ក្នុងចំណោមអត្តសញ្ញាណប័ណ្ណដែលត្រូវបានគេដកហូត ៦២,២% ត្រូវបានយកដោយមេភូមិ ១៤,៦% ដោយមេឃុំ ១,១% ដោយក្រុមហ៊ុនឯកជន និង ៤,៤% ដោយប៉ូលីស ។

### រូបភាពទី ១០ អត្តសញ្ញាណប័ណ្ណដែលត្រូវគេដកហូត




### ៨.៤.២ អត្តសញ្ញាណប័ណ្ណត្រូវបានគេដកហូតតាមខេត្ត

តារាងទី៩ បង្ហាញថា ខេត្តកំពង់ស្ពឺមានភាគរយខ្ពស់ជាងគេដែលអត្តសញ្ញាណប័ណ្ណជាតិខ្មែររបស់អ្នកមានសិទ្ធិបោះឆ្នោតត្រូវបានគេដក ១០,៣% ជាមួយគ្នានេះដែរ ស្ទឹងត្រែង ៩,១% និងមណ្ឌលគិរី ៧,៩% ។ ផ្ទុយទៅវិញខេត្ត តាកែវមានភាគរយទាបជាងគេដែលអត្តសញ្ញាណប័ណ្ណជាតិខ្មែរត្រូវបានគេដកហូត ។

មានការព្រួយបារម្ភដោយយោងទៅលើលទ្ធផលនៃខេត្តនីមួយៗដែលអត្តសញ្ញាណប័ណ្ណជាតិខ្មែរត្រូវបានគេដកហូត ក្នុងនោះភាគច្រើនគឺខេត្តដែលនៅជាប់ព្រំដែន បើធៀបជាមួយខេត្តដទៃទៀត ។

**តារាងទី ៩ អត្តសញ្ញាណប័ណ្ណត្រូវបានគេដកហូតតាមខេត្ត**

| រៀង លេ | ខេត្ត | អត្តសញ្ញាណប័ណ្ណត្រូវបានដកហូត | |
|---|---|---|---|
| | | ចំនួន | % |
| ១ | បន្ទាយមានជ័យ | ៧ | ១,៧ |
| ២ | បាត់ដំបង | ៤ | ១ |
| ៣ | កំពង់ចាម | ២៣ | ៥,៧ |
| ៤ | កំពង់ឆ្នាំង | ២០ | ៤,៩ |
| ៥ | កំពង់ស្ពឺ | ៤២ | ១០,៣ |
| ៦ | កំពង់ធំ | ២៤ | ៥,៩ |
| ៧ | កំពត | ៤ | ១ |
| ៨ | កណ្ដាល | ២៣ | ៥,៧ |
| ៩ | កោះកុង | ១៤ | ៣,៤ |
| ១០ | ក្រចេះ | ១១ | ២,៧ |
| ១១ | មណ្ឌលគិរី | ៣២ | ៧,៩ |
| ១២ | ភ្នំពេញ | ១៩ | ៤,៧ |
| ១៣ | ព្រះវិហារ | ២២ | ៥,៤ |
| ១៤ | ព្រៃវែង | ១ | ០,២ |
| ១៥ | ពោធិ៍សាត់ | ២២ | ៥,៤ |
| ១៦ | រតនគិរី | ១៩ | ៤,៧ |
| ១៧ | សៀមរាប | ១២ | ៣ |
| ១៨ | ព្រះសីហនុ | ៤ | ១ |
| ១៩ | ស្ទឹងត្រែង | ៣៧ | ៩,១ |
| ២០ | ស្វាយរៀង | ២២ | ៥,៤ |
| ២១ | តាកែវ | ៧ | ១,១ |
| ២២ | ឧត្តរមានជ័យ | ១៤ | ៣,៤ |
| ២៣ | កែប | ២១ | ៥,២ |
| ២៤ | ប៉ៃលិន | ២ | ០,៥ |

## ៨.៥ ភាពភ័យខ្លាច

### ៨.៥.១ ភាពភ័យខ្លាចរបស់អ្នកបោះឆ្នោត

រូបភាពទី ១១ បានបង្ហាញថា ៩៨,៩% នៃអ្នកមានសិទ្ធិបោះឆ្នោតពុំមានការភ័យខ្លាចជុំវិញការចុះឈ្មោះ និងការពិនិត្យឈ្មោះបោះឆ្នោតទេ ប៉ុន្តែមាន ១,២% បានបង្ហាញពីការព្រួយបារម្ភ ។

យោងតាមរបាយការណ៍លទ្ធផលអង្កេតស្រាវជ្រាវបញ្ជីបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោតឆ្នាំ ២០០៨ របស់ខុមហ្វ្រែលបានបង្ហាញថា ២៣,៩% នៃអ្នកផ្តល់ចម្លើយបានបង្ហាញពីការព្រួយបារម្ភអំពីសុវត្ថិភាពផ្ទាល់ខ្លួនរបស់ពួកគេ។

ទាំងនេះមានន័យថា អ្នកមានសិទ្ធិបោះឆ្នោត មានការព្រួយបារម្ភក្នុងករណីដែលលទ្ធផលនៃការបោះឆ្នោតបានបង្ហាញឲ្យដឹង និងពួកគេពុំមានការព្រួយបារម្ភនៅក្នុងកំឡុងការចុះឈ្មោះ និងពិនិត្យបញ្ជីឈ្មោះបោះឆ្នោត។

**រូបភាពទី ១១ ភាពភ័យខ្លាចរបស់អ្នកបោះឆ្នោត**




### ៨.៥.២ មូលហេតុដែលបណ្តាលឲ្យមានការភ័យខ្លាច

រូបភាពទី១២ បង្ហាញពីហេតុផលដែលអ្នកមានសិទ្ធិបោះឆ្នោតមានការភ័យខ្លាចក្នុងពេលចុះឈ្មោះ និងពិនិត្យឈ្មោះបោះឆ្នោត។ ៦៩% នៃអ្នកមានសិទ្ធិបោះឆ្នោតមានភាពភ័យខ្លាច ដោយមូលហេតុមកពីមានការព្រួយបារម្ភដោយខ្លួនឯង។ ៦% បារម្ភថាខ្លាចគេដឹងពីសមាសភាពគាំទ្រគណបក្ស និង ៣,៤% មានអារម្មណ៍ថាមានការបំភិតបំភ័យ។ ២,៦% បារម្ភថាមានអំពើហឹង្សា និងការគំរាមកំហែង និង ១៩% គឺបារម្ភពីករណីផ្សេងៗទៀត។

**រូបភាពទី ១២ មូលហេតុដែលនាំឲ្យភ័យខ្លាច**



### ៨.៥.៣ ការស្ទង់មតិស្តីពីប្រព័ន្ធចុះឈ្មោះបោះឆ្នោត

រូបភាពទី ១៣ បង្ហាញថា ៤១,៤% នៃអ្នកមានសិទ្ធិបោះឆ្នោតឲ្យអានុសាសន៍ទៅលើការធ្វើបច្ចុប្បន្នភាពនៃបញ្ជីឈ្មោះបោះឆ្នោត និង ២២,១% ចង់ឲ្យមានការផ្លាស់ប្តូរប្រព័ន្ធចុះឈ្មោះបោះឆ្នោត។ ទោះបីយ៉ាងណា ៣៦,៤% មិនបានឆ្លើយទាក់ទងទៅនឹងការធ្វើបច្ចុប្បន្នភាព និងការផ្លាស់ប្តូរប្រព័ន្ធចុះឈ្មោះបោះឆ្នោតទាំងស្រុងនោះទេ ។

រូបភាពទី ១៣ ការស្ទង់មតិពីប្រព័ន្ធចុះឈ្មោះបោះឆ្នោត




## ៨.៦ ការចូលរួមរបស់អ្នកបោះឆ្នោត

### ៨.៦.១ អ្នកបោះឆ្នោតនឹងចូលរួមបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ ២០១២

រូបភាពទី ១៤ បង្ហាញពីការចូលរួមរបស់អ្នកបោះឆ្នោតក្នុងការជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់សំរាប់ឆ្នាំ ២០១២។ ៩៨,៨% នៃអ្នកបោះឆ្នោតនឹងទៅបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០១២ ប៉ុន្តែ ១,២% នឹងមិនទៅបោះឆ្នោតទេ។

រូបភាពទី១៤ អ្នកបោះឆ្នោតចូលរួមបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ ២០១២



### ៨.៦.២ មូលហេតុដែលអ្នកបោះឆ្នោតមិនចូលរួមបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ ២០១២

តារាងទី១០ បង្ហាញពីហេតុផលដែលអ្នកបោះឆ្នោតនឹងមិនទៅបោះឆ្នោតឆ្នាំ២០១២។ ក្នុងចំណោមអ្នកមិនទៅបោះឆ្នោត ២៤,១% នៃអ្នកចុះឈ្មោះបោះឆ្នោតបានលើកឡើងថា ឈ្មោះរបស់ពួកគេមិនមាននៅក្នុងបញ្ជីបោះឆ្នោត។ ១១,៩% ខ្វះឯកសារផ្លូវការ ៨,៥% មិនបានចុះឈ្មោះបោះឆ្នោត ៦,៦% ផ្លាស់ប្តូរទីលំនៅ ៤,៤% មិនចាប់អារម្មណ៍នឹងនយោបាយ ៤,៤% មិនដឹងពីបញ្ហានយោបាយ ៥% មិនដឹងថាបោះឆ្នោតនៅពេលណា, ៣,៨% ដោយសារតែពិការ, ១,៩% គ្មានហេតុផលពិសេសណាមួយទេ, ១,៦% មិនដឹងទៅបោះឆ្នោតនៅទីណា និង ២,៨% ជឿជាក់ថាការបោះឆ្នោតមិនធ្វើឱ្យមានការផ្លាស់ប្តូរនោះទេ ។

**តារាងទី ១០ មូលហេតុដែលអ្នកបោះឆ្នោតមិនចូលរួមបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ ២០១២**

| លេខរៀង | ចម្លើយ | ចំនួន | % |
|---|---|---|---|
| ១ | មិនចាប់អារម្មណ៍ក្នុងផ្នែកនយោបាយ | ១៤ | ៤,៤ |
| ២ | ការបោះឆ្នោតរបស់ខ្ញុំមិនធ្វើឲ្យមានការផ្លាស់ប្តូរនោះទេ | ៩ | ២,៨ |
| ៣ | ខ្ញុំមិនមានការយល់ដឹងគ្រប់គ្រាន់ពីបញ្ហានយោបាយ | ១៤ | ៤,៤ |
| ៤ | មិនមានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោត | ៧៧ | ២៤,១ |
| ៥ | មិនអាចចុះឈ្មោះបាន | ២៧ | ៨,៥ |
| ៦ | មិនដឹងពីរបៀបបោះឆ្នោត | ១៣ | ៤,១ |
| ៧ | មិនដឹងពេលណាគេបោះឆ្នោត | ១៦ | ៥ |
| ៨ | មិនស្គាល់កន្លែងទៅបោះឆ្នោត | ៥ | ១,៦ |
| ៩ | ដោយសារតែខ្ញុំពិការ | ១២ | ៣,៨ |
| ១០ | មិននៅផ្ទះ ឬផ្លាស់ប្តូរទីលំនៅ | ២១ | ៦,៦ |
| ១១ | មិនមានលុយសម្រាប់ធ្វើដំណើរទៅបោះឆ្នោត | ៣ | ០,៩ |
| ១២ | គ្មានហេតុផលពិសេសណាមួយ | ៦ | ១,៩ |
| ១៣ | មិនមានឯកសារគ្រប់គ្រាន់ | ៣៨ | ១១,៩ |

## ៨.៧ ឯកសារសំរាប់ការចុះឈ្មោះបោះឆ្នោត

### ៨.៧.១ អ្នកមានសិទ្ធិបោះឆ្នោតមានអត្តសញ្ញាណប័ណ្ណជាតិខ្មែរ

រូបភាពទី១៥ បង្ហាញថា ៩២% នៃអ្នកមានសិទ្ធិបោះឆ្នោតមានអត្តសញ្ញាណប័ណ្ណជាតិខ្មែរ និង ៨% ពុំមានអត្តសញ្ញាណប័ណ្ណ ។

ក្នុងចំណោមអ្នកបានចុះឈ្មោះបោះឆ្នោត ៦,៩% មិនមានអត្តសញ្ញាណប័ណ្ណជាតិខ្មែរ និង ៩៣,១% មានអត្តសញ្ញាណជាតិខ្មែរ ។

## រូបភាពទី ១៥ អ្នកមានសិទ្ធិបោះឆ្នោតមានអត្តសញ្ញាណប័ណ្ណជាតិខ្មែរ







### ៨.៧.២ អ្នកបានចុះឈ្មោះបោះឆ្នោតប្រើប្រាស់ឯកសារសំរាប់ការចុះឈ្មោះបោះឆ្នោត

តារាងទី១១ បានបង្ហាញពីឯកសារដែលអ្នកបានចុះឈ្មោះបោះឆ្នោតបានប្រើក្នុងកំឡុងពេលចុះឈ្មោះបោះឆ្នោត។ ៨៩% នៃអ្នកចុះឈ្មោះបោះឆ្នោតបានប្រើប្រាស់អត្តសញ្ញាណប័ណ្ណ ហើយ ៣៤,៨% ប្រើសៀវភៅគ្រួសារដែលមានបិទរូបថត ។ ១៥,៤% បានប្រើសំបុត្រកំណើត, ៣,៣% ប្រើប្រាស់លិខិតបញ្ជាក់ទីលំនៅ និង ១,៦% បានប្រើប្រាស់ប័ណ្ណសំគាល់គ្រួសារផ្តល់ដោយរដ្ឋកម្ពុជា។

### តារាងទី ១១ អ្នកបានចុះឈ្មោះបោះឆ្នោតប្រើឯកសារសំរាប់ការចុះឈ្មោះបោះឆ្នោត

| លេខរៀង | ឯកសារ | ចំនួន | % |
|---|---|---|---|
| ១ | អត្តសញ្ញាណប័ណ្ណជាតិខ្មែរ | ៧២៥៣ | ៨៩ |
| ២ | លិខិតឆ្លងដែន | ១២០ | ១ |
| ៣ | សញ្ញាណប័ណ្ណមន្ត្រីរាជការស៊ីវិល | ១១៣ | ១,៤ |
| ៤ | សញ្ញាណប័ណ្ណនគរបាលជាតិ | ៣៣ | ០,៤ |
| ៥ | សុទ្ធិប័ត្រគណៈធម្មយុត្តិកនិកាយ | ៩ | ០,១ |
| ៦ | ប័ណ្ណសំគាល់គ្រួសារផ្តល់ដោយរដ្ឋកម្ពុជា | ១៩៤ | ២,៤ |
| ៧ | សំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត | ១២៥៨ | ១៥,៤ |
| ៨ | សៀវភៅគ្រួសារមានរូបថត | ២៨៣៨ | ៣៤,៨ |
| ៩ | អត្តសញ្ញាណប័ណ្ណកងយោធពលខេមរភូមិន្ទ | ២៦ | ០,៣ |
| ១០ | ប័ណ្ណសម្គាល់ខ្លួនចេញដោយក្រសួងស្ថាប័នរដ្ឋ | ៣៥ | ០,៤ |
| ១១ | ឆាយាគណៈមហានិកាយ | ៥ | ០,១ |
| ១២ | សង្ឃដីកា | ១៩ | ០,២ |
| ១៣ | លិខិតបញ្ជាក់ទីលំនៅ | ២៧០ | ៣,៣ |
| ១៤ | លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឲ្យការបោះឆ្នោត | ១០៤ | ១,៣ |
| ១៥ | ផ្សេងៗ | ១០៧ | ១,៣ |

## ៨.៨ ភាពត្រឹមត្រូវនៅក្នុងបញ្ជីបោះឆ្នោត ២០១១

### ៨.៨.១ ការផ្ទៀងផ្ទាត់ទិន្នន័យអ្នកបោះឆ្នោតនៅក្នុងបញ្ជីបោះឆ្នោត ២០១១ ធៀបនឹង បញ្ជីបោះឆ្នោត ២០០៨

ការផ្ទៀងផ្ទាត់ឯកសារអត្តសញ្ញាណអ្នកបោះឆ្នោតនេះ គឺសំដៅទៅលើការធ្វើសវនកម្មផ្ទៀងផ្ទាត់ទិន្នន័យរបស់អ្នកបោះឆ្នោត និងទិន្នន័យដែលមាននៅក្នុងបញ្ជីបោះឆ្នោតឆ្នាំ២០១១ និងធ្វើការប្រៀបធៀបទិន្នន័យនេះជាមួយបញ្ជីបោះឆ្នោតឆ្នាំ២០០៨ ។

តារាងទី១២ បង្ហាញថា ភាពមិនត្រឹមត្រូវ ២៤,៦% នៃអ្នកចុះឈ្មោះបោះឆ្នោត ដែលមានខុសព័ត៌មានយ៉ាងតិចមួយករណីនៅក្នុងបញ្ជីបោះឆ្នោតឆ្នាំ ២០១១ បើធៀបទៅនឹងបញ្ជីបោះឆ្នោតឆ្នាំ ២០០៨ មាន ២១,៨%។ ភាគរយនេះឃើញថា ភាពមិនត្រឹមត្រូវនៃបញ្ជីបោះឆ្នោតឆ្នាំ២០១១ មានការកើនឡើង បើធៀបនឹងបញ្ជីបោះឆ្នោតឆ្នាំ២០០៨ ។

ខុមហ្វ្រែលបានរកឃើញថា ១៧,២% អ្នកចុះឈ្មោះបោះឆ្នោតដែលមិនមានទិន្នន័យក្នុងបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ ២០១១ (ឈ្មោះរបស់ពួកគេមិនអាចរកឃើញ ឬ ឈ្មោះនោះបានផ្លាស់ប្តូរទាំងស្រុង) ។ ប៉ុន្តែភាគរយនេះមានកំរិតទាបជាងបើធៀបទៅនឹង ១៨,៥% ដែលអ្នកចុះឈ្មោះបោះឆ្នោតមិនមានទិន្នន័យក្នុងបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០០៨។ ទោះបីជាយ៉ាងណា ចំនួននេះ ដែលប្រហែល ១,៥ លាននាក់នៃអ្នកចុះឈ្មោះបោះឆ្នោត ដែលអាចប្រឈមនឹងការបាត់បង់សិទ្ធិនៅក្នុងការបោះឆ្នោតនាពេលខាងមុខ ។

យោងតាមរបាយការណ៍លទ្ធផលអង្កេតស្រាវជ្រាវបញ្ជីឈ្មោះបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០០៨ ដោយខុមហ្វ្រែល ឃើញថា ៤៤០,០០០ នៃអ្នកមានសិទ្ធិបោះឆ្នោត ពុំបានបោះឆ្នោតដោយសារបញ្ហាផ្សេងៗដែលច្រើនតែជាករណីដែលអ្នក បោះឆ្នោតពុំអាចរកឈ្មោះ ឬការិយាល័យបោះឆ្នោតឃើញ ។

ភាពត្រឹមត្រូវនៃបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០១១ មានភាពប្រសើរជាងបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០០៨ ប្រសិនបើគិតតែទៅលើ ថ្ងៃខែឆ្នាំកំណើត ភេទ និងអាស័យដ្ឋាន ។ ទោះបីជាយ៉ាងណាបញ្ជីនេះមានភាពត្រឹមត្រូវច្រើន ប្រសិនបើគិតតែទៅលើឈ្មោះ និងថ្ងៃខែឆ្នាំកំណើត ។

ទោះបីយ៉ាងណា បើពិនិត្យមើលទិន្នន័យ ឈ្មោះ ថ្ងៃខែឆ្នាំកំណើត និងភេទ ដោយមិនគិតពីអាស័យដ្ឋានវិញ ឃើញថាបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០០៨ មានភាពមិនត្រឹមត្រូវ ១៨,១% ធៀបនឹង ២១,៥% បញ្ជីឈ្មោះបោះឆ្នោតឆ្នាំ ២០១១។ ដោយយោងតាមនិតិវិធីរបស់ គជប បើសិនទិន្នន័យណាមួយក្នុងចំណោមទិន្នន័យទាំងបួនមានភាពមិនត្រឹមត្រូវ (ឈ្មោះ អាស័យដ្ឋាន ថ្ងៃខែឆ្នាំកំណើត និងភេទ) អ្នកបោះឆ្នោតនៅតែមានសិទ្ធិបោះឆ្នោត ។

ជាទូទៅ បញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០១១ មានភាពប្រសើរ បើធៀបជាមួយបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០០៨ ចំពោះភាគរយអ្នកចុះឈ្មោះបោះឆ្នោតមានភាពមិនប្រក្រតី (មិនមានទិន្នន័យក្នុងបញ្ជី) បានធ្លាក់ចុះ ។

ការធ្វើសវនកម្មបានរកឃើញថា ទិន្នន័យដែលមិនមានក្នុងបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០១១ ភ្នំពេញមានភាគរយខ្ពស់ជាងគេ ១២,៧% ។ រតនគិរី ៧,៦% , ឧត្តរមានជ័យ ៧,៣%, កោះកុង ៦,១% និងបាត់ដំបង ៥,៩% ។ ចំណែកឯខេត្តផ្សេងទៀតគឺភាពមិនត្រឹមត្រូវក្រោម ៥%។

សំរាប់ឆ្នាំ ២០១២ គជប បានរៀបចំបង្ហាញពីបញ្ជីឈ្មោះបោះឆ្នោតដាក់ក្នុងវែបសាយរបស់ខ្លួន ដែលនេះអាចផ្តល់ភាពងាយស្រួលដល់ម្ចាស់ឆ្នោតធ្វើការស្វែងរកឈ្មោះរបស់ខ្លួន និងទីកន្លែងបោះឆ្នោតតាមរយៈវែបសាយនេះ។ ខុមហ្វ្រែលរកឃើញករណីពិសេសចំពោះព័ត៌មានអ្នកបោះឆ្នោតមានបន្ថែមឋានៈកិត្តិយសឧទាហរណ៍ **"សម្តេច"** ភ្ជាប់ជាមួយនាមត្រកូលនៅក្នុងបញ្ជីឈ្មោះបោះឆ្នោត ២០១១ ដែលបានបង្កើត និងបង្ហាញនៅលើវែបសាយរបស់ គជប ដែលខុសពីអ្នកបោះឆ្នោតដទៃទៀត។ ដូច្នេះ គជប មានប្រតិបត្តិការពិសេសខ្លះដែលមិនមានចែងក្នុងនីតិវិធី ដោយមានអ្នកបោះឆ្នោតមានបន្ថែមទិន្នន័យ "ឋានៈ" ជាពិសេសនៅក្នុងបញ្ជីឈ្មោះបោះឆ្នោត ២០១១ ។ (សូមមើលឧបសម្ព័ន្ធ ៣ បញ្ជីឈ្មោះបោះឆ្នោត)

**តារាងទី ១២ ការផ្ទៀងផ្ទាត់ទិន្នន័យអ្នកបោះឆ្នោតនៅក្នុងបញ្ជីបោះឆ្នោត ២០១១ ធៀបនឹងបញ្ជីបោះឆ្នោត ២០០៨**

| លេ | គុណភាព បញ្ជីបោះឆ្នោត | បញ្ជីបោះឆ្នោត ២០០៨ | | | បញ្ជីបោះឆ្នោត ២០១១ | | |
|---|---|---|---|---|---|---|---|
| | | ភាពត្រឹមត្រូវ % | ភាពមិនត្រឹមត្រូវ % | គ្មានក្នុងបញ្ជី % | ភាពត្រឹមត្រូវ % | ភាពមិនត្រឹមត្រូវ % | គ្មានក្នុងបញ្ជី % |
| ១ | ឈ្មោះ | ៧៣,៣ | ៧,២ | ១៨,៥ | ៧២,៩ | ៩,៩ | ១៧,២ |
| ២ | ថ្ងៃខែឆ្នាំកំណើត | ៦៦,៤ | ១៣,៨ | ១៨,៥ | ៦៨,៥ | ១៤,៣ | ១៧,២ |
| ៣ | ភេទ | ៧៧,៩ | ០,៤ | ១៨,៥ | ៨២,៥ | ០,៣ | ១៧,២ |
| ៤ | អាស័យដ្ឋាន | ៧៤,៦ | ៥,៦ | ១៨,៥ | ៧៨,៨ | ៣,៩ | ១៧,២ |
| ៥ | % អ្នកផ្តល់ចម្លើយ | ៥៩,៧ | ២១,៨ | ១៨,៥ | ៥៨,២ | ២៤,៦ | ១៧,២ |
| ៦ | %អ្នកផ្តល់ចម្លើយ (មិនគិតអាស័យដ្ឋាន) | ៦៣,៤ | ១៨,១ | ១៨,៥ | ៦១,៣ | ២១,៥ | ១៧,២ |

## ៦. សន្និដ្ឋាន

ការសិក្សាបានបង្ហាញពីការព្រួយបារម្ភ ទាក់ទងទៅនឹងកំរិតនៃការចុះឈ្មោះបោះឆ្នោត និងភាពត្រឹមត្រូវនៃបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០១១។

ទោះបីជាភាគរយនៃអ្នកចុះឈ្មោះបោះឆ្នោតខ្ពស់ ៩៤,២% ប៉ុន្តែក៏នៅមានបន្សល់អ្នកមានសិទ្ធិបោះឆ្នោតពុំទាន់បានចុះឈ្មោះបោះឆ្នោតនៅឡើយ។ ផ្ទុយមកវិញ ប្រសិនបើការប៉ាន់ប្រមាណអ្នកមានសិទ្ធិបោះឆ្នោតសរុបឆ្នាំ ២០១១ ដោយ គជប មានភាពត្រឹមត្រូវ ចំនួនអ្នកចុះឈ្មោះបោះឆ្នោតគួរតែមានកំរិតទាបជាង ប៉ុន្តែ គជប ខ្លួនឯងបានធ្វើការចុះឈ្មោះបោះឆ្នោតឆ្នាំ២០១១ បានរហូតដល់ ១០៤% ដែលចំនួននេះអាចលើសពីការប៉ាន់ប្រមាណ អាចដោយសារតែមានបញ្ជីឈ្មោះបោះឆ្នោតមានឈ្មោះ "ឈ្មោះខ្មោច" ឬ/និង "ឈ្មោះស្ទួន" ឬម្យ៉ាងទៀតអាចមកពីបញ្ហាបច្ចេកទេសក្នុងការប៉ាន់ប្រមាណ។

ការព្រួយបារម្ភពីចំនួនអ្នកចុះឈ្មោះបោះឆ្នោតជាយុវជនមានកំរិតទាបជាងចំនួនអ្នកចុះឈ្មោះបោះឆ្នោត ដែលមានវ័យចំណាស់។ ហេតុផលទាំងនេះក៏អាចបណ្តាលមកពីខ្វះព័ត៌មាន មិនយល់ពីសារៈសំខាន់នៃការបោះឆ្នោត។ ចំណែកកំរិតនៃការអប់រំក៏អាចទាក់ទងទៅនឹងកំរិតនៃការចុះឈ្មោះបោះឆ្នោត ពីព្រោះថាអ្នកមានសិទ្ធិបោះឆ្នោតដែល មានកំរិតវប្បធម៌ទាបមិនបានទៅចុះឈ្មោះបោះឆ្នោតច្រើនជាងអ្នកដែលមានកំរិតវប្បធម៌ខ្ពស់។

ចំពោះចំណេះដឹងដែលទាក់ទងជាមួយការបោះឆ្នោត ភាគច្រើនអ្នកមានសិទ្ធិបោះឆ្នោតពុំបានដឹងពីបញ្ជីឈ្មោះបោះឆ្នោតដំបូង ជាពិសេសការប្រើប្រាស់លិខិតបញ្ជាក់អត្តសញ្ញាណសំរាប់បំរើឲ្យការបោះឆ្នោតជំនួសទំរង់១០១៨។ ដូចគ្នាដែរការប្រើប្រាស់អត្តសញ្ញាណប័ណ្ណដែលអស់សុពលភាពសំរាប់ការបោះឆ្នោតខាងមុខ ក៏ប្រជាពលរដ្ឋមិនបានដឹងពីព័ត៌មាននេះដែរ។ ទាំងនេះអាចជាចំនុចដែលគួរឲ្យព្រួយបារម្ភ បើសិនអ្នកមានសិទ្ធិបោះឆ្នោតពុំបានដឹងពីនិតិវិធី នៃការប្រើប្រាស់ឯកសារសំរាប់ការបោះឆ្នោតនោះ ប្រជាពលរដ្ឋអាចនឹងបាត់បង់សិទ្ធិសំរាប់ការបោះឆ្នោត ។

ជាមួយគ្នានេះដែរ ភាគរយនៃអ្នកចុះឈ្មោះបោះឆ្នោតដែលមានខុសព័ត៌មានយ៉ាងតិចមួយករណីដែលមាននៅក្នុងបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០១១ មានកំរិតខ្ពស់ជាងបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០០៨។ ប៉ុន្តែភាគរយអ្នកចុះឈ្មោះបោះឆ្នោតដែលទិន្នន័យមិនមាននៅក្នុងបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០១១ ១៧,២% មានកំរិតទាបជាង បញ្ជីឈ្មោះបោះឆ្នោតឆ្នាំ ២០០៨ ១៨,៥% ។ ចំនួននេះអាចប្រហែល ១,៥លាននាក់ អាចប្រឈមនឹងការបាត់បង់សិទ្ធិក្នុងការបោះឆ្នោតនាពេលខាងមុខ ។

## ឧបសម្ព័ន្ធ ១ វិធិសាស្រ្តនៃការស្រាវជ្រាវ

### ១- វិធីសាស្រ្តនៃការជ្រើសរើសការិយាល័យសំណាក (Polling Station Sample Size Method)

វិធីសាស្រ្តនៃការជ្រើសរើសសំណាក គឺយើងផ្តោតតាមវិធីសាស្រ្តរើសការិយាល័យបោះឆ្នោត ដោយផ្អែកលើការសិក្សាវិធីសាស្រ្តដែលធ្លាប់បានអនុវត្តកន្លងមកដូចជា ការសោកល្បងលទ្ធផលបោះឆ្នោត២០០៧ ការបោះឆ្នោតឆ្នាំ២០០៨ "បញ្ចូនលទ្ធផលឆ្នោតលឿន២០០៨ ហៅកាត់ថា **ភីវីធី**" និងការសិក្សាស្រាវជ្រាវបញ្ជីឈ្មោះបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោត២០០៨។

សំរាប់ឆ្នាំ២០១១ យើងត្រូវការប្រើប្រាស់នូវការិយាល័យសំណាក ចេញពីអ្នកមានសិទ្ធិបោះឆ្នោតក្នុងបញ្ជីឈ្មោះបោះឆ្នោតសំរាប់ឆ្នាំ២០១១។

**ជំហានទី១**

ការជ្រើសរើសអ្នកមានសិទ្ធិបោះឆ្នោតសំណាក យើងបានកំណត់យកមណ្ឌលចំនួន ២៤ រាជធានី/ខេត្ត ដើម្បីធ្វើកិច្ចការងារនេះ។ ដែលមានកំរិតជឿជាក់ក្នុងការវាយតំលៃ (Confidence Level) ៩៩% និងកំរិតលំអៀង (Margin of Error) ០.២%។

$$n = \frac{Nz^2 p(1-p)}{NE^2 + z^2 p(1-p)} = 397{,}435 \text{ នាក់}$$

កំណត់សំគាល់

| អក្សរតំណាង | អត្ថន័យ | តំលៃ |
|---|---|---|
| N | ចំនួនអ្នកមានសិទ្ធិបោះឆ្នោតជាតំណាង (Sample) | 397,435 |
| N | ទិន្នន័យសរុបអ្នកបោះឆ្នោតដែលមានក្នុងបញ្ជី២០១០ | 8,894,219 |
| E | កំរិតលំអៀងដែលកំណត់យក | 0.002 |
| P | ជាតំលៃ Assumed heterogeity or Variance | 0.5 |
| Z | ជាតំលៃកំរិតជឿជាក់ 99% | 2.58 |

**ជំហានទី២**

សិក្សារកចំនួនអ្នកបានចុះឈ្មោះបោះឆ្នោត ក្នុងមួយការិយាល័យជាមធ្យម ខាងក្រោមជាចំនួនការិយាល័យ និងអ្នកចុះឈ្មោះសរុបតាមមណ្ឌលនីមួយៗ ដូចខាងក្រោមៈ

| ឈ្មោះរាជធានី/ខេត្ត | សរុបលទ្ធផលបញ្ជីឈ្មោះ២០១០ | | |
|---|---|---|---|
| | ការិយាល័យ | ចុះឈ្មោះថ្មី | ចំនួនអ្នកចុះឈ្មោះក្នុងការិ. មធ្យម |
| Banteay Mean Chey | 919 | 432457 | 471 |
| Batt Dambang | 1303 | 662059 | 508 |
| Kampong Cham | 2464 | 1178148 | 478 |
| Kampong Chhnang | 659 | 299803 | 455 |
| Kampong Speu | 1025 | 465047 | 454 |
| Kampong Thom | 880 | 419136 | 476 |

| | | | |
|---|---|---|---|
| Kampot | 798 | 394355 | 494 |
| Kandal | 1427 | 760119 | 533 |
| Koh Kong | 158 | 67908 | 430 |
| Kratie | 386 | 190053 | 492 |
| Mondul Kiri | 81 | 31262 | 386 |
| Phnom Penh | 1576 | 888382 | 564 |
| Preah Vihear | 244 | 108960 | 447 |
| Prey Veng | 1555 | 754660 | 485 |
| Pursat | 607 | 260715 | 430 |
| Rattanak Kiri | 159 | 75585 | 475 |
| Siem Reap | 1105 | 548613 | 496 |
| Preah Sihanouk Ville | 230 | 117745 | 512 |
| Stung Treng | 144 | 60232 | 418 |
| Svay Rieng | 766 | 374344 | 489 |
| Takeo | 1263 | 625049 | 495 |
| Otdor Mean Chey | 240 | 120884 | 504 |
| Krong Keab | 54 | 22225 | 412 |
| Pailin | 83 | 36478 | 439 |
| **Total** | **18126** | **8894219** | **11343** |

ការសិក្សាបានបង្ហាញនូវចំនួនអ្នកមានសិទ្ធិបោះឆ្នោតសរុប ដែលតិចបំផុតក្នុងមួយការិយាល័យមាន ចំនួន ៣៨៦នាក់ ច្រើនបំផុតមានចំនួន ៥៦៤នាក់ និងជាមធ្យមក្នុងមួយការិយាល័យមានចំនួន ៤៧៣នាក់។

| តិចបំផុតក្នុងមួយការិយាល័យ | ច្រើនបំផុតក្នុងមួយការិយាល័យ | ជាមធ្យមក្នុងមួយការិយាល័យ |
|---|---|---|
| 386 | 564 | 473 |

**ជំហានទី៣**

ការសិក្សារកចំនួនការិយាល័យដែលតំណាងទិន្នន័យ (Sample) សំណាកដែលមានចំនួន ៣៩៧,៤៣៥នាក់។ នៅក្នុងជំហានទី២ ការសិក្សាមានចំនួនអ្នកចុះឈ្មោះជាមធ្យមចំនួន ៤៧៣នាក់ ដូច្នេះការគណនាការិយាល័យសំណាកគឺៈ

$$\text{ការិយាល័យសំណាក} = \frac{397,435}{473} = 840 \text{ ការិយាល័យ}$$

តាមការសិក្សាដោយសារតែកំណើនការិយាល័យមានការប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ នោះយើងសន្មត់យកទិន្នន័យជាចំនួនការិយាល័យសំណាក សំរាប់ការសិក្សាក្នុងការចុះឈ្មោះ ក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោត២០១១ ចំនួន ៨៥០ការិយាល័យសំណាក។

**ជំហានទី៤**

ការសិក្សារកកំរិតលំអៀងសំរាប់ការិយាល័យ តាមរូបមន្តដូចខាងក្រោមៈ

$$\text{ភាគរយនៃកំរិតលំអៀងការិយាល័យ} = \frac{\sqrt{p*(1-p)}}{\sqrt{n}} * z = 4.42\%$$

**ចំណាំៈ**

| អក្សរតំណាង | អត្ថន័យ | តំលៃ |
|---|---|---|
| កំរិតលំអៀងការិយាល័យ | ជាកំរិតលំអៀងនៃការិយាល័យបោះឆ្នោតដែលយកមកសិក្សាបើប្រៀបធៀបជាមួយការិយាល័យសរុប | ៤.៤២% |
| P | ជាតំលៃ Assumed heterogeity or Variance | 0.៥ |
| N | ជាការិយាល័យសំណាកដែលយកមកសិក្សា | ៨៥០ការិយាល័យ |

ដូច្នេះកំរិតលំអៀងសំរាប់ការិយាល័យសំណាកដែលយកមកសិក្សាមានកំរិតលំអៀងត្រឹមតែ ៤.៤២%។

**ជំហានទី៥**

សិក្សារកចំនួនការិយាល័យសំណាក តាមរាជធានីខេត្តនីមួយៗ។ ដោយការិយាល័យសំណាក ដែលយើងបានប្រើមានចំនួន ៨៥០ការិយាល័យ ដែលស្មើនឹង ៤.៦៩% បើធៀបនឹងការិយាល័យសរុបក្នុងបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០១១ មានចំនួន សរុប ១៨,១២៦ការិយាល័យ។

$$\textbf{ការិយាល័យសំណាក} = \frac{850}{18{,}126} = 0.0469$$

ដូចនេះការិយាល័យសំណាកដែលយើងយកមកប្រើសំរាប់សិក្សា មានចំនួន ៤.៦៩ភាគរយ នៃការិយាល័យសរុបទាំងមូល។

ដូច្នេះចំនួនការិយាល័យសំណាកតាមមណ្ឌលនិមួយៗវាជាផលគុណនៃតំលៃសមាមាត្ររវាងភាគរយនៃការិយាល័យសំណាក និងការិយាល័យតាមមណ្ឌលនិមួយៗ ដូចខាងក្រោមៈ

| ឈ្មោះរាជធានី/ខេត្ត | **ការិយាល័យសរុប** | **តំលៃសមាមាត្រ** | **ការិយាល័យសំណាក** |
|---|---|---|---|
| បន្ទាយមានជ័យ | 919 | 0.0469 | 43 |
| បាត់ដំបង | 1303 | | 61 |
| កំពង់ចាម | 2464 | | 116 |
| កំពង់ឆ្នាំង | 659 | | 31 |
| កំពង់ស្ពឺ | 1025 | | 48 |
| កំពង់ធំ | 880 | | 41 |
| កំពត | 798 | | 37 |
| កណ្ដាល | 1427 | | 67 |
| កោះកុង | 158 | | 7 |
| ក្រចេះ | 386 | | 18 |
| មណ្ឌលគិរី | 81 | | 4 |

| | | | |
|---|---|---|---|
| ភ្នំពេញ | 1576 | | 74 |
| ព្រះវិហារ | 244 | | 11 |
| ព្រៃវែង | 1555 | | 73 |
| ពោធិ៍សាត់ | 607 | | 28 |
| រតនគិរី | 159 | | 7 |
| សៀមរាប | 1105 | | 52 |
| ព្រះសីហនុ | 230 | | 11 |
| ស្ទឹងត្រែង | 144 | | 7 |
| ស្វាយរៀង | 766 | | 36 |
| តាកែវ | 1263 | | 59 |
| ឧត្តរមានជ័យ | 240 | | 11 |
| កែប | 54 | | 4 |
| ប៉ៃលិន | 83 | | 4 |
| **សរុប** | **18126** | | **850** |

## ២- វិធីសាស្ត្រនៃការជ្រើសរើសទីតាំងតាមមណ្ឌលនីមួយៗ (Station Sampling Method)

វិធីសាស្ត្រនេះដោយពឹងផ្អែកលើកម្មវិធី២ សំរាប់ធ្វើការជ្រើសរើស ដូចខាងក្រោមៈ

២.១.បញ្ចូលរាល់ការិយាល័យសរុបទាំងអស់ក្នុងមណ្ឌលនីមួយៗ ក្នុងកម្មវិធីទិន្នន័យ (Ms. Access) ដែលមានព័ត៌មានដូចជាទីតាំងរាជធានី/ខេត្ត ខណ្ឌ/ស្រុក សង្កាត់/ឃុំ លេខកូដការិយាល័យ ចំនួនអ្នកបោះឆ្នោតសរុប ម្តងមួយការិយាល័យៗ។

២.២.ព័ត៌មានការិយាល័យ ក្នុងកម្មវិធីទិន្នន័យ ត្រូវបំលែងវាទៅជាឯកសាររបស់កម្មវិធី SPSS។ បន្ទាប់មកប្រើប្រាស់កម្មវិធីវិភាគទិន្នន័យ (SPSS) ជ្រើសរើសនូវការិយាល័យសំណាកនូវចំនួនដែលត្រូវយក (ចំនួនការិយាល័យដែលត្រូវយកមើលក្នុងតារាងនៃ **ជំហានទី៥** ក្នុងជួរ**ការិយាល័យសំណាក**) ចេញពីការិយាល័យសរុបក្នុងមណ្ឌលនិមួយៗ (Random Station Sampling)។

២.៣. បន្ទាប់ពីទទួលបាននូវទីតាំង លេខកូដការិយាល័យ និងអ្នកចុះឈ្មោះសរុបក្នុងការិយាល័យ តាមចំនួនការិយាល័យ បន្ទាប់មកត្រូវបំលែងវា ទៅជាឯកសាររបស់កម្មវិធី Ms. Access វិញ។ នៅក្នុងកម្មវិធីទិន្នន័យត្រូវស្វែងរកចំនួនអ្នកបោះឆ្នោតសរុប ក្នុងការិយាល័យសំណាកដែលយើងយកមកប្រើ។

២.៤. ដោយផ្អែកលើកម្មវិធីទិន្នន័យ យើងអាចកំណត់នូវទីតាំងរាជធានីខេត្ត ខណ្ឌ/ស្រុក សង្កាត់/ឃុំ ចំនួនអ្នកបោះឆ្នោតសរុបក្នុងការិយាល័យសំណាក។

| ឈ្មោះរាជធានី/ខេត្ត | ចំនួនសរុបនៃទិន្នន័យសំណាក | | | |
|---|---|---|---|---|
| | ស្រុក/ខណ្ឌ | សង្កាត់/ឃុំ | ការិយាល័យ | អ្នកចុះឈ្មោះ |
| បន្ទាយមានជ័យ | 9 | 31 | 43 | 18561 |
| បាត់ដំបង | 14 | 45 | 61 | 27921 |
| កំពង់ចាម | 16 | 81 | 116 | 55503 |
| កំពង់ឆ្នាំង | 8 | 26 | 31 | 12519 |

| | | | | |
|---|---|---|---|---|
| កំពង់ស្ពឺ | 7 | 36 | 48 | 22704 |
| កំពង់ធំ | 8 | 34 | 41 | 17330 |
| កំពត | 7 | 32 | 37 | 19354 |
| កណ្ដាល | 11 | 50 | 67 | 38508 |
| កោះកុង | 6 | 6 | 7 | 2910 |
| ក្រចេះ | 6 | 14 | 18 | 8972 |
| មណ្ឌលគិរី | 4 | 4 | 4 | 936 |
| ភ្នំពេញ | 9 | 52 | 74 | 39918 |
| ព្រះវិហារ | 5 | 10 | 11 | 3449 |
| ព្រៃវែង | 13 | 52 | 73 | 33887 |
| ពោធិ៍សាត់ | 6 | 19 | 28 | 10626 |
| រតនគិរី | 7 | 7 | 7 | 2638 |
| សៀមរាប | 12 | 38 | 52 | 21709 |
| ព្រះសីហនុ | 4 | 8 | 11 | 4422 |
| ស្ទឹងត្រែង | 4 | 7 | 7 | 3737 |
| ស្វាយរៀង | 8 | 30 | 36 | 18797 |
| តាកែវ | 10 | 47 | 59 | 23909 |
| ឧត្តរមានជ័យ | 4 | 8 | 11 | 5452 |
| កែប | 2 | 3 | 4 | 2025 |
| ប៉ៃលិន | 2 | 4 | 4 | 1976 |
| **សរុប** | **182** | **644** | **850** | **397663** |

**៣- វិធីសាស្ត្រនៃការជ្រើសរើសចំនួនអ្នកត្រូវសម្ភាសន៍តាមមណ្ឌលនីមួយៗ** (Stratified Sampling Method)

### ៣.១. ការជ្រើសរើសអ្នកត្រូវសំភាសន៍សរុបក្នុងមណ្ឌលនីមួយៗ

ដោយផ្អែកលើចំនួនអ្នកបោះឆ្នោតក្នុងការិយាល័យសំណាក យើងមានរូបមន្តកំណត់រកចំនួនអ្នកសំភាសន៍សំណាកតាមមណ្ឌលនិមួយៗ ក្នុងកំរិតជឿជាក់ (Confidence level) 95% និងកំរិតលំអៀង (Margin of error) 5% ដូចខាងក្រោម:

$$n = \frac{NZ^2_{\alpha/2}}{4(N-1)E^2 + Z^2_{\alpha/2}}$$

| កំណត់សំគាល់ | |
|---|---|
| n | ចំនួនអ្នកសម្ភាសន៍ត្រូវយកមកសម្ភាសន៍ (Sample Size) |
| N | ទិន្នន័យអ្នកចុះឈ្មោះសរុបក្នុងការិយាល័យសំណាក |
| E | កំរិតលំអៀង ៥% |
| $Z^2_{\alpha/2}$ | មេគុណនៃរបាយទិន្នន័យធម្មតា (Coefficient of Normal Distribution) |

ខាងក្រោមនេះ ជាតារាងបង្ហាញពីទិន្នន័យអ្នកត្រូវសម្ភាសន៍តាមមណ្ឌលនិមួយៗ

| ឈ្មោះរាជធានី/ខេត្ត | ចំនួនសរុបនៃទិន្នន័យសំណាក | | | | ចំនួនសម្ភាសន៍ |
|---|---|---|---|---|---|
| | ស្រុក/ខណ្ឌ | សង្កាត់/ឃុំ | ការិយាល័យ | អ្នកចុះឈ្មោះ | |
| បន្ទាយមានជ័យ | 9 | 31 | 43 | 18561 | 376 |
| បាត់ដំបង | 14 | 45 | 61 | 27921 | 379 |
| កំពង់ចាម | 16 | 81 | 116 | 55503 | 382 |
| កំពង់ឆ្នាំង | 8 | 26 | 31 | 12519 | 373 |
| កំពង់ស្ពឺ | 7 | 36 | 48 | 22704 | 378 |
| កំពង់ធំ | 8 | 34 | 41 | 17330 | 376 |
| កំពត | 7 | 32 | 37 | 19354 | 377 |
| កណ្តាល | 11 | 50 | 67 | 38508 | 380 |
| កោះកុង | 6 | 6 | 7 | 2910 | 339 |
| ក្រចេះ | 6 | 14 | 18 | 8972 | 368 |
| មណ្ឌលគិរី | 4 | 4 | 4 | 936 | 273 |
| ភ្នំពេញ | 9 | 52 | 74 | 39918 | 381 |
| ព្រះវិហារ | 5 | 10 | 11 | 3449 | 346 |
| ព្រៃវែង | 13 | 52 | 73 | 33887 | 380 |
| ពោធិ៍សាត់ | 6 | 19 | 28 | 10626 | 371 |
| រតនគិរី | 7 | 7 | 7 | 2638 | 335 |
| សៀមរាប | 12 | 38 | 52 | 21709 | 377 |
| ព្រះសីហនុ | 4 | 8 | 11 | 4422 | 354 |
| ស្ទឹងត្រែង | 4 | 7 | 7 | 3737 | 353 |
| ស្វាយរៀង | 8 | 30 | 36 | 18797 | 376 |
| តាកែវ | 10 | 47 | 59 | 23909 | 378 |
| ឧត្តរមានជ័យ | 4 | 8 | 11 | 5452 | 359 |
| កែប | 2 | 3 | 4 | 2025 | 323 |
| ប៉ៃលិន | 2 | 4 | 4 | 1976 | 322 |
| **សរុប** | **182** | **644** | **850** | **397,663** | **8656** |

### ៣.២. វិធីសាស្ត្រជ្រើសរើសសំណាកក្នុងការិយាល័យនីមួយៗ

ក្រោយពីទទួលបានចំនួនអ្នកសំភាសន៍សរុបតាមមណ្ឌលនីមួយៗ យើងប្រើប្រាស់វិធីសាស្ត្រ Stratified Sampling Method ដើម្បីរកចំនួនអ្នកសម្ភាសន៍តាមការិយាល័យនិមួយៗ ដែលអាស្រ័យលើការចុះឈ្មោះរបស់ប្រជាពលរដ្ឋ ដែលហៅថា (Strata) ។

ខាងក្រោមនេះ ជាវិធីគណនារកចំនួនអ្នកបោះឆ្នោតតាមការិយាល័យក្នុងរាជធានីខេត្ត ដែលសមមាត្រទៅនឹងអ្នកបោះឆ្នោតសរុបការិយាល័យសំណាកក្នុងបញ្ជីឈ្មោះបោះឆ្នោត២០១១ (Proportion of the Interviewee) ។

$$n_i = n * P_i, \; (i=1,2,3,\ldots,24)$$

ni ជាចំនួនអ្នកត្រូវសម្ភាសន៍ក្នុងការិយាល័យសំណាកនិមួយៗ ដែលទទួលបានពីតំលៃសមាមាត្រ Pi

n ជាចំនួនអ្នកត្រូវសម្ភាសន៍សរុបក្នុងការិយាល័យសំណាកសរុបក្នុងមណ្ឌលនីមួយៗ ដែលបានពីការគណនា (ចំណុច៣)

Pi ជាតំលៃសមាមាត្រនៃអ្នកមានឈ្មោះបោះឆ្នោតក្នុងការិយាល័យសំណាកនិមួយៗតាមមណ្ឌល

i=1,2,3,… ជាចំនួនការិយាល័យក្នុងមណ្ឌលនិមួយៗ ដែលយកមកសិក្សា (Strata)

**<u>ចំណាំ:</u>** Pi ជាតំលៃមួយដែលយើងប្រើប្រាស់រូបមន្ត Proportion សំរាប់តំលៃសមាមាត្រតាមការិយាល័យក្នុងមណ្ឌលនិមួយៗ

$$P_i = N_i / N$$

Pi ជាតំលៃសមាមាត្រចំនួនអ្នកបោះឆ្នោតក្នុងការិយាល័យសំណាកតាមមណ្ឌលនីមួយៗ

Ni ជាចំនួនអ្នកបានចុះឈ្មោះបោះឆ្នោតសរុបតាមការិយាល័យសំណាកនិមួយៗក្នុងមណ្ឌល

N ជាចំនួនអ្នកបោះឆ្នោតសរុបក្នុងមណ្ឌលនិមួយៗ (ការិយាល័យសំណាក)

រាល់ព័ត៌មានលំអិតដែលទាក់ទងចំនួនអ្នកត្រូវសំភាសន៍ក្នុងការិយាល័យសំណាកនិមួយៗ តាមមណ្ឌលនីមួយៗ និងទីតាំងការិយាល័យ សូមមើលតារាងភ្ជាប់ជាមួយ ដែលបានសិក្សាចេញពីកម្មវិធីទិន្នន័យ (Ms. Access)។

## ៤- វិធីសាស្ត្រជ្រើសរើសអ្នកមានសិទ្ធិបោះឆ្នោតដើម្បីសម្ភាសន៍

ក្រុមការងារសម្ភាសន៍ទាំងអស់ ត្រូវតែកំណត់យកចំនួនមនុស្សមកសម្ភាសន៍ តាមចំនួនដែលបានកំណត់ក្នុងភូមិ និងត្រូវគោរព តាមគោលការណ៍។

សំរាប់វិធីសាស្ត្រក្នុងការជ្រើសរើសនេះខុមហ្វ្រែលបានប្រើប្រាស់វិធីសាស្ត្រមួយដែល ហៅថា "**ការជ្រើសរើសដោយបង្កើតប្រព័ន្ធ ចៃដន្យ** (Systematic Random Sampling Method)" ដែលមាន ៣ដំណាក់កាល ដូចខាងក្រោម:

### ៤.១. វិធីសាស្ត្រកំណត់ចំនួនខ្នងផ្ទះសំរាប់ជ្រើសរើស (Interval Scale)

ដើម្បីកំណត់យកផ្ទះដែលត្រូវសំភាសន៏ វាអាស្រ័យលើចំនួនខ្នងផ្ទះ (មួយផ្ទះមួយគ្រួសារ) ដែលមាននៅក្នុងភូមិ ដូចនេះដើម្បីជ្រើសរើសយកផ្ទះ ជាដំបូងអ្នកសម្ភាសន៍ត្រូវតែជួបជាមួយមេភូមិ ឬសមាជិកភូមិណាមួយ ដើម្បីសួរពីចំនួនគ្រួសារនៅក្នុងភូមិនេះ។ បន្ទាប់មកអ្នកត្រូវដឹងថា តើភូមិនេះត្រូវការជ្រើសរើសមនុស្សសម្ភាសន៍ប៉ុន្មាននាក់?។ ក្នុងករណីមានព័ត៌មានទាំងអស់នេះហើយ អ្នកត្រូវកំណត់ រក ចន្លោះនៃការជ្រើសរើស Interval Scale ដូចខាងក្រោម:

$$\text{Interval Scale (Int)} = \frac{N_i}{n_i}$$

Ni ជាចំនួនខ្នងផ្ទះសរុបក្នុងភូមិ

ni ជាចំនួនអ្នកត្រូវធ្វើការសម្ភាសន៍ក្នុងភូមិ

ឧទាហរណ៍: ក្នុងភូមិនេះមានចំនួន ៥០គ្រួសារ ម្យ៉ាងទៀតក្នុងភូមិនេះត្រូវការសម្ភាសន៍ ៥នាក់ ដូចនេះការរាប់ផ្ទះដើម្បីធ្វើការសម្ភាសន៍គឺ រាប់គ្រប់ ១០ផ្ទះ យកមួយ ពីព្រោះ ៥០ផ្ទះ/៥នាក់ = ១០ផ្ទះ។

ចំណាំៈ ករណីអគារមានចំនួនច្រើនជាន់ ហើយគ្រួសាររស់នៅ មានតែមួយគ្រួសារ នោះអគារច្រើនជាន់យើងគិតមួយទេ។

**៤.២. ការជ្រើសរើសផ្ទះដើម្បីចូលសម្ភាសន៍ដំបូង** (Selection of the first household)

ដើម្បីជ្រើសរើសផ្ទះដំបូង អ្នកត្រូវធ្វើការចាប់ឆ្នោតដោយចៃដន្យ (សន្លឹកឆ្នោតមានលេខ ១ ដល់លេខ ៥)។ ពេលចាប់បានលេខណាមួយ ចូរអ្នករាប់ផ្ទះពីទីតាំងដំបូងគេដែលអ្នកចាប់ផ្ដើមអង្កេតដល់ទីតាំងផ្ទះដែលជាលេខ ដែលអ្នកចាប់បាន (សន្លឹកឆ្នោត) ហើយចាត់ទុកថាផ្ទះ នោះជាផ្ទះទីមួយក្នុងការសំភាសន៍ ។ ផ្ទះដែលត្រូវសំភាសន៍បន្តទៀត គឺជាទីតាំងផ្ទះដែលអ្នកជ្រើសរើសដោយផ្លោះទៅតាមតំលៃចន្លោះ (Interval Scale) ដែលបានកំណត់ ។

**៤.៣.ការជ្រើសរើសសមាជិកគ្រួសារដើម្បីសម្ភាសន៍** (Selection the Interview in Household)

- ជំហានទី១ នៅពេលចូលដល់គ្រួសារដែលត្រូវធ្វើការសម្ភាសន៍ ជាដំបូងអ្នកត្រូវសួរឈ្មោះ សមាជិកគ្រួសារដែលមានអាយុ ចាប់ពី ១៨ឆ្នាំ ឡើង ហើយកត់ត្រាវាចូលទៅក្នុងតារាងបញ្ជី។
- ជំហានទី២ អ្នកត្រូវមើលឈ្មោះណាមួយដែលមានព្យញ្ជនៈទី១ ជាព្យញ្ជនៈដើមគេ ត្រូវយកឈ្មោះអ្នកនោះ មកសម្ភាសន៍។ តែបើសិនជាព្យញ្ជនៈទី១ ដូចគ្នា អ្នកត្រូវមើលបន្តទៅស្រៈ ឬព្យញ្ជនៈទី២ ទៀត។ បើសិនជាស្រៈ ឬព្យញ្ជនៈណាដើមគេ អ្នកត្រូវសម្ភាសន៍ អ្នកនោះ។

**ឧទាហរណ៍ជាចំណេះដឹងក្នុងការជ្រើសរើស**

នៅក្នុងភូមិ "ក" មានផ្ទះចំនួន ៦០ខ្នង។ ក្នុងភូមិនេះខ្ញុំត្រូវការសម្ភាសន៍មនុស្ស ១០នាក់។ ដូចនេះដើម្បីបានអ្នកត្រូវសម្ភាសន៍ម្នាក់ អ្នកត្រូវអនុវត្តជាជំហានៗ ដូចខាងក្រោមៈ

- ជំហានទី១ ជាដំបូងខ្ញុំគណនារកចន្លោះនៃការជ្រើសរើស (៦០ផ្ទះ/១០នាក់=០៦ផ្ទះ) ខ្ញុំទទួលបាន ០៦ផ្ទះរាប់មួយ
- ជំហានទី២ យើងមានសន្លឹកឆ្នោត ៥សន្លឹក ដែលសន្លឹកនីមួយៗសរសេរលេខ១ រហូតដល់លេខ៥ដាក់ ក្នុងហោប៉ៅ។នៅពេល នោះខ្ញុំលូកដៃចាប់យកសន្លឹកឆ្នោតដោយចៃដន្យពីក្នុងហោប៉ៅ ១សន្លឹក (ចាប់ចំលេខ៣)។
- ជំហានទី៣ ជាដំបូងខ្ញុំរាប់ផ្ទះដើមភូមិ ដែលខ្ញុំកំណត់ថាជាផ្ទះទី១ រាប់រហូតដល់ផ្ទះទី៣ ហើយខ្ញុំចូលសម្ភាសន៍សមាជិក ក្នុងផ្ទះនោះតែម្ដង។
- ជំហានទី៤ ជួបសមាជិកគ្រួសារណាមួយ រួចសួរឈ្មោះសមាជិកគ្រួសារនោះ ដោយកត់ត្រាចូលបញ្ជី "បញ្ជីឈ្មោះសមាជិក គ្រួសារ" ដូចខាងក្រោមៈ

| ល.រ | ឈ្មោះសមាជិកគ្រួសារ | ភេទ | អាយុ | អ្នកត្រូវសម្ភាសន៍ | មានវត្តមាន |
|---|---|---|---|---|---|
| ១ | ចាន់រស្មី | ប្រុស | ២០ | ☑ | ☑ |
| ២ | តារា | ប្រុស | ៣០ | ☐ | ☐ |
| ៣ | បុប្ផា | ស្រី | ២២ | ☐ | ☑ |

ការយកឈ្មោះ "ចាន់រស្មី" ដោយសារតែឈ្មោះគាត់ មានព្យញ្ជនៈនៅដើមគេ។

- ជំហានទី៥ ដោយយោងលើការគណនាក្នុងជំហានទី១ អ្នកសម្ភាសន៍ត្រូវរាប់៦ផ្ទះបន្តទៀតចាប់ពីផ្ទះអ្នកសម្ភាសន៍ទី១ ដើម្បីសម្ភាសន៍អ្នកទី២ និងធ្វើដដែលៗ រហូតគ្រប់ចំនួន ១០នាក់ ដែលត្រូវយកពីក្នុងភូមិនេះ។

## ៥. ការត្រួតពិនិត្យសកម្មភាពសម្ភាសន៍ និងប្រមូលទំរង់

នៅក្នុងពេលធ្វើការសម្ភាសន៍ ដើម្បីធ្វើការត្រួតពិនិត្យ លើសកម្មភាពការងារ យើងបានរៀបចំក្រុមត្រួតពិនិត្យដូចជាៈ ក្រុមការងារស្នាក់ការកណ្តាល ក្រុមការងារខេត្តក្រុង ប្រធានក្រុមការងារមូលដ្ឋាន។ ក្រុមទាំងនេះមានសកម្មភាព ដូចខាងក្រោមៈ

**៥.១. ប្រធានក្រុមការងារមូលដ្ឋានៈ** ចុះទៅត្រួតពិនិត្យសមជិកក្រុមរបស់ខ្លួន ដែលកំពុងធ្វើការ បន្ទាប់មកប្រមូលទំរង់សំណួរ ដែលសមាជិកក្រុមបានធ្វើហើយ យកមកត្រួតពិនិត្យមើលការបំពេញទំរង់សំណួរថាតើត្រឹមត្រូវឬអត់។ បើសិនជាការត្រួតពិនិត្យមើលឃើញថាមិនត្រឹមត្រូវទេ ត្រូវតែឱ្យសមជិកក្រុមធ្វើការសម្ភាសន៍ម្តងទៀត ឬរកវិធីដោះស្រាយតាមបញ្ហាកើតមាន។

**ចំណាំ ពេលសម្ភាសន៍ចប់** ប្រធានក្រុមការងារត្រូវតែប្រមូលទំរង់សំណួរពីសមាជិកក្រុម របស់ខ្លួនរួច និងកែឱ្យរួចរាល់ដោយបញ្ចូលឈ្មោះ និងចុះហត្ថលេខាប្រធានក្រុម និងត្រូវបញ្ជូនឈ្មោះនោះមកលេខាខេត្តក្រុង ឬអ្នកទទួលខុសត្រូវខេត្ត។

**៥.២. ក្រុមការងារខេត្តក្រុង** ៖ ត្រូវធ្វើការត្រួតពិនិត្យលើទំរង់របាយការណ៍ដែលទទួលបានពីប្រធានក្រុមការងារមូលដ្ឋានម្តងទៀត។ ការត្រួតពិនិត្យនេះជួយកាត់បន្ថយភាពមិនពេញលេញ ឬកំហុសដែលកើតឡើងពីការមិនបំពេញ ឬការមើលដោយមិន យកចិត្តទុកដាក់ពីប្រធានក្រុមការងារមូលដ្ឋាន បន្ទាប់មកទើបប្រមូលទំរង់នេះបញ្ជូនមកស្នាក់ការកណ្តាលខុមហ្វ្រែលភ្នំពេញ។

**៥.៣.ក្រុមការងារស្នាក់ការកណ្តាលៈ** រៀបចំធ្វើសកម្មភាពដូចខាងក្រោមៈ

៥.៣.១.ត្រូវទូរស័ព្ទទំនាក់ទំនងជាប្រចាំក្នុងមួយថ្ងៃ ០២ដង (ព្រឹក និងល្ងាច) ទៅប្រធានក្រុម ការងារមូលដ្ឋាន ឬលេខារាជធានីខេត្ត ដើម្បីសាកសួរពីបញ្ហាដែលកើតមាន ឬផលវិបាកផ្សេងៗ។

៥.៣.២.នៅក្នុងពេលចុះសម្ភាសន៍ ក្រុមការងារនេះអាចចុះទៅមើល ខេត្តណាមួយដែលបានចាត់តាំង ដើម្បីឱ្យទៅមើលអ្នកសម្ភាសន៍ ដើម្បីសិក្សាថាតើអ្នកសម្ភាសន៍ បំពេញកិច្ចការការត្រូវតាមវិធីសាស្ត្រ? ចំទីតាំងដែលបានកំណត់ឱ្យឬអត់? គាត់ចុះធ្វើការមែនឬអត់?។

៥.៣.៣.នៅពេលទទួលទំរង់សំណួរ ពីរាជធានីខេត្ត ក្រុមនេះត្រូវធ្វើការត្រួតពិនិត្យលើទំរង់សំណួរម្តងទៀត

## ៦.ការត្រួតពិនិត្យលើទំរង់សំណួរក្នុងកម្មវិធីបញ្ចូលទិន្នន័យ

សកម្មភាពបញ្ចូលទិន្នន័យត្រូវឆ្លងកាត់ការត្រួតពិនិត្យ និងការរើសដូចខាងក្រោមៈ

៦.១.ជ្រើសរើសអ្នកបញ្ចូលទិន្នន័យ

- អ្នកបញ្ចូលទិន្នន័យជាអ្នកដែលចេះប្រើប្រាស់កុំព្យូទ័រ កម្មវិធី Ms. Access
- អាចបញ្ចូលទិន្នន័យបាន មួយទំរង់ ក្នុងមួយរយៈពេល ៥-៧នាទី

៦.២.អ្នកបញ្ចូលត្រូវឆ្លងកាត់ការបង្រៀនពីកម្មវិធីបញ្ចូលនេះ

៦.៣.ពេលបញ្ចូលទិន្នន័យត្រូវជ្រើសរើសមនុស្ស ០២នាក់ ពីក្រុមការងារស្នាក់ការកណ្តាល ដើម្បីត្រួតពិនិត្យលើការបញ្ចូលទិន្នន័យ

៦.៤.រៀងរាល់ថ្ងៃត្រូវត្រួតពិនិត្យ ដូចខាងក្រោមៈ

-ជ្រើសរើសទិន្នន័យដែលបានបញ្ចូល ចំនួន ៥% ក្នុងមួយថ្ងៃ ដើម្បីមើល និងផ្ទៀងផ្ទាត់អ្នកបញ្ចូលថាត្រឹមត្រូវ ដែរឬទេ?

-ក្នុងពេលត្រួតពិនិត្យ បើសិនជាបានរកឃើញថា អ្នកបញ្ចូលណាម្នាក់មានកំហុសក្នុង ៥% ដំបូង ពេលនោះត្រូវជ្រើសរើស ទិន្នន័យអ្នកបញ្ចូលនោះចំនួន ៥% បន្ថែមទៀត ដើម្បីមើល។ ក្នុងករណីកំហុសកើតឡើងលើសពី ៥% ត្រូវមើលឡើងវិញ ទាំងអស់។

៦.៥.ក្រោយពេលបញ្ចូលចប់ទាំងអស់ត្រូវមើល ទិន្នន័យ ៥% ឡើងវិញទៀតដើម្បីឱ្យប្រាកដថា ទិន្នន័យដែលបានបញ្ចូល មានគុណ ភាពល្អ និងវិភាគអាចទទួលយកបាន ។

## ៧.វិធិសាស្រ្តវិភាគទិន្នន័យ

នៅក្នុងការវិភាគ យើងបានប្រើប្រាស់នូវវិធីសាស្រ្តស្ថិតិមួយចំនួន តាមតារាងដែលត្រូវវិភាគ ដូចខាងក្រោមៈ

៧.១.សិក្សារកភាគរយនៃទិន្ន័យសំរាប់វិភាគ ដោយប្រើ Analyze Descriptive Frequency។ ឧទាហរណ៍ៈ តើមានអ្នកមានសិទ្ធិបោះឆ្នោត ទៅចុះឈ្មោះបោះឆ្នោតប៉ុន្មាននាក់ (សំណួរទី១)។

៧.២.សិក្សាប្រៀបធៀបទិន្នន័យតាមផ្នែកផ្សេងៗគ្នានៃចំលើយ ដោយប្រើប្រាស់ Model Crosstab by layer សំរាប់វិភាគចំលើយ។ ក្នុងនោះយើងបានសិក្សាលើតារាងរបស់ Model crosstab layer ដើម្បីចង់ដឹងថាអ្នកទៅចុះឈ្មោះបោះឆ្នោត និងមិនទៅចុះឈ្មោះបោះឆ្នោត (សំណួរទី៨) ជាមួយខេត្តរាជធានីនិមួយៗ (សំណួរទី៣) តើស្ត្រីនិងបុរសមានចំនួនភាគរយដូចគ្នាដែរឬទេ? (សំណួរទី១)។

៧.៣.ការប្រើប្រាស់វិធីសាស្រ្តរកទំនាក់ទំនងនៃចំលើយដែលជា ចំលើយបែបគុណភាព (Quality answer) តាមរយៈ Crosstab data ជាមួយ Model Chi-square ដើម្បីសិក្សាពី **កំរិតប្រែប្រួល** របស់វា ថាតើវាអាស្រ័យគ្នាដែរឬទេ។ នៅក្នុងគំរោងស្រាវជ្រាវ យើងចង់ដឹងថា តើមុខរបររបស់អ្នកមានសិទ្ធិបោះឆ្នោត (សំណួរទី៧) វាពិតជាហេតុផលដែលធ្វើឲ្យអ្នកមានសិទ្ធិបោះឆ្នោតទៅ ឬមិនទៅ ចុះឈ្មោះបោះឆ្នោតមែនឬទេ?។

៧.៤.ការសិក្សា និងប្រើប្រាស់ Log-linear សំរាប់សិក្សារកភាពបំរែបំរួលនៃអាញ្ញត្តិ (Varible) ជាច្រើន ថាតើវាមានទំនាក់ទំនងរវាង គ្នាដែរឬទេ និងដើម្បីងាយស្រួលកសាងតារាងលទ្ធផលថ្មីមួយដែលមានទំនាក់ទំនងអាចជឿជាក់សំរាប់វិភាគរបាយការណ៍។ ក្នុងគំរោងស្រាវជ្រាវនេះ យើងបាន សិក្សាលើសំណួរមួយចំនួនដើម្បីមើលភាពបំរែបំរួលនៃទំនាក់ទំនងរបស់វា ថាតើការលំបាករបស់ប្រជាពលរដ្ឋក្នុងការទៅពិនិត្យបញ្ជីឈ្មោះបោះឆ្នោតជារៀងរាល់ឆ្នាំ (សំណួរទី៣១) ស្ត្រីឬបុរស (សំណួរទី២) ក្មេងឬចាស់ (សំណួរទី១) មានការលំបាកដូចម្តេចដែរ បើប្រៀបធៀបតាមខេត្តរាជធានីនិមួយៗ (សំណួរទី៣)។

**ឧបសម្ព័ន្ធ ២ គម្រូវសំនួរសម្រាប់ការអង្កេត**

**គណៈកម្មាធិការដើម្បីការបោះឆ្នោត ដោយសេរី និងយុត្តិធម៌នៅកម្ពុជា**

***សហការជាមួយ KYA, NICFEC និង PDP-Center***

ខុមហ្វ្រែល COMFREL

# ផ្នែកទី១ ទម្រង់ស្រាវជ្រាវអំពីបញ្ជីឈ្មោះបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោត

| | | | |
|---|---|---|---|
| ឈ្មោះអ្នកទៅសម្ភាសន៍: | | ហត្ថលេខាអ្នកទៅសម្ភាសន៍: | |
| ទីតាំងអ្នកត្រូវសម្ភាសន៍ ភូមិ: | | ឃុំ-សង្កាត់: | |
| ក្រុង-ស្រុក-ខណ្ឌ: | | រាជធានី-ខេត្ត: | |
| ថ្ងៃ/ខែ/ឆ្នាំ បំពេញទម្រង់: | ថ្ងៃ ខែ ឆ្នាំ ២០១១ | ពេលវេលាចាប់ផ្តើម និងបញ្ចប់: | |
| ឈ្មោះប្រធានក្រុមការងារ: | | ហត្ថលេខាប្រធានក្រុមការងារ: | |
| ឈ្មោះអ្នកត្រួតពិនិត្យថ្នាក់ខេត្ត: | | ហត្ថលេខាអ្នកត្រួតពិនិត្យថ្នាក់ខេត្ត: | |

## I. ព័ត៌មានស្តីពីប្រជាសាស្ត្រ

១. ភេទអ្នកផ្តល់បទសម្ភាសន៍ (អ្នកសម្ភាសន៍ត្រូវមើលជាក់ស្តែង)

☐ ស្រី ☐ ប្រុស

២. តើអ្នកមានអាយុប៉ុន្មាន?……………………ឆ្នាំ(អ្នកសម្ភាសន៍ត្រូវសួរជាក់ស្តែង)

៣. ទីកន្លែងកំណើត ភូមិ......................ឃុំ/សង្កាត់......................ស្រុក/ខណ្ឌ......................ខេត្ត/រាជធានី.....................។

៤. ជនជាតិដើម និងភាសាកំណើត........................ (១=ខ្មែរ, ២=ចិន, ៣=ចាម, ៤=វៀតណាម ៥=ផ្សេងៗ....................)

៥. តើអ្នកចេះអាន និង/ឬចេះសរសេរភាសាខ្មែរដែរឬទេ? (ចម្លើយមានតែ១)

☐ ចេះអាន ☐ ចេះសរសេរ ☐ មិនចេះអាន និងសរសេរ(រំលងទី៦) ☐ បដិសេធន៍ឆ្លើយ

៦. តើអ្នកបានសិក្សាដល់កំរិតណា? (ចម្លើយមានតែ ១)

| | | | |
|---|---|---|---|
| ☐ | មិនដែលបានទៅរៀនសោះ | ☐ | ឧត្តមសិក្សា |
| ☐ | កំរិតបឋមសិក្សា (ថ្នាក់ទី ១-៦) | ☐ | ក្រោយ ឧត្តមសិក្សា |
| ☐ | កំរិតអនុវិទ្យាល័យ (ថ្នាក់ទី ៧-៩) | ☐ | អប់រំក្រៅប្រព័ន្ធ |
| ☐ | កំរិតវិទ្យាល័យ (ថ្នាក់ទី ១០-១២) | ☐ | បដិសេធន៍ឆ្លើយ |

៧. តើអ្នកប្រកបមុខរបរ (មុខរបរចុងក្រោយ) អ្វីដែរ ក្នុងរយៈពេលមួយឆ្នាំចុងក្រោយនេះ? (ចម្លើយមានច្រើន)

| | | | |
|---|---|---|---|
| ☐ | រកស៊ីខ្លួនឯង (រាប់បញ្ចូលទាំង កសិករ អ្នកចំការ អ្នកនេសាទ និងអ្នករត់ម៉ូតូឌុប) | ☐ | ការងារមានមានប្រាក់ខែនៅក្នុងវិស័យឯកជនមិនមែនកសិកម្ម (ឧស្សាហកម្ម សេវាកម្ម ។ល។) |
| ☐ | ការងារមានប្រាក់ខែ នៅក្នុងវិស័យកសិកម្មឯកជន | ☐ | ការងារមានប្រាក់ខែនៅក្នុងក្របខណ្ឌរដ្ឋ (រដ្ឋបាលសាធារណៈ) |
| ☐ | កម្មកររកចំណូលប្រចាំថ្ងៃក្នុង វិស័យកសិកម្ម/រុក្ខាប្រមាញ់/នេសាទ | ☐ | កម្មកររកចំណូលប្រចាំថ្ងៃ ក្នុងវិស័យឧស្សាហកម្ម សេវាកម្ម ។ល។ |

| | | | |
|---|---|---|---|
| ☐ | ការងារមានប្រាក់ខែនៅអង្គការមិនមែនរដ្ឋាភិបាល សមាគម ឬសហគមន៍ | ☐ | មិនមានការងារធ្វើទេក្នុងរយៈ១ឆ្នាំចុងក្រោយនេះ |
| ☐ | ជំនួញលក្ខណៈគ្រួសារ | ☐ | បដិសេធឆ្លើយ |
| ☐ | ផ្សេងៗ (សូមបញ្ជាក់)៖______ | | |

## II. ការចុះឈ្មោះបោះឆ្នោត

ការធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះប្រចាំឆ្នាំ២០១១

៨. តើអ្នកធ្លាប់បានទៅចុះឈ្មោះបោះឆ្នោតដែរឬទេ?

☐ ធ្លាប់បានទៅ (រំលងសំណួរទី៩) ☐ មិនបានទៅ

៩. តើមកពីមូលហេតុអ្វី បានជាអ្នកមិនទៅចុះឈ្មោះបោះឆ្នោត? (ចម្លើយមានច្រើន រំលងសំណួរពីទី១០ ដល់ ២៩)

| | | | |
|---|---|---|---|
| ☐ | មិនមានព័ត៌មានពីការពិនិត្យបញ្ជីឈ្មោះ និង ចុះឈ្មោះអ្នកបោះឆ្នោត | ☐ | មិនមានឯកសារគ្រាប់គ្រាន់ |
| ☐ | ធុញនឹងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត | ☐ | ការិយាល័យចុះឈ្មោះនៅឆ្ងាយពេក |
| ☐ | ទីកន្លែងចុះឈ្មោះ មិនបង្កលក្ខណៈងាយស្រួល | ☐ | ខ្ញុំត្រូវបានគេរាំងមិនឲ្យទៅពិនិត្យ និងចុះឈ្មោះ |
| ☐ | ព្រោះធ្លាប់មានឈ្មោះក្នុងបញ្ជីអ្នកបោះឆ្នោតម្តងហើយ | ☐ | មិនមានពេលគ្រប់គ្រាន់ ក្នុងការចុះ ឈ្មោះ/ផ្ទៀងផ្ទាត់ឈ្មោះ |
| ☐ | កាលនោះខ្ញុំឈឺ | ☐ | ខ្ញុំមិនបានដឹងថា មានសិទ្ធិចូលរួម |
| ☐ | ទើបតែផ្លាស់ប្តូរទីលំនៅថ្មី | ☐ | អត់លុយ |
| ☐ | បង្កឧបសគ្គ ដោយប្រកាន់គណបក្សនយោបាយ | ☐ | បដិសេធឆ្លើយ |

សូមបញ្ជាក់បន្ថែមករណី បង្កឧបសគ្គ ឬរាំងមិនឲ្យទៅចុះឈ្មោះ ..................................................................................... ..................................................................................................................។

៩ក. តើអ្នកមានឈ្មោះបោះឆ្នោតក្នុងបញ្ជីឈ្មោះ ដោយមិនបានទៅចុះឈ្មោះដោយខ្លួនឯងដែរទេ?

☐ មាន ☐ មិនមែនទេ

បើមានតើអ្នកណាជាអ្នកចុះឈ្មោះអោយ..........................................................................................។

១០. បើបានចុះឈ្មោះ តើអ្នកទៅចុះឈ្មោះបោះឆ្នោតចុងក្រោយបំផុតតាំងពីឆ្នាំណា?

| | | | |
|---|---|---|---|
| ☐ | ឆ្នាំ២០១១ (ខ្ញុំទើបចុះឈ្មោះថ្មី)(សួរបន្តរហូតដល់សំណួរទី១៧ ហើយ រំលងពីសំណួរទី១៨ រហូតដល់ទី២៦) | ☐ | ឆ្នាំ២០០៨ |
| ☐ | ឆ្នាំ២០១០ | ☐ | មុនឆ្នាំ២០០៨ |
| ☐ | ឆ្នាំ២០០៩ | | |

១១. តើអ្នកចុះឈ្មោះនៅក្នុងឃុំ សង្កាត់ ដែលអ្នកកំពុងរស់នៅនេះមែនឬទេ?

☐ មែន (រំលងសំណួរទី១២) ☐ មិនមែនទេ

១២. បើមិនមែនទេ សូមបញ្ជាក់ទីកន្លែងដែលបានចុះភូមិ..............ឃុំ................ស្រុក.................រាជធានី/ខេត្ត................

១៣. បើសិនជាអ្នកបានទៅចុះឈ្មោះបោះឆ្នោត តើស្មៀនបានចុះឈ្មោះឲ្យដែរឬទេ?

☐ បានចុះឈ្មោះ (រំលងសំណួរទី១៤) ☐ មិនបានចុះឈ្មោះទេ

១៤. តើមកពីមូលហេតុអ្វី បានជាស្មៀនមិនបានចុះឈ្មោះបោះឆ្នោតឲ្យ? (ចម្លើយមានច្រើន)

| | | | |
|---|---|---|---|
| ☐ | ព្រោះធ្លាប់មានឈ្មោះក្នុងបញ្ជីអ្នកបោះឆ្នោតម្តងហើយ | ☐ | មិនមានឯកសារគ្រាប់គ្រាន់ |
| ☐ | ទើបតែផ្លាស់ប្តូរទីលំនៅថ្មី | ☐ | អត់លុយ |
| ☐ | បង្កឧបសគ្គ ដោយប្រកាន់គណបក្សនយោបាយ | ☐ | បដិសេធឆ្លើយ |

សូមបញ្ជាក់បន្ថែមករណី បង្កឧបសគ្គ ឬរាំងមិនឲ្យចុះឈ្មោះ ..............................................................................................................................................................................................................................................................។

១៥. តើអ្នកមានផលលំបាកកំរិតណា ក្នុងការទៅចុះឈ្មោះបោះឆ្នោតកន្លងទៅ?

| មានផលលំបាកខ្លាំងណាស់ | មានផលលំបាកច្រើន | លំបាក | មិនសូវលំបាក | មិនលំបាកទាល់តែសោះ (រំលងសំណួរទី១៦) |
|---|---|---|---|---|
| ☐ | ☐ | ☐ | ☐ | ☐ |

១៦. បើសិនជាមានផលលំបាក តើផលលំបាកនោះជាអ្វី? (អាចជ្រើសរើសបានច្រើន)

| | | | |
|---|---|---|---|
| ☐ | ពិបាកធ្វើដំណើរព្រោះកន្លែងនៅឆ្ងាយពេក | ☐ | រង់ចាំរយៈពេលដ៏យូរក្នុងការចុះឈ្មោះ |
| ☐ | ជាប់រវល់ការងារ ពិបាកក្នុងការទៅពិនិត្យ ឬចុះឈ្មោះ | ☐ | សេវាកម្មនៅកន្លែងបោះឆ្នោតមិនបង្ក លក្ខណៈងាយស្រួល និងរាក់ទាក់ |
| ☐ | មានការគំរាមកំហែង និងរំខានមិនឲ្យទៅចុះឈ្មោះ | ☐ | មិនចេះអាន/សរសេរ |
| ☐ | ចំពេលខ្លួនមានជំងឺ | ☐ | ខ្លួនជាជនពិការ |
| ☐ | ផ្សេងៗ (សូមបញ្ជាក់)៖.................................................................................................................................. | | |

១៧. តើឯកសារសំគាល់អត្តសញ្ញាណណាមួយ ដែលអ្នកប្រើសម្រាប់ចុះឈ្មោះបោះឆ្នោត? (ចម្លើយលើសពី១)

| | | | |
|---|---|---|---|
| ☐ | អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ | ☐ | សៀវភៅគ្រួសារមានរូបថត |
| ☐ | លិខិតឆ្លងដែន | ☐ | អត្តសញ្ញាណប័ណ្ណកងយោធពលខេមរភូមិន្ទ |
| ☐ | អត្តសញ្ញាណប័ណ្ណមន្ត្រីរាជការស៊ីវិល | ☐ | ប័ណ្ណសម្គាល់ខ្លួនចេញដោយក្រសួងស្ថាប័នរដ្ឋ |
| ☐ | អត្តសញ្ញាណប័ណ្ណនគរបាលជាតិ | ☐ | ឆាយាគណៈមហានិកាយ |
| ☐ | សុទ្ធិប័ត្រគណៈធម្មយុត្តិកនិកាយ | ☐ | សង្ឃដីកា |
| ☐ | ប័ណ្ណសំគាល់គ្រួសារផ្តល់ដោយរដ្ឋកម្ពុជា | ☐ | លិខិតបញ្ជាក់ទីលំនៅ |
| ☐ | សំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត | ☐ | លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឲ្យការបោះឆ្នោត |
| ☐ | ផ្សេងៗ សូមបញ្ជាក់: ______________________________________________ | | |

១៨. តើអ្នកបានទៅពិនិត្យបញ្ជីឈ្មោះចុងក្រោយឆ្នាំ២០១០ កាលពីកំឡុងចុងខែសីហា ដល់ តុលា ឆ្នាំ២០១១ កន្លងមកដែរឬទេ?

☐ បាន(រំលងសំណួរទី១៩) ☐ មិនបាន

១៩. បើមិនបាន តើមកពីមូលហេតុអ្វី បានជាអ្នកមិនទៅមើលបញ្ជីឈ្មោះចុងក្រោយឆ្នាំ២០១០? (ចម្លើយមានច្រើន រំលងសំណួរទី២០,២១,២២,២៣,២៤,២៥,២៦)

| | | | |
|---|---|---|---|
| ☐ | មិនមានព័ត៌មានពីការពិនិត្យបញ្ជីឈ្មោះ និង ចុះឈ្មោះអ្នកបោះឆ្នោត | | ការិយាល័យចុះឈ្មោះនៅឆ្ងាយពេក |
| ☐ | ធុញនឹងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត | ☐ | ខ្ញុំត្រូវបានគេរាំងមិនឲ្យទៅពិនិត្យ និងចុះឈ្មោះ |
| ☐ | ទីកន្លែងចុះឈ្មោះ មិនបង្កលក្ខណៈងាយស្រួល | ☐ | មិនមានពេលគ្រប់គ្រាន់ក្នុងការចុះ ឈ្មោះ/ផ្ទៀងផ្ទាត់ |

| | | | |
|---|---|---|---|
| | | | ឈ្មោះ |
| ☐ | ព្រោះធ្លាប់មានឈ្មោះក្នុងបញ្ជីអ្នកបោះឆ្នោតម្តងហើយ | ☐ | ខ្ញុំមិនបានដឹងថា មានសិទ្ធិចូលរួម |
| ☐ | កាលនោះខ្ញុំឈឺ | ☐ | អត់លុយ |
| ☐ | ផ្លាស់ប្តូរទីលំនៅ | ☐ | បដិសេធឆ្លើយ |
| ☐ | បង្កឧបសគ្គ ដោយប្រកាន់គណបក្សនយោបាយ (សូមសរសេរបញ្ជាក់បន្ថែមខាងក្រោម) | | |

សូមបញ្ជាក់បន្ថែមករណីបង្កឧបសគ្គឬរាំងមិនឲ្យទៅពិនិត្យនិងផ្ទៀងផ្ទាត់ឈ្មោះ..................................................................
....................................................................................................................................................។

២០. បើបានទៅពិនិត្យឈ្មោះ តើទិន្នន័យ (ឈ្មោះ, ភេទ, ថ្ងៃខែឆ្នាំកំណើត...) របស់អ្នកក្នុងបញ្ជីឈ្មោះបោះឆ្នោតនោះ ត្រឹមត្រូវដែរឬទេ?

☐ ត្រឹមត្រូវ (រំលងសំណួរទី២១,២២,២៣,២៤,២៥) ☐ មិនត្រឹមត្រូវទេ

២១. បើមិនត្រឹមត្រូវ សូមបញ្ជាក់ថាតើខុសទិន្នន័យណាខ្លះខាងក្រោមនេះ (ចម្លើយមានច្រើន)៖

| | | | |
|---|---|---|---|
| ☐ | ឈ្មោះ | ☐ | ថ្ងៃខែឆ្នាំកំណើត |
| ☐ | ភេទ | ☐ | អាសយដ្ឋានបច្ចុប្បន្ន |
| ☐ | ផ្សេងៗ (សូមបញ្ជាក់)..................................................................។ | | |

២២. បើសិនមិនត្រឹមត្រូវ តើអ្នកបានស្នើឲ្យមន្ត្រីចុះឈ្មោះបោះឆ្នោតធ្វើការកែតម្រូវឲ្យដែរឬទេ?

☐ បានស្នើ (រំលងសំណួរទី២៣) ☐ មិនបានស្នើ

២៣. បើមិនបានស្នើឲ្យកែតម្រូវ តើមកពីមូលហេតុអ្វី? (រំលងសំណួរទី២៤,២៥)

| | | | |
|---|---|---|---|
| ☐ | មិនដឹងថាខ្លួនមានសិទ្ធិ | ☐ | មិនដឹងពីរបៀបកែតម្រូវ |
| ☐ | អត់ជួបមន្ត្រី | ☐ | អត់មានឯកសារអះអាង |
| ☐ | ផ្សេងៗ (សូមបញ្ជាក់)..................................................................។ | | |

២៤. បើបានស្នើឲ្យកែតម្រូវ តើមន្ត្រីនោះបានធ្វើការកែតម្រូវដែរទេ?

☐ បានធ្វើការកែតម្រូវ (រំលងសំណួរទី២៥ ) ☐ មិនបានធ្វើការកែតម្រូវ

២៥. បើមិនបានធ្វើការកែតម្រូវ សូមបញ្ជាក់ពីមូលហេតុដូចខាងក្រោម (ចម្លើយលើសពីមួយ)៖

| | | | |
|---|---|---|---|
| ☐ | មន្ត្រីនោះប្រាប់ថាមិនមានឯកសារសំអាងគ្រប់គ្រាន់ | ☐ | មានការរើសអើងនិន្នាការនយោបាយ |
| ☐ | មន្ត្រីចុះឈ្មោះមិនមានពេលវេលាកែតម្រូវឲ្យ | ☐ | មន្ត្រីថាខុសតិចតួចក៏អាចបោះឆ្នោតបាន |
| ☐ | ផ្សេងៗ (សូមបញ្ជាក់)..................................................................។ | | |

២៦. តើទីតាំងការិយាល័យបោះឆ្នោតរបស់អ្នកត្រូវបានផ្លាស់ប្តូរដែរទេ? (សម្រាប់អ្នកចុះឈ្មោះបោះឆ្នោតមុនឆ្នាំ២០១១)

☐ បានផ្លាស់ប្តូរ ☐ មិនបានផ្លាស់ប្តូរទេ

២៧. អ្នកដឹងថា តើអ្វីជាបញ្ជីឈ្មោះបោះឆ្នោតដំបូង ដែរឬទេ?

☐ ដឹង ☐ មិនដឹងទេ (រំលងសំណួរទី២៨, ២៩)

២៨. បើដឹង តើគេបិទបញ្ជីឈ្មោះបោះឆ្នោតដំបូងដើម្បីអ្វី? (ចម្លើយលើសពីមួយ)

| | | | |
|---|---|---|---|
| ☐ | ដើម្បីផ្ទៀងផ្ទាត់ឈ្មោះចុងក្រោយ | ☐ | ដើម្បីឲ្យមានការប្តឹងតវ៉ា (ករណីខុសឈ្មោះ) ឬប្តឹងជំទាស់ |
| ☐ | ផ្សេងៗ (សូមបញ្ជាក់)..................................................................។ | | |

២៩. បើដឹង តើគេបិទនៅពេលណា? (ចម្លើយមានតែមួយ)

| | | | | | |
|---|---|---|---|---|---|
| ☐ | ក្រោយពេលចុះឈ្មោះថ្ងៃទី ១៩ តុលា ២០១១ | ☐ | បិទមុន ឬក្នុងកំឡុងពេលចុះឈ្មោះ | ☐ | មិនដឹង |
| ☐ | ផ្សេងៗ (សូមបញ្ជាក់)…………………………………………………………………………..។ | | | | |

៣០. តើអ្នកបានទទួលព័ត៌មានពីការចុះឈ្មោះបោះឆ្នោតពីប្រភពណាដែរ? (ចម្លើយមានច្រើន)

| | | | |
|---|---|---|---|
| ☐ | វិទ្យុ/ទូរទស្សន៍ | ☐ | អ្នកជិតខាង/សមាជិកសហគមន៍ គ្រួសារ/មិត្តភ័ក្តិ |
| ☐ | គណបក្សនយោបាយ | ☐ | ការចុះបង្រៀន និងផ្សព្វផ្សាយពីមន្ត្រីមូលដ្ឋាន |
| ☐ | កាសែត/ខិត្តប័ណ្ណ/រូបភាពផ្ទាំងធំ (poster) | ☐ | មេភូមិ |
| ☐ | ខ្ញុំមិនបានទទួលព័ត៌មានអ្វីទាំងអស់ពីដំណើរការ នៃការបោះឆ្នោត | ☐ | អាជ្ញាធរ |
| ☐ | វេទិកាសាធារណៈរបស់អង្គការសង្គមស៊ីវិល | ☐ | បដិសេធឆ្លើយ |
| ☐ | ការចាក់ផ្សាយតាមមេក្រូ | | |
| ☐ | ផ្សេងៗ (សូមបញ្ជាក់)៖.......................................................................................................................។ | | |

៣១. តើអ្នកយល់យ៉ាងដូចម្តេច ចំពោះការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ជារៀងរាល់ឆ្នាំ?

| លំបាក | មិនលំបាក (រំលងសំណួរទី៣២,៣៣) | គ្មានយោបល់ (រំលងសំណួរទី៣២,៣៣) |
|---|---|---|
| ☐ | ☐ | ☐ |

៣២. បើលំបាក តើចាំបាច់ធ្វើការផ្លាស់ប្តូរ ឬកែលំអ ដែរឬទេ?

☐ ☐ ចាំបាច់ ☐ មិនចាំបាច់ ☐ មិនដឹង

៣៣. បើចាំបាច់ធ្វើការផ្លាស់ប្តូរ ឬ កែលំអ សូមជ្រើសរើសចំលើយណាមួយខាងក្រោម (ចម្លើយមានតែមួយ)

| | | | |
|---|---|---|---|
| ☐ | កែលំអលើបញ្ជីបោះឆ្នោតបច្ចុប្បន្ន | ☐ | ផ្លាស់ប្តូរបញ្ជីបោះឆ្នោតទាំងស្រុង មានន័យថាដូរប្រព័ន្ធចុះឈ្មោះបោះឆ្នោត |
| ☐ | ផ្សេងៗ.......................................................................................................................។ | | |

៣៤. តើអ្នកមានអារម្មណ៍យ៉ាងដូចម្តេច ក្នុងកំឡុងពេលចុះឈ្មោះ និងក្រោយការចុះឈ្មោះបោះឆ្នោតឆ្នាំ២០១១នេះ។

☐ ភ័យខ្លាច ☐ គ្មានភ័យខ្លាចអ្វីទេ (រំលងសំណួរទី៣៥)

៣៥. បើសិនជាមានការភ័យខ្លាច តើមកពីមូលហេតុអ្វី? (ចម្លើយមានតែមួយ)

| | | | |
|---|---|---|---|
| ☐ | ដោយមានការបំភិតបំភ័យ | ☐ | អំពើហឹង្សា និងការគំរាមកំហែង |
| ☐ | ដឹងពីសមាសភាពខ្ញុំគាំទ្រគណបក្ស | ☐ | ចេះតែព្រួយបារម្ភណ៍ខ្លួនឯង |
| ☐ | ផ្សេងៗ.......................................................................................................................។ | | |

***<u>ឯកសារបញ្ជាក់អត្តសញ្ញាណ</u>***

៣៦. តើអ្នកដឹងថាត្រូវបំពេញលក្ខខណ្ឌអ្វីខ្លះ ដើម្បីឲ្យអ្នកមានសិទ្ធិទៅចុះឈ្មោះបោះឆ្នោតបាន? (ចម្លើយមានច្រើន)

| | | | |
|---|---|---|---|
| ☐ | អាយុចាប់ពី ១៨ ឆ្នាំ ឡើងទៅ | ☐ | ជាជនមិនវិកលចរិត ឬស្ថិតក្រោមអាណាព្យាបាល |
| ☐ | ត្រូវមានសញ្ជាតិខ្មែរ | ☐ | អ្នកមិនស្ថិតក្នុងស្ថានភាពជាប់ពន្ធនាគារ |
| ☐ | មានអាសយដ្ឋានក្នុងឃុំសង្កាត់ដែលខ្លួនរស់នៅ | ☐ | ខ្ញុំអត់ដឹង |
| ☐ | មានឯកសារបញ្ជាក់អត្តសញ្ញាណ | ☐ | បដិសេធឆ្លើយ |
| ☐ | ផ្សេងៗ (សូមបញ្ជាក់)៖ | | |

៣៧. តើទម្រង់១០១៨ អាចយកទៅប្រើប្រាស់សំរាប់ការចុះឈ្មោះ និងបោះឆ្នោតពេលខាងមុខបានដែរឬទេ?

☐ បាន ☐ មិនបាន ☐ មិនស្គាល់

៣៨. តើអ្នកមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ក្នុងពេលបច្ចុប្បន្ននេះដែរឬទេ?

☐ ☐ មាន ☐ ☐ មិនមាន

៣៩. តើអត្តសញ្ញាណប័ណ្ណផុតកំណត់ពេលប្រើប្រាស់ អាចប្រើក្នុងពេលបោះឆ្នោតឆ្នាំ២០១២ និង២០១៣ខាងមុខបានដែរឬទេ?

☐ បាន ☐ ☐ មិនបាន ☐ មិនដឹង

៤០. តើអ្នកត្រូវបានគេដកហូត កត់លេខអត្តសញ្ញាណប័ណ្ណ ឬឯកសារបញ្ជាក់អត្តសញ្ញាណដែលអ្នកប្រើសំរាប់ការចុះឈ្មោះបោះឆ្នោត និងផ្ទៀងផ្ទាត់ឈ្មោះក្នុងឆ្នាំ២០១១នេះ ដែរឬទេ?

☐ មាន ☐ គ្មានទេ (រំលងសំណួរទី៤១)

បើមានសូមបញ្ជាក់ពីមូលហេតុក្នុងការដក:

.......................................................................................................................................................................................................

.......................................................................................................................។

៤១. តើនរណាជាអ្នកដកហូត កត់លេខអត្តសញ្ញាណប័ណ្ណ ឬឯកសារបញ្ជាក់អត្តសញ្ញាណរបស់អ្នក? (ចម្លើយមានតែមួយ)

| | | | |
|---|---|---|---|
| ☐ | ក្រុមហ៊ុន | ☐ | មេភូមិ |
| ☐ | មេឃុំ | ☐ | ប៉ូលីស |
| ☐ | ផ្សេងៗ.................................................................................................................................................។ | | |

៤២. កន្លងមក តើអ្នកបានទទួលព័ត៌មានអំពីការបោះឆ្នោតពីប្រភពណាដែរ? (ចម្លើយមានច្រើន)

| | | | |
|---|---|---|---|
| ☐ | យុទ្ធនាការផ្សព្វផ្សាយការបោះឆ្នោតរបស់គណៈកម្មការរៀបចំការបោះឆ្នោតនៅក្នុងឃុំ/ខេត្ត | ☐ | អ្នកជិតខាង/សមាជិកសហគមន៍ គ្រួសារ/មិត្តភ័ក្តិ |
| ☐ | វិទ្យុ/ទូរទស្សន៍ | ☐ | ប្រជុំ/កិច្ចប្រជុំសាធារណៈ/យុទ្ធនាការ |
| ☐ | គណបក្សនយោបាយ | ☐ | មេភូមិ |
| ☐ | កាសែត/ខិត្តប័ណ្ណ/រូបភាពផ្ទាំងធំ (poster) | ☐ | អាជ្ញាធរ |
| ☐ | ខ្ញុំមិនបានទទួលព័ត៌មានអ្វីទាំងអស់ពីដំណើរការ នៃការបោះឆ្នោត | ☐ | បដិសេធឆ្លើយ |
| ☐ | ផ្សេងៗ (សូមបញ្ជាក់)៖.........................................................................................................................។ | | |

### III. ការបោះឆ្នោតនាពេលខាងមុខ

៤៣. តើអ្នកនឹងទៅបោះឆ្នោត ជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០១២ ខាងមុខនេះដែរឬទេ?

☐ ខ្ញុំនឹងទៅបោះឆ្នោត (រំលងសំណួរទី៤៤) ☐ ខ្ញុំនឹងមិនទៅបោះឆ្នោតទេ

៤៤. បើសិនអ្នកមិនទៅចូលរួមបោះឆ្នោតក្រុមប្រឹក្សាឃុំ/សង្កាត់២០១២ ពេលខាងមុខទេ តើមកពីមូលហេតុអ្វី? (ចម្លើយមានច្រើន)

| **ហេតុផលសំខាន់** | | | |
|---|---|---|---|
| ☐ | មិនចំណាប់អារម្មណ៍ក្នុងផ្នែកនយោបាយ | ☐ | ខ្ញុំមិនអាចទៅកន្លែងបោះឆ្នោតនោះបាន |
| ☐ | ការបោះឆ្នោតរបស់ខ្ញុំមិនធ្វើឱ្យមានការផ្លាស់ប្តូរនោះទេ | ☐ | ដោយសារតែខ្ញុំពិការ |
| ☐ | ខ្ញុំមិនមានការយល់ដឹងគ្រប់គ្រាន់ពីបញ្ហានយោបាយ | ☐ | មិននៅផ្ទះ ឬផ្លាស់ប្តូរលំនៅដ្ឋាន |
| ☐ | មិនមានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោត | ☐ | មិនមានលុយសម្រាប់ធ្វើដំណើរទៅបោះឆ្នោត |
| ☐ | មិនអាចចុះឈ្មោះបាន | ☐ | គេឱ្យលុយ/អំណោយ ដើម្បីកុំឱ្យខ្ញុំទៅបោះឆ្នោត |
| ☐ | មិនដឹងពីរបៀបបោះឆ្នោត | ☐ | គ្មានហេតុផលពិសេសណាមួយទេ |
| ☐ | មិនដឹងពេលណាគេបោះឆ្នោត | ☐ | មិនមានឯកសារគ្រប់គ្រាន់ |
| ☐ | មិនស្គាល់កន្លែងទៅបោះឆ្នោត | ☐ | បដិសេធឆ្លើយ |
| ☐ | ផ្សេងៗ (សូមបញ្ជាក់)៖..........................................................។ | | |

៤៥. សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០១២ខាងមុខ តើអ្នកនឹងជ្រើសរើសគណបក្សដដែលដែរឬទេ?

☐ គណបក្សដដែល ☐ ជ្រើសរើសគណបក្សថ្មី ☐ មិនចង់និយាយ ☐ មិនទាន់សំរេចចិត្ត

សូមបញ្ជាក់ពីមូលហេតុណាមួយ បើសិនជាអាច
..........................................................................................................។

៤៦. តើអ្នកចង់បានមេឃុំ/ចៅសង្កាត់ ជាបុរស ឬជាស្ត្រី សម្រាប់ការបោះឆ្នោតក្រុមប្រឹក្សាឃុំ/សង្កាត់ឆ្នាំ២០១២ខាងមុខ?

☐ បុរស ☐ ស្ត្រី ☐ បុរស ឬស្ត្រីដូចគ្នា ☐មិនដឹង/មិនមានយោបល់

សូមបញ្ជាក់ពីមូលហេតុណាមួយ..........................................................................................................។

៤៧. តើអ្នកចង់បានប្រព័ន្ធបោះឆ្នោតជារបៀបបោះយ៉ាងដូចម្តេច ដែរនៅពេលខាងមុខ?

☐ បោះឲ្យបុគ្គលដែលអ្នកពេញចិត្ត ☐ បោះឲ្យគណបក្សដែលខ្លួនស្រឡាញ់

☐ ដោយចំរុះ (បុគ្គលផង និងគណបក្សផង) ☐ មិនដឹង

## ការផ្ទៀងផ្ទាត់ឯកសារជាមួយបញ្ជីឈ្មោះផ្លូវការ

៤៨. សូមកត់ត្រាទិន្នន័យនៃអ្នកផ្តល់បទសម្ភាសន៍ ពីឯកសារប្រើពេលចុះឈ្មោះ ឬពិនិត្យឈ្មោះ ឬកែឈ្មោះចុងក្រោយគេ

| ល.រ | ទិន្នន័យសំខាន់ៗដែលត្រូវស្រង់ | ទិន្នន័យពីក្នុងឯកសារសំគាល់ អត្តសញ្ញាណអ្នកផ្តល់បទសម្ភាសន៍ ប្រើពេលចុះឈ្មោះ ឬបោះឆ្នោត (បំពេញដោយអ្នកសម្ភាសន៍) | | ទិន្នន័យពីក្នុងបញ្ជីឈ្មោះបោះឆ្នោត ផ្លូវការឆ្នាំ ២០១១ (បំពេញដោយស្នាក់ការកណ្តាល) | | កូដ: (បំពេញដោយស្នាក់ការកណ្តាល) ១=ដូចគ្នា ២=មិនដូចគ្នា ឬ មិនពេញលេញ ៣=គ្មានទិន្នន័យនៅក្នុងបញ្ជីអ្នកបោះឆ្នោត | | |
|---|---|---|---|---|---|---|---|---|
| ៤៨-១ | ឈ្មោះ* | នាមត្រកូល: | | នាមត្រកូល: | | ១ | ២ | ៣ |
| | | នាមខ្លួន: | | នាមខ្លួន: | | | | |
| ៤៨-២ | ថ្ងៃ ខែ ឆ្នាំកំណើត | ថ្ងៃ: | | ថ្ងៃ: | | ១ | ២ | ៣ |
| | | ខែ: | | ខែ: | | | | |
| | | ឆ្នាំ: | | ឆ្នាំ: | | | | |
| ៤៨-៣ | ភេទ | ប្រុស ☐ | ស្រី ☐ | ប្រុស ☐ | ស្រី ☐ | ១ | ២ | ៣ |
| ៤៨-៤ | អាសយដ្ឋានបច្ចុប្បន្ន | ភូមិ: | | ភូមិ: | | ១ | ២ | ៣ |
| | | ឃុំ: | | ឃុំ: | | ១ | ២ | ៣ |
| | | ខេត្ត: | | ខេត្ត: | | | | |

*ខុមហ្វ្រែល សន្យាថាប្រើប្រាស់ឈ្មោះរបស់អ្នកផ្តល់ចំលើយសម្រាប់តែផ្ទៀងផ្ទាត់ ជាមួយបញ្ជីឈ្មោះបោះឆ្នោតតែប៉ុណ្ណោះ មិនបង្ហាញដល់អ្នកដ៏ទៃទៀតទេ។

## សំណួរសំរាប់តែអ្នកពិនិត្យបញ្ជី

៤៩. តើអ្នកផ្តល់បទសម្ភាសន៍ មានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោត សំរាប់ឆ្នាំ ២០១១ ដែរឬទេ? (បំពេញដោយស្នាក់ការកណ្តាល)

☐ ☐ មាន☐ ☐ មិនមាន

៥០. បើមានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតសម្រាប់ឆ្នាំ ២០១១ តើមានលេខរៀងទីប៉ុន្មាន? (បំពេញដោយស្នាក់ការកណ្តាល)

មានលេខរៀងទី ៖ ______________________________

# ឧបសម្ព័ន្ធទី ៣ បញ្ជីឈ្មោះបោះឆ្នោតគ ៥ ប រូបភាពសកម្មភាព និងសំរង់ឯកសារផ្សេងៗ

## ក. បញ្ជីឈ្មោះបោះឆ្នោតរបស់គ ៥ ប នៅលើវែបសាយ




## ខ. រូបភាពសកម្មភាព

រូបភាពខាងក្រោម ជាសកម្មភាពក្រុមការងារ របស់អង្គការខុមហ្វ្រែល មានអង្គការដៃគូ ចំនួន ៣ ដូចជា KYA, PDP-Center និង NICFEC ជួបជាមួយគណៈបក្សនយោបាយ ក្រសួងមហាផ្ទៃ និង គ.ជ.ប ដើម្បីពិគ្រោះយោបល់ និងសហប្រតិបត្តិការ លើគំពោងស្រាវជ្រាវ និងទំរង់សំណួរ។

### ១.កិច្ចប្រជុំជាមួយគណបក្សនយោបាយ




ជួបជាមួយ ប្រធានគណបក្សសិទ្ធិមនុស្ស ដឹកនាំដោយ ឯកឧត្តម **គឹម សុខា** នៅឯស្នាក់ការគណបក្ស ថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ២០១១



ជួបជាមួយ ឯកឧត្តម **ញឹក ប៊ុនឆៃ** ប្រធានគណបក្ស ហ៊្វុនស៊ិនប៉ិច នៅឯស្នាក់ការគណបក្ស ថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០១១



ជួបជាមួយ គណបក្សនរោត្តមរណឫទ្ធិ ដឹកនាំដោយ
ឯកឧត្តម **សៅ រ៉ានី** នៅឯស្នាក់ការគណបក្ស
ថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ២០១១



ជួបជាមួយ ប្រធានគណបក្សសមរង្ស៊ី ដឹកនាំដោយ
ឯកឧត្តម **សុន ឆ័យ** នៅឯស្នាក់ការគណបក្ស
ថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០១១

## ២. កិច្ចប្រជុំជាមួយក្រសួងមហាផ្ទៃ និង គ.ជ.ប



ជួបជាមួយ តំណាងក្រសួងមហាផ្ទៃ ដឹកនាំដោយ
ឯកឧត្តម **សក់ សេដ្ឋា** នៅឯស្នាក់ការ ក្រសួងមហាផ្ទៃ
ថ្ងៃទី ០២ ខែសីហា ឆ្នាំ២០១១



ជួបជាមួយ តំណាង គ.ជ.ប ដឹកនាំដោយ
ឯកឧត្តម **អែម សុផាត** នៅឯស្នាក់ការ គ.ជ.ប
ថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០១១

## ៣. ប្រជុំក្រុមការងារពិភាក្សាគំរោង និងលើកបញ្ហាកើតមានក្នុងគំរោង





ការពិភាក្សា និងរាយការណ៍នូវបញ្ហាដែលកើតមានឡើងដល់គំរោង របស់លេខា ខេត្ត/រាជធានី ជាមួយ លោក **គល់ បញ្ញា** នាយកប្រតិបត្តិអង្គការខុមហ្វ្រែល នៅថ្ងៃទី ២១ ធ្នូ ឆ្នាំ២០១១។



ការជជែកគ្នារវាងមន្ត្រីកម្មវិធី ជាមួយនិងលេខា ខេត្ត/រាជធានី របស់ខុមហ្វ្រែល ដើម្បីស្វែងរកចំណុចខ្លាំង ចំណុចខ្សោយ និងការផ្តល់អនុសាសន៍ ដល់គំរោងកាលពីថ្ងៃទី ២១ ធ្នូ ឆ្នាំ២០១១ នៅឯស្នាក់ការខុមហ្វ្រែល។

.

## ៤. វគ្គបណ្តុះបណ្តាលសិក្ខាកាមតាមខេត្ត/រាជធានី



សកម្មភាពបង្រៀនអ្នកសង្កេតការណ៍ មុនចុះសំភាសន៍ប្រជាពលរដ្ឋ នៅខេត្តកំពង់ចាម ដែលមានអ្នកសង្កេតការណ៍ចូលរួម ចំនួន ៣៣នាក់ មកពីខេត្តចំនួន៣ មានស្វាយរៀង ព្រៃវែង និងកំពង់ចាម នៅថ្ងៃទី ២០-២១ ខែ តុលា ឆ្នាំ២០១១ ។





សកម្មភាពបង្រៀននៅក្នុងខេត្ត សៀមរាប នៅថ្ងៃទី ២០-២១ តុលា ២០១១
មានអ្នកសង្កេតការណ៍ចំនួន ៣៧នាក់ មកពីខេត្ត ព្រះវិហារ ឧត្តរមានជ័យ សៀមរាប និងកំពង់ធំ។

## ៥. សកម្មភាពអ្នកសង្កេតការណ៍ ចុះសំភាសន៍ប្រជាពលរដ្ឋតាមមូលដ្ឋាន





លោក ឡឹក យឿន ជាអ្នកសង្កេតការណ៍ បានចុះសំភាសន៍ប្រជាពលរដ្ឋនៅក្នុងភូមិ ពង្រ ឃុំ កន្ទ្រាំង ស្រុកប្រាសាទបាគង ខេត្តសៀមរា និង លោក ឈឹម វន ជាអ្នកសង្កេតការណ៍ខុមហ្វ្រែល បានសំភាសន៍ប្រជាពលរដ្ឋនៅខេត្តកំពង់ចាម កាលពីថ្ងៃទី ៩ ខែ វិច្ឆិកា ២០១១។





សកម្មភាព លោក ច្រេង គឹមស៊ាន បានធ្វើដំណើរតាមភូមិ ចុះសំភាសន៍ប្រជាពលរដ្ឋក្នុងស្រុកសន្ទុក ខេត្តកំពង់ធំ ដែលកំពង់តែលិចទឹក នៅថ្ងៃទី ២៨ វិច្ឆិកា ឆ្នាំ២០១១។



ការធ្វើដំណើរជុំះម៉ូតូ របស់ លោក ហុក ហេង តាមផ្លូវលិចទឹកដ៏លំបាកពីថ្នល់ជាតិទៅភូមិ ស្រះព្រីង ឃុំបាជាយ ស្រុកបាជាយ ខេត្តកំពង់ចាម





ការធ្វើដំណើរជិះទូក របស់លោក ហុង ហេង ដើម្បីសំភាសន៍ប្រជាពលរដ្ឋ ពីផ្ទះមួយទៅផ្ទះមួយដែលកំពង់លិចទឹកនៅក្នុងភូមិ ច្បារអំពៅ ឃុំ ច្បារអំពៅ ស្រុកបាជាយ ខេត្តកំពង់ចាម នៅថ្ងៃទី ២៩ វិច្ឆិកា ២០១១






ភូមិពោធិ៍រៀងជើង ឃុំពោធិ៍រៀង ស្រុកកំពង់លាវ ខេត្តព្រៃវែង ដ៏សែនឆ្ងាយ តម្រូវឲ្យអ្នកសង្កេតការណ៍ លោកស្រី ប៊ុត បុប្ផាថូ ការជួលទូក ចុះទៅសំភាសន៍ប្រជាពលរដ្ឋនៅថ្ងៃទី ២៨ វិច្ឆិកា ២០១១។

## ៦ .សកម្មភាពបញ្ចូលទិន្នន័យ



# គ. សំរង់ឯកសារផ្សេងៗ

ថ្ងៃពុធ ទី២៩ ខែកុម្ភៈ ឆ្នាំ២០១២ ខេមបូឌា ដេលី ៣

ព័ត៌មានជាតិ

## អង្គការ ខុមហ្វ្រែល និយាយថា បញ្ជីឈ្មោះអ្នកបោះឆ្នោតរបស់គ.ជ.ប មានបញ្ហា

LAUREN CROTHERS និង អ៊ាង ម៉េងឡេង
ខេមបូឌា ដេលី

អ្នកសង្កេតការណ៍បោះឆ្នោតមួយក្រុមបាននិយាយកាលពីម្សិលមិញថា ដោយនៅសល់តែរយៈពេលបួនខែទៀតដល់ថ្ងៃបោះឆ្នោតឃុំ-សង្កាត់នោះ មានការព្រួយបារម្ភថាឈ្មោះអ្នកបោះឆ្នោតចំនួន១,៥លាននាក់ មិនត្រូវបានកត់ត្រាទុកឲ្យបានត្រឹមត្រូវក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតថ្នាក់ជាតិនេះទេ មានន័យថាអ្នកទាំងនោះអាចបាត់បង់សិទ្ធិក្នុងការបោះឆ្នោតបាន។

គណកម្មាធិការដើម្បីការបោះឆ្នោតដោយសេរីនិងយុត្តិធម៌ហៅកាត់ថាខុមហ្វ្រែល បានរកឃើញថា ខណៈដែល៩៤,២ភាគរយនៃអ្នកមានសិទ្ធិបោះឆ្នោតក្នុងប្រទេសកម្ពុជាបានចុះឈ្មោះបោះឆ្នោតរួចហើយនោះ តួលេខរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតហៅកាត់ថា គ.ជ.ប បែរជាបង្ហាញថា ១០៤ភាគរយនៃអ្នកមានសិទ្ធិបោះឆ្នោតបានចុះឈ្មោះរួចហើយទៅវិញ។

លោក គល់ បញ្ញា នាយកប្រតិបត្តិអង្គការខុមហ្វ្រែល បាននិយាយថាការរកឃើញនេះបានធ្វើឲ្យធម្មនុញ្ញភាពនៃការបោះឆ្នោតឃុំ-សង្កាត់ដែលចាំបាច់ក្នុងការកំណត់រចនាសម្ព័ន្ធនយោបាយថ្នាក់ក្រោមនៅកម្ពុជា ធ្លាក់ទៅក្នុងភ្លឹមន្ទិល។

លោក គល់ បញ្ញា បានថ្លែងក្នុងឱកាសចេញផ្សាយការរកឃើញនេះថា "ជាពិសេស យើងមានការព្រួយបារម្ភចំពោះអ្នកបោះឆ្នោតទាំងឡាយណាដែលបានចុះឈ្មោះ[បោះឆ្នោត]រួចហើយ ប៉ុន្តែមិនឃើញមានឈ្មោះរបស់ខ្លួនក្នុងបញ្ជី ឬចំពោះអ្នកដែលគ្មានទិន្នន័យច្បាស់លាស់ ពីព្រោះបញ្ហានេះធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់ពួកគាត់ក្នុងការបោះឆ្នោត"។ លោកបានថ្លែងថា "នេះគឺជារឿងដែលត្រូវមានការផ្លាស់ប្តូរ មុនថ្ងៃបោះឆ្នោតមកដល់។ ប្រជាពលរដ្ឋជាច្រើន នឹងមកដល់ហើយបែរជាមិនអាចបោះឆ្នោតបាន"។

លោកបានបន្ថែមថា "វាស្មើនឹងចំនួនអ្នកបោះឆ្នោតប្រមាណ១,៥លាននាក់ ហើយខ្លះក្នុងចំណោមនេះទំនងជានឹងបាត់បង់សិទ្ធិក្នុងការបោះឆ្នោតនាពេលខាងមុខនេះ"។

ការរកឃើញរបស់ ខុមហ្វ្រែល នេះ ផ្អែកលើការស្ទង់មតិអ្នកបោះឆ្នោតចុះឈ្មោះរួចហើយចំនួន៨,៧៧២នាក់ ដែលត្រូវបានជ្រើសរើសចោះៗនៅទូទាំងប្រទេសកម្ពុជា ចាប់ពីខែតុលារហូតដល់ខែមករា។ ខុមហ្វ្រែល បានប្រៀបធៀបទិន្នន័យដែលបានមកពីការស្ទង់មតិរបស់ខ្លួន ជាមួយបញ្ជីឈ្មោះធ្វើបច្ចុប្បន្នភាពហើយរបស់គ.ជ.ប. ហើយបានរកឃើញថាទិន្នន័យរបស់អ្នកមានសិទ្ធិបោះឆ្នោតចំនួន១៧,២ភាគរយ ដែលខ្លួនបានស្ទង់មតិ ពុំឃើញមាននៅលើបញ្ជីឈ្មោះបោះឆ្នោតផ្លូវការរបស់គ.ជ.ប.ឡើយ ឬបើមិនដូច្នេះទេ ឈ្មោះរបស់ពួកគាត់ត្រូវបានគេប្តូរ។

ភាពមិនត្រឹមត្រូវនៃបញ្ជីឈ្មោះអ្នកបោះឆ្នោត មានកម្រិតខ្ពស់បំផុតនៅក្នុងរាជធានីភ្នំពេញ។ ខុមហ្វ្រែល បានរកឃើញថាអ្នកបោះឆ្នោតចំនួន១២,៧ភាគរយ ដែលពួកគេបានស្ទង់មតិ ពុំមានទិន្នន័យកត់ត្រាទុកនៅលើបញ្ជីឈ្មោះអ្នកបោះឆ្នោតទេ។

ខុមហ្វ្រែល បានឲ្យដឹងថាតួលេខសរុបនៃប្រជាជនដែលបានចុះឈ្មោះបោះឆ្នោតនៅថ្ងៃទី៣ខែមិថុនាក៏ខ្ពស់ជាងតួលេខនៃប្រជាជនកម្ពុជាដែលមានសិទ្ធិបោះឆ្នោតពិតប្រាកដឆ្ងាយណាស់ដែរ គឺខ្ពស់ជាងដល់ទៅ ៤០០.០០០នាក់ឯណោះ។

លោក គង់ រ៉ាវិន អ្នកសម្របសម្រួលស្ថិតិផ្នែកសង្កេតការណ៍បាននិយាយនៅក្នុងសន្និសីទសារព័ត៌មាននេះថា ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតនៅកម្ពុជាមានសរុបចំនួន៨,៨លាននាក់ ប៉ុន្តែបញ្ជីឈ្មោះបោះឆ្នោតរបស់ គ.ជ.ប សម្រាប់ការបោះឆ្នោតនេះបែរជាមានឈ្មោះអ្នកបោះឆ្នោតដល់ទៅ៩,២លាននាក់ទៅវិញ។

គេអាចសន្មតបានថា បញ្ហានេះអាចដោយសារតនៅមាន "ឈ្មោះអ្នកបោះឆ្នោតខ្មោច" និងបញ្ជីឈ្មោះថតចម្លងចេញពីបញ្ជីឈ្មោះ[អ្នកបោះឆ្នោត]កាលពីឆ្នាំ២០១១។

ខុមហ្វ្រែល បានសរសេរថា មិនដូច្នោះទេ "ប្រហែលជាដោយសារមានបញ្ហាបច្ចេកទេសនៅក្នុងការប៉ាន់ប្រមាណរបស់គ.ជ.ប"។

លោក ទេព នីថា អគ្គលេខាធិការ គ.ជ.ប បាននិយាយថា លោកមិនទាន់បានឃើញសេចក្តីសង្ខេបនៃការស្ទង់មតិរបស់ខុមហ្វ្រែលទេ ប៉ុន្តែលោកបានទទួលស្គាល់ថា បញ្ជីឈ្មោះអ្នកបោះឆ្នោតនោះ គឺពិតជាមិនទាន់សុក្រឹតមែន។ លោកបានថ្លែងថា "យើងដឹងថាបញ្ជីឈ្មោះអ្នកបោះឆ្នោតនៅមិនទាន់សុក្រឹតទេ ប៉ុន្តែយើងកំពុងតែព្យាយាមកែលម្អ ដើម្បីកុំឲ្យមានកំហុសនៅពេលក្រោយទៀត"។ លោកបានថ្លែងបន្ថែមថា ចំនួនអ្នកចុះឈ្មោះបោះឆ្នោតខ្ពស់ជ្រុលនេះគឺដោយសារការធ្វើចំណាកស្រុក ហើយឈ្មោះអ្នកបោះឆ្នោតមិនត្រូវបានលុបចេញពីបញ្ជីទេ។

ទោះជាយ៉ាងណា លោក ទេព នីថា បាននិយាយថា ការបោះឆ្នោតនឹងប្រព្រឹត្តទៅតាមការគ្រោងទុក។ លោកបានថ្លែងថា "ការបោះឆ្នោតនឹងនៅតែបន្ត ព្រោះតួលេខរបស់ខុមហ្វ្រែលបានមកពីការស្ទង់មតិមួយ ហើយយើងមិនដឹងថា តើពួកគេបានប្រើរូបមន្តអ្វីទេ"។

លោក ជាម យៀប សមាជិកសភា មកពីគណបក្សប្រជាជនកម្ពុជាកំពុងកាន់អំណាច បានសម្តែងមន្ទិលអំពីលទ្ធផលនៃការរកឃើញរបស់ខុមហ្វ្រែល ដោយសារតែលទ្ធផលទាំងនេះផ្អែកលើការស្ទង់មតិអ្នកបោះឆ្នោតចោះៗមិនមែនលើចំនួនអ្នកបោះឆ្នោតទូទាំងប្រទេសនោះទេ។

លោក ជាម យៀប ថ្លែងថា "ខុមហ្វ្រែល មិនបានធ្វើការស្ទង់មតិទូទាំងប្រទេសទេ ប៉ុន្តែ គ.ជ.បវិញ បានធ្វើការងារនេះទូទាំងប្រទេសកម្ពុជា។ ខ្ញុំជឿជាក់លើតួលេខរបស់ គ.ជ.ប ព្រោះគេមានបណ្តាញនៅទូទាំងប្រទេសចាប់ពីថ្នាក់ជាតិរហូតដល់ថ្នាក់ភូមិ"។

*ប្រែសម្រួលដោយ ហាម សុផាណ្ណា*
*និង ឡឿង សារ៉ាតា*

# Election Body Denies 1.5M Votes at Risk

BY LAUREN CROTHERS AND EANG MENGLENG
THE CAMBODIA DAILY

The National Election Committee (NEC) yesterday rejected a report by an election monitoring group, which found that 1.5 million voters could be at risk of losing their right to vote in the upcoming commune election.

The Committee for Free and Fair Elections (Comfrel) on Tuesday released the results of a survey that found that 1.5 million voters have not been properly recorded in the national voter list, endangering their right to vote.

"The figures Comfrel issued on Tuesday are unacceptable," NEC Secretary-General Tep Nytha said. "We would be sad if these Comfrel figures were true, but we don't believe that they are."

He added: "The NEC has not received that many complaints from voters saying that their names were lost from the list."

The Comfrel survey also found that 94.2 percent of the country's eligible voters have registered to cast their vote, though the NEC's figures show that 104 percent of voters have registered to cast a ballot.

Comfrel's Executive Director Koul Panha said he stood by his

## Election...

CONTINUED FROM PAGE 1

organization's findings, which were based on a survey of 8,772 registered voters between October and January.

"Comfrel stands by those numbers, and the NEC should find a solution to prevent conflict from happening," Mr. Panha said, adding that people's rights were being violated and that would make them angry, particularly in cities.

"In Phnom Penh, the people are well informed and they are committed to the election, so they protest if things go wrong," he said.

"I think especially in the cities, people will be very angry—I observed before that they shout outside the [voter] station, 'Why can I not find my name?'"

In contrast, he said, voters turned away on polling day in rural areas tend to quietly return home, "and that's a problem."

Comfrel also found that there are only 8.8 million eligible voters in Cambodia, which is a staggering 400,000 people less than the 9.2 million names on the country's official voter list.

In an interview on Tuesday, Mr. Nytha agreed that the voter list was bloated, but he said disgruntled voters would have to wait until the next voter registration period, which is later this year, to try to rectify the problem.

Independent political analyst Lao Mong Hay said the NEC should be ensuring that voting day issues are kept to an absolute minimum, and problems should be addressed now.

"I would encourage the NEC to take action to address the issue," he said. "Why delay it? Get people to work on measures to improve the system and correct these flaws."

## គ.ជ.ប៖ ការរកឃើញរបស់ ខុមហ្វ្រែលលើបញ្ជី ឈ្មោះបោះឆ្នោតឆ្នាំ ២០១១ ពុំមានភាពត្រឹមត្រូវ

Monday, 05 March 2012 14:33 ដោយ: អេង គីមជាង-Posted: ID-009

**ភ្នំពេញ:** គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានអះអាងថា ការស្រាវជ្រាវរកលទ្ធផលលើបញ្ជីឈ្មោះបោះឆ្នោត របស់គណៈកម្មាធិការ ដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ ហៅកាត់ថា ខុមហ្វ្រែល ទាក់ទងនឹងការធ្វើសវនកម្មលើបញ្ជីបោះឆ្នោតឆ្នាំ២០១១ ពុំមានលក្ខណៈត្រឹមត្រូវទេ។

យោងតាមសេចក្តីប្រកាសព័ត៌មានរបស់ គ.ជ.ប បានឲ្យដឹងថា លទ្ធផលរកឃើញរបស់ខុមហ្វ្រែល ពុំមានភាពត្រឹមត្រូវ ព្រោះថា យោងទៅតាមអំឡុងពេលធ្វើសវនកម្ម គឺខុមហ្វ្រែលធ្វើសវនកម្មទៅលើបញ្ជីបោះឆ្នោតមួយ ដែលកំពុងតែដំណើរការនៅឡើយ ដូច្នេះសវនកម្មនោះ ពុំមែនធ្វើទៅលើបញ្ជីបោះឆ្នោត ដែល មានបញ្ជីពេញលេញជាផ្លូវការទេ។ បញ្ជីបោះឆ្នោតឆ្នាំ២០១១ គ.ជ.ប ទើបតែផ្តល់សុពលភាពនៅថ្ងៃ ទី៣១ ខែធ្នូ ឆ្នាំ២០១១ ហើយខុមហ្វ្រែលបានទាក់ទងយកបញ្ជីបោះឆ្នោតផ្លូវការនេះ នៅថ្ងៃទី១៣ ខែមករា ក្រោយការធ្វើសវនកម្ម។

សេចក្តីប្រកាសដដែលបានបន្តថា សវនកម្មរបស់ខុមហ្វ្រែល ពុំមានភាពដែលគួរឲ្យទុកចិត្តបាន ដូចនៅឆ្នាំ ២០០៨ ។ ខុមហ្វ្រែលធ្លាប់បានធ្វើសវនកម្មលើបញ្ជីបោះឆ្នោតចំនួន២លើក ហើយលទ្ធផលតួលេខទាំងពីរ លើកនោះ មិនដូចគ្នាឡើយ។ លើសពីនេះទៀតការយល់ឃើញរបស់អង្គការមួយនេះពុំបានផ្អែកលើភស្តុតាងទិន្នន័យច្បាស់លាស់ឡើយ។ ឧទាហរណ៍ការលើកឡើងថា កាលពីឆ្នាំ២០០៨ អ្នកមានសិទ្ធិបោះឆ្នោត «ប្រមាណ៤៤ម៉ឺននាក់ មិនអាចបោះឆ្នោតបានដោយសារតែជួបបញ្ហារក ឈ្មោះមិនឃើញនៅការិយាល័យបោះឆ្នោត»។

សេចក្តីប្រកាសបន្តថា ចំពោះបញ្ហាអ្នកបោះឆ្នោតខកខានពុំបានបោះឆ្នោតនេះ គ.ជ.ប ចាំច្បាស់ថា ក្រោយពេលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០០៧ ខុមហ្វ្រែលបានចុះទៅសាកសួរអ្នកបោះឆ្នោតចំនួន ២៩០នាក់ ក្នុង១៥ឃុំ សង្កាត់ និង១៥ខេត្ត-ក្រុង ហើយក្នុងចំណោមនោះ គឺមាន៥៤នាក់ ដែលមិនបានបោះឆ្នោត ដោយមូលហេតុលើសពីបញ្ហារកឈ្មោះពុំឃើញនោះទៅទៀត។

ដូច្នេះដើម្បីវាយតម្លៃឲ្យបានត្រឹមត្រូវ ខុមហ្វ្រែលពុំអាចផ្អែកទៅលើការសាកសួរអ្នកបោះឆ្នោតចំនួនតិច ដូច ជា ២៩០នាក់ (៣-៤នាក់ក្នុង១ឃុំ សង្កាត់)ហើយទាញយោបល់សរុបថា ក្នុងឆ្នាំបោះឆ្នោតនេះ មានមនុស្សរាប់ម៉ឺននាក់ពុំអាចបោះឆ្នោតបាន ដោយសារមូលហេតុតែមួយ «រកឈ្មោះរបស់ពួកគេមិនឃើញ»៕

ភ្នំពេញ ប៉ុស្តិ៍ | The Phnom Penh Post





## មានការទាមទារប្តូរប្រព័ន្ធចុះឈ្មោះបោះឆ្នោត

WEDNESDAY, 29 FEBRUARY 2012 12:01 មាស សុខជា

Share Tweet 0

**ភ្នំពេញ:** ក្នុងវេទិកាតុមូលមួយ កាលពីម្សិលមិញ អង្គការសង្គមស៊ីវិល និងគណបក្សនយោបាយបានទាមទារឲ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ផ្លាស់ប្តូរប្រព័ន្ធចុះឈ្មោះអ្នកបោះឆ្នោតនាពេលបច្ចុប្បន្ន ដោយពួកគេអះអាងថា ប្រព័ន្ធនេះ បានធ្វើឲ្យបាត់ឈ្មោះអ្នកបោះឆ្នោត។

តាមរបាយការណ៍ស្ទង់មតិរបស់អង្គការ COMFREL ស្តីពីបញ្ជីឈ្មោះអ្នកបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោតឆ្នាំ ២០០៨ បានឲ្យដឹងថា អ្នកមានសិទ្ធិបោះឆ្នោតចំនួន ៤៤០០០០ នាក់ មិនអាចបោះឆ្នោតបានទេ ដោយសារតែមិនអាចរកឈ្មោះរបស់ពួកគេឃើញ នៅមណ្ឌលបោះឆ្នោត។

ដោយសម្អាងលើហេតុផលនេះហើយ ទើបក្រុមអង្គការសង្គមស៊ីវិល និងគណបក្សនយោបាយ ទាមទារឲ្យមានការផ្លាស់ប្តូរទាំងស្រុង ដើម្បីធ្វើឲ្យការចុះឈ្មោះបោះឆ្នោតងាយស្រួល និងធានាគុណភាពនៃបញ្ជីឈ្មោះអ្នកបោះឆ្នោត។ ប្រព័ន្ធថ្មី ត្រូវកំណត់រយៈពេលចុះឈ្មោះបោះឆ្នោតបានគ្រប់ពេលក្នុងអំឡុងម៉ោងធ្វើការ។

សេចក្តីព្រាងអនុសាសន៍រួម ស្តីពីបញ្ជីឈ្មោះអ្នកបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោត របស់សង្គមស៊ីវិល បានសរសេរថា៖ «រដ្ឋាភិបាលត្រូវធ្វើវិសោធនកម្មបទប្បញ្ញត្តិ ស្តីពីការចេញអត្តសញ្ញាណប័ណ្ណ ដែលត្រូវតែអនុញ្ញាតឲ្យប្រើប្រាស់អស់មួយជីវិត។ ប្រជាពលរដ្ឋត្រូវបានលើកទឹកចិត្តឲ្យផ្លាស់ប្តូររូបថតរបស់ខ្លួន បន្ទាប់ពីប្រើប្រាស់អត្តសញ្ញាណប័ណ្ណបាន ២០ ឆ្នាំ»។

អនុសាសន៍នោះបន្ថែមថា បញ្ជីឈ្មោះអ្នកបោះឆ្នោត ត្រូវបញ្ចូលក្នុងទិន្នន័យអត្តសញ្ញាណប័ណ្ណ សម្រាប់ពលរដ្ឋម្នាក់ៗ ហើយ គ.ជ.ប ត្រូវប្រើទិន្នន័យនោះ ខណៈដែលពលរដ្ឋម្នាក់ៗ មានអត្តសញ្ញាណប័ណ្ណអចិន្ត្រៃយ៍។

លោក គល់ បញ្ញា នាយកប្រតិបត្តិអង្គការ COMFREL បានថ្លែងក្នុងវេទិកាតុមូលថា បញ្ជីឈ្មោះអ្នកបោះឆ្នោតឆ្នាំ ២០១១ មានសារៈសំខាន់ សម្រាប់ការបោះឆ្នោតឃុំ-សង្កាត់ ខែមិថុនា ឆ្នាំ ២០១២ ដែល គ.ជ.ប ត្រូវធានាថា ក្នុងការបោះឆ្នោតខាងមុខនេះ អ្នកបោះឆ្នោតមិនបាត់ឈ្មោះរបស់ខ្លួនដូចមុនទៀតទេ។ លោកបន្តថា៖«យើងគួរផ្លាស់ប្តូរប្រព័ន្ធចុះឈ្មោះបោះឆ្នោតនេះ ដើម្បីឲ្យបញ្ជីឈ្មោះអ្នកបោះឆ្នោត អាចល្អប្រសើរឡើង»។ លោកបន្តថា ក្រសួងមហាផ្ទៃ ត្រូវចេញអត្តសញ្ញាណប័ណ្ណដល់ប្រជាជន ដោយគ្មានថ្ងៃផុតកំណត់ ដែលអាចប្រើប្រាស់មួយជីវិត ហើយផ្ទេរទៅឲ្យ គ.ជ.ប ហើយ គ.ជ.ប ត្រូវធានាថា អ្នកណាក៏ដោយ ដែលកាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ត្រូវមានសិទ្ធិបោះឆ្នោត។

លោក គួយ ប៊ុនរឿន តំណាងរាស្ត្រមកពីគណបក្ស សម រង្ស៊ី លោក ទឹម ប៉ូរ៉ាក់ មន្ត្រីជាន់ខ្ពស់គណបក្សសិទ្ធិមនុស្ស និងលោក ហង្ស ពុទ្ធា នាយកប្រតិបត្តិអង្គការ NIFEC បានគាំទ្រអនុសាសន៍របស់ COMFREL ។

លោក ហង្ស ពុទ្ធា បាននិយាយថា៖ «ខ្ញុំសូមអំពាវនាវដល់ម្ចាស់ជំនួយជួយកម្ពុជាឲ្យមានការបោះឆ្នោតកាន់តែល្អប្រសើរ»។

លោក ទេព នីថា អគ្គលេខាធិការ គ.ជ.ប បានថ្លែងថា ការផ្លាស់ប្តូរប្រព័ន្ធបោះឆ្នោត មិនមែនជាកាតព្វកិច្ចរបស់ គ.ជ.ប ទេ វាផ្អែកលើច្បាប់ និងថា កម្ពុជា មិនអាចផ្លាស់ប្តូរប្រព័ន្ធចុះឈ្មោះបោះឆ្នោតបច្ចុប្បន្នបានទេ ដោយអះអាងថា អ្វីដែលអង្គការសង្គមស៊ីវិលត្រូវការ គ្មានប្រទេសណាមួយអាចធ្វើបានឡើយ។ ប៉ុន្តែលោកអះអាងថា ក្នុងដំណាក់កាលទី៣ កម្ពុជានឹងផ្លាស់ប្តូរប្រព័ន្ធចុះឈ្មោះបោះឆ្នោត។ លោក បញ្ជាក់ថា៖ «គោលដៅ យើងចង់ធ្វើអ៊ីចឹង ប៉ុន្តែវាមិនទាន់ដល់ស្ថានការណ៍ឆ្នាំ ២០១៣ ទេ»។

លោក ខៀវ សុភ័គ អ្នកនាំពាក្យក្រសួងមហាផ្ទៃ បានថ្លែងថា ចំពោះអត្តសញ្ញាណប័ណ្ណដែលផុតកំណត់រួចហើយ ត្រូវបានឲ្យពន្យារពេលដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៣។ លោកបន្តថា៖«ក្រសួង កំពុងយកចិត្តទុកដាក់យ៉ាងខ្លាំង។ យើងកំពុងបន្តដំណើរការនេះ»៕ TK

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

********

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រ.ក/លេខ ០៣.០០៧/១២ គ.ជ.ប.អគ្គ.៣ស**

រាជធានីភ្នំពេញ ថ្ងៃទី 05 ខែមីនា ឆ្នាំ២០១២

## យោបល់ គ.ជ.ប ចំពោះលទ្ធផលស្រាវជ្រាវរបស់ខុមហ្វ្រែលទាក់ទងនឹងការធ្វើសវនកម្មលើបញ្ជីបោះឆ្នោត ឆ្នាំ២០១១

ក្នុងកិច្ចពិភាក្សាកាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១២ គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា ហៅកាត់ថា (ខុមហ្វ្រែល) បានបង្ហាញអំពីលទ្ធផលទាក់ទងនឹងការធ្វើសវនកម្មលើបញ្ជីបោះឆ្នោត ដែលបានធ្វើការស្រាវជ្រាវចាប់ពីថ្ងៃទី១១ ខែតុលា ឆ្នាំ២០១១ ដល់ថ្ងៃទី១២ ខែមករា ឆ្នាំ២០១២ ។

គ.ជ.ប យល់ឃើញថា លទ្ធផលរកឃើញរបស់ខុមហ្វ្រែលពុំមានភាពត្រឹមត្រូវទេ ព្រោះថា យោងទៅតាមអំឡុងពេលធ្វើសវនកម្ម គឺខុមហ្វ្រែលធ្វើសវនកម្មទៅលើបញ្ជីបោះឆ្នោតមួយដែលកំពុងតែដំណើរការនៅឡើយ ដូច្នេះ សវនកម្មនោះពុំមែនធ្វើទៅលើបញ្ជីបោះឆ្នោតដែលមានភាពជាបញ្ជីពេញលេញជាផ្លូវការ ។ បញ្ជីបោះឆ្នោតឆ្នាំ២០១១ គ.ជ.ប ទើបតែផ្ដល់សុពលភាពនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១ ហើយខុមហ្វ្រែលបានទាក់ទងយកបញ្ជីបោះឆ្នោតផ្លូវការនេះនៅថ្ងៃទី១៣ ខែមករា គឺក្រោយការធ្វើសវនកម្ម ។

ម្យ៉ាងទៀត គ.ជ.ប ពុំបានឃើញថា សវនកម្មនេះបានសិក្សាអំពីលក្ខណៈបញ្ជាក់ពីគុណភាពទាំង ៣យ៉ាងនៃបញ្ជីបោះឆ្នោតផងដែរ ដូចជា ៖

ទី១- ភាពពេញលេញ (ឧទាហរណ៍ ភាគរយរបស់អ្នកមានសិទ្ធិបោះឆ្នោតនៅក្នុងបញ្ជីបោះឆ្នោត)

ទី២- បច្ចុប្បន្នភាព (ដែលបង្ហាញថាតើបញ្ជីនេះមានឈ្មោះអ្នកដែលត្រូវបោះឆ្នោត ឬអត់)

ទី៣- ភាពត្រឹមត្រូវ (ដែលបញ្ជាក់អំពីការបញ្ចូលទិន្នន័យ ឈ្មោះ ថ្ងៃខែឆ្នាំកំណើតត្រឹមត្រូវ ឬយ៉ាងណា)។

កន្លងមក គ.ជ.ប បានសង្កេតឃើញសវនកម្មរបស់ខុមហ្វ្រែលពុំមានភាពដែលគួរឱ្យទុកចិត្តបាន ដូចជា នៅឆ្នាំ២០០៨ ខុមហ្វ្រែលធ្លាប់បានធ្វើសវនកម្មលើបញ្ជីបោះឆ្នោតចំនួន ២លើក ហើយលទ្ធផលតួលេខទាំង ២លើកនោះ មិនដូចគ្នានោះឡើយ ។ លើសពីនេះទៀត ការយល់ឃើញរបស់ខុមហ្វ្រែលពុំបានផ្អែកលើភស្តុតាងទិន្នន័យច្បាស់លាស់ឡើយ ឧទាហរណ៍ ការលើកឡើងថា កាលពីឆ្នាំ២០០៨ អ្នកមានសិទ្ធិបោះឆ្នោត "ប្រមាណ ៥៧ម៉ឺននាក់ មិនអាចបោះឆ្នោតបានដោយសារតែជួបបញ្ហា***រកឈ្មោះមិនឃើញ***នៅការិយាល័យបោះឆ្នោត" ។ គ.ជ.ប សួរថា តើខុមហ្វ្រែលផ្អែកលើទិន្នន័យស្រាវជ្រាវណាមួយដែលចង្អុលថា អ្នកបោះឆ្នោតចំនួន ៥៧ម៉ឺននាក់នោះ មិនអាចបោះឆ្នោតបានដោយសារមូលហេតុតែមួយគត់គឺ "រកឈ្មោះមិនឃើញ" ។ រីឯចំនួន ៥៧ម៉ឺននាក់ ក្នុងការអះអាងច្បាស់លាស់យ៉ាងនេះបានមកពីណា ?

ចំពោះបញ្ហាអ្នកបោះឆ្នោតខកខានពុំបានបោះឆ្នោតនេះ គ.ជ.ប បានចាំយ៉ាងច្បាស់ថា ក្រោយពេលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០០៧ ខុមហ្វ្រែលបានចុះទៅសាកសួរអ្នកបោះឆ្នោតចំនួន ២៩០នាក់ ក្នុង ១៥ឃុំ សង្កាត់ និង ១៥ខេត្ត ក្រុង ហើយក្នុងចំណោមនោះគឺមាន ៥៤នាក់ ដែលមិនបានបោះឆ្នោតដោយមូលហេតុលើសពីបញ្ហារកឈ្មោះពុំឃើញនោះទៅទៀត ។ ដូច្នេះដើម្បីវាយតម្លៃឱ្យបានត្រឹមត្រូវ ខុមហ្វ្រែលពុំអាចផ្អែកទៅលើការសាកសួរអ្នកបោះឆ្នោតចំនួនតិច ដូចជា ២៩០នាក់ (៣-៤នាក់ ក្នុង ១ឃុំ សង្កាត់) ហើយទាញយោបល់សរុបថា ក្នុងឆ្នាំបោះឆ្នោត មាន "មនុស្សរាប់ម៉ឺននាក់" ពុំអាចបោះឆ្នោតបានដោយសារមូលហេតុតែមួយ "រកឈ្មោះរបស់ពួកគេមិនឃើញ " ។

គ.ជ.ប នៅតែបដិសេធទាំងស្រុងអំពីការរកឃើញរបស់ខុមហ្វ្រែលថា មានអ្នកបោះឆ្នោតចំនួន ៤៩ម៉ឺននាក់ ពុំបានបោះឆ្នោតដោយសារមូលហេតុតែមួយគឺ "រកឈ្មោះមិនឃើញ" លើកលែងតែខុមហ្វ្រែលបង្ហាញការរកឃើញរបស់ខ្លួនទៅតាមបែបបច្ចេកទេសសុទ្ធសាធ ដែលពុំមានលក្ខណៈ "នយោបាយ" សម្រាប់បំពុលបរិយាកាសមុនពេលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ នាខែមិថុនា ឆ្នាំ២០១២ ខាងមុខនេះ ។

គ.ជ.ប នឹងធ្វើការសិក្សាបំភ្លឺទៅនឹងសវនកម្មថ្មីៗនេះ នៅពេលដែលខុមហ្វ្រែលបញ្ជូនរបាយការណ៍នៃសវនកម្មរបស់ខ្លួនមក គ.ជ.ប ។/